ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ វគ្គបណ្ដុះបណ្ដាលស្ដីពីសន្តិភាព និងសិទ្ធិមនុស្ស

◆ សំណល់បន្សល់ពីសង្គ្រាម និងសន្តិភាព

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១២ ខែសីហា ឆ្នាំ២០១៧

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

ស្វែងរកការពិត

លេខ២១២ ខែសីហា ឆ្នាំ២០១៧

## មាតិកា

◆ វគ្គបណ្តុះបណ្តាលស្តីពីសន្តិភាព និងសិទ្ធិមនុស្ស ..............................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ សា វិន ប្រធានក្រសួងឃោសនា ..................២

◆ ដំណើផយុវជន-យុវនារីបដិវត្តន៍ ..................................................៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ កុមារីក្នុងសម័យខ្មែរក្រហម ..................................................២០

◆ គ្រូតែងនិពន្ធដែលនៅរស់ជីវិតពីរបបខ្មែរក្រហម ..............................២១

◆ ប្រសិនបើអំបិលផ្អែម ជីវិតនៅតែមានសង្ឃឹម ..............................២៥

◆ អតីតគ្រូរបាំបុរាណ និងចម្រៀង ..............................................២៧

◆ ទោះជាក្មេងកំព្រាក៏នៅតែពុះពារ ..............................................៣០

◆ ធ្នុងត្រីកញ្ចុះ ..................................................................៣៣

**ផ្នែកច្បាប់**

◆ សហព្រះរាជអាជ្ញា បន្តផ្ញើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ បញ្ចប់កិច្ច ...........៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ គរុសិស្សភូមិភាគបាត់ដំបង សិក្សាពីវិធីសាស្ត្របង្រៀន ....................៤៤

◆ សំណល់បន្សល់ពីសង្គ្រាម និងសន្តិភាព .......................................៤៦

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ ប្រសិនបើគ្មានរបបខ្មែរក្រហម យើងនឹងរស់នៅជុំគ្នា .........................៤៩

◆ ខ្ញុំយំគ្រប់ពេលដែលខ្មែរក្រហមបង្គាប់ឲ្យហៅឪពុកខ្ញុំថា "មិត្ត" .............៥៥



គរុសិស្សមកពីសាលាគរុកោសល្យខេត្តបាត់ដំបង ទស្សនកិច្ចសិក្សានៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ យាង សេងហឿន, ម៉ែន ពិចិត្រ, សួស សកល, ប៉ៅ គឹមហុក, រ៉ូនិត អារី, អ៊ុីវ ថាយល័រ **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ទាវ សារៈមុនិន្ទ និង ឆេង វេង **អ្នកបកប្រែ** ៖ លន់ច័ន្ទសុចិត្រា និង អ៊ូច គន្ធា **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** ៖ សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** ៖ សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# វគ្គបណ្តុះបណ្តាលស្តីពីសន្តិភាព និងសិទ្ធិមនុស្ស

*មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមានសេចក្តីសោមនស្សរីករាយប្រកាសបើក «វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍» ដែលមានការចូលរួមពីសំណាក់សិក្ខាកាមចំនួន៣០នាក់នៅស្រុកអន្លង់វែង ។ «វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍» លើកទីមួយនឹងបណ្តុះបណ្តាលសិក្ខាកាមចំនួន១៥នាក់ចាប់ពីថ្ងៃទី២៨ខែសីហា ឆ្នាំ២០១៧ ដល់ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ ។ កម្មវិធីបណ្តុះបណ្តាលរយៈពេល៥ថ្ងៃនេះផ្តោតសំខាន់ទៅលើការបង្រៀន និងការអនុវត្តជំនាញក្នុងការដឹកនាំដំណើរទេសចរណ៍ក្នុងតំបន់ ។ «វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍» ដាក់បញ្ចូលនូវការតាំងពិព័រណ៍ស្តីពីប្រវត្តិសាស្ត្រ និងការវិវត្តរបស់ស្រុកអន្លង់វែង ព្រមទាំងការបង្រៀនអំពីប្រវត្តិសាស្ត្រតំបន់អន្លង់វែង និងប្រវត្តិសាស្ត្រកម្ពុជាទៀតផង ។ ការតាំងពិព័រណ៍អំពីប្រធានបទ «ការកែច្នៃសណ្ឋានដី និងការព្យាបាលរបួសសង្គម» នឹងផ្តល់ជូនសិក្ខាកាមនូវចំណេះដឹងអំពីចលនាខ្មែរក្រហម និងទីតាំងប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងស្រុកអន្លង់វែង ។ ការបង្រៀននៅក្នុង «វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍» ផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចជាចលនាខ្មែរក្រហមក្នុងតំបន់ និងក្នុងប្រទេសកម្ពុជាទាំងមូល (ដែលរួមបញ្ចូលទាំងសារសំខាន់នៃទីតាំងប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែង) របៀបសម្របសម្រួលដំណើរទេសចរណ៍នៅក្នុងតំបន់អន្លង់វែង បច្ចេកទេសនៃការរៀបរាប់សាច់រឿង និងវិធីសាស្ត្រក្នុងការលើកទឹកចិត្តសាធារណជនឲ្យធ្វើការឆ្លុះបញ្ចាំងបែបស៊ីជម្រៅអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។*

*«វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍» មានចក្ខុវិស័យក្នុងការរៀបចំឲ្យមានដំណើរទេសចរណ៍របស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ក្លាយជាអ្នកដឹកនាំដំណើរទេសចរណ៍ ។ ការស្តាប់សាច់រឿងរបស់អតីតកម្មាភិបាលខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជំរុញឲ្យមានការពិភាក្សាដ៏មានឥទ្ធិពលដែលប្រកបដោយខ្លឹមសារអប់រំ និងមានលក្ខណៈហ្មត់ចត់ ។ ការពិភាក្សាបែបនេះជួយលើកកម្ពស់តម្លៃសន្តិភាពតាមរយៈការចងចាំ និងការផ្សះផ្សា ។ គោលដៅរយៈពេលខ្លីរបស់ «វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍» គឺជាការបង្កើនសមត្ថភាពរបស់ប្រជាជនមូលដ្ឋានក្នុងការដឹកនាំដំណើរទេសចរណ៍ ។ ប៉ុន្តែសកម្មភាពនៅក្នុងវគ្គបណ្តុះបណ្តាលនេះក៏បានផ្សារភ្ជាប់ជាមួយនឹងគោលដៅរយៈពេលវែងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក្នុងការបង្កើតការអភិវឌ្ឍយូរអង្វែងដែលមិនប៉ះពាល់ដល់បរិស្ថាន ។*

*«ប្លង់គោលស្រុកអន្លង់វែង» បានរួមបញ្ចូលនូវកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមហ៊ុនរចនាប្លង់ដេវ៉ាកាង និងដៃគូពាក់ព័ន្ធដទៃដើម្បីបង្កើតចក្ខុវិស័យថ្មីមួយសម្រាប់ស្រុកអន្លង់វែងដែលជាតំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម ។ «ប្លង់គោលស្រុកអន្លង់វែង» មានគោលដៅបង្កើតទីក្រុងសន្តិភាពការផ្សះផ្សានិងការបង្កើតជីវិតថ្មីនៅលើទីតាំងនៃអំពើហិង្សា និងការប៉ះទង្គិចផ្លូវចិត្ត ។*

*វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍មិនអាចប្រព្រឹត្តទៅបានទេប្រសិនបើគ្មានការចូលរួមចំណែកដ៏សប្បុរសរបស់ទីភ្នាក់ងារស៊ុីសសម្រាប់កិច្ចសហប្រត្តិបត្តិការ និងអភិវឌ្ឍន៍ដែលជាម្ចាស់ជំនួយគោលរបស់វគ្គបណ្តុះបណ្តាលនេះ ។ វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ក៏មិនអាចរៀបចំឡើងបានដែរប្រសិនបើគ្មានការគាំទ្រពីព្រះមហាក្សត្រីយានីនៃប្រទេសកាណាដា «ព្រះមហាក្សត្រីយានីអេលីហ្សាប៊ែតទី២» និងលោកស្រីគ្រីស៊ីយាហ្វ្រីលេនដែលជាព្រះរាជតំណាងរបស់ព្រះមហាក្សត្រី និងជារដ្ឋមន្ត្រីការបរទេសរបស់ប្រទេសកាណាដាដែលធ្វើអន្តរាគមន៍តាមរយៈក្រសួងការបរទេសពាណិជ្ជកម្ម និងអភិវឌ្ឍន៍ «DFATD» ព្រមទាំងការគាំទ្រគោលរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងមូលនិធិរ៉ូប៊ឺតបស្ស ។ វគ្គបណ្តុះបណ្តាលនេះបានរៀបចំឡើងដោយមានកិច្ចសហការពីអភិបាលខេត្តឧត្តរមានជ័យ និងក្រសួងទេសចរណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ។*

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ចម្លើយសារភាពរបស់ សា វិន ប្រធានក្រសួងឃោសនា និងវប្បធម៌របស់ស្រុកមានជ័យថ្មី តំបន់២៣ ភាគបូព៌ា

***ដកស្រង់ចេញពីឯកសារលេខ D៤១២៨៤***

*សា វិន ជាអ្នកទោសដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ។ មុនចាប់ខ្លួន សា វិន មានតួនាទីជាសមាជិកស្រុកមានជ័យថ្មី តំបន់២៣ ហើយដោយឡែក សា វិន ក៏មានតួនាទីមួយផ្សេងទៀតដែរ គឺជាប្រធានក្រសួងឃោសនា និងវប្បធម៌របស់ស្រុកមានជ័យថ្មី ។ សា វិន មានអាយុ៤៩ឆ្នាំ (គិតត្រឹមឆ្នាំ១៩៧៨) កើតនៅភូមិព្រៃអង្គ្រង ឃុំព្រៃស្វាយ ស្រុករមាសហែក ខេត្តស្វាយរៀង ។ ឪពុកឈ្មោះ ចាន់ វ៉ា (រស់នៅក្នុងសហករណ៍) និងម្តាយឈ្មោះ ផង់ (ស្លាប់) ។ ប្រពន្ធឈ្មោះ ទេព អ៊ួន នៅមន្ទីរឃោសនាការស្រុកមានជ័យថ្មី និងមានកូនចំនួន៩នាក់ ប្រុស៧នាក់ និងស្រីពីរនាក់ ។ សា វិន ត្រូវបានអង្គការចាប់ខ្លួនដោយចោទប្រកាន់ពីការធ្វើសកម្មភាពជាមួយបក្ខពួកប្រឆាំងនឹងបដិវត្តន៍ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ ហើយឯកសារដែលសរសេរដោយដៃមានចំនួន៨៣ទំព័រ ត្រូវបានធ្វើចប់នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៨ ។ តាមរយៈឯកសារនេះបញ្ជាក់ថា សា វិន បានចំណាយពេលអស់ជាងមួយខែក្នុងការឆ្លើយសារភាព ។ យើងមិនដឹងថា ការឆ្លើយសារភាពរបស់ សា វិន ពិតប្រាកដយ៉ាងណានោះទេ ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបដែលបានដកស្រង់ចេញពីចម្លើយសារភាពរបស់ សា វិនៈ*

កាលពីតូច សា វិន រស់នៅជាមួយឪពុកម្តាយធ្វើស្រែចម្ការ និងបានរៀនសូត្រដល់ថ្នាក់ទី១០ នៅសាលាវត្តជ្រៃ លុះពេលមានអាយុ១៩ឆ្នាំ ឪពុកម្តាយក៏បានរៀបការប្រពន្ធឲ្យ ។ ឆ្នាំ១៩៥២ សា វិន បានចូលធ្វើខ្មែរឥស្សរៈ តាមរយៈឈ្មោះ កែវ អាន ជាគណៈកងទ័ពភាគបូព៌ា (សមាជិកតំបន់២៣ក្នុងឆ្នាំ១៩៧០ បច្ចុប្បន្នអង្គការចាប់ហើយ) ។ បន្ទាប់មក ឈ្មោះ សា ផាក បានចាត់ សា វិន ឲ្យធ្វើប្រធានភូមិព្រៃអង្គ្រង និងក្តាប់ឈ្លប១២នាក់ ។ ឆ្នាំ១៩៥៣-៥៤ នៅពេលបារាំងអុកឡុក រាតត្បាតខ្លាំង សា វិន និងបក្ខពួកបានរត់ទៅលាក់ខ្លួននៅភូមិព្រៃស្វាយ និងវត្តគំនុំ ឃុំសម្បត្តិមានជ័យ បន្ទាប់មក បារាំងបានបាញ់ឈ្លបរបស់ សា វិន ស្លាប់អស់ប្រាំបីនាក់ នៅសល់បួននាក់ ។ ពេលរត់គេចខ្លួនទៅនៅភូមិព្រៃស្វាយនោះ សា វិន មានការទាក់ទងជិតស្និទ្ធជាមួយ កែវ អាន (កាលនោះ កែវ អាន ជាគណៈកងទ័ពភាគបូព៌ា) ហើយ កែវ អាន បានអប់រំ សា វិន ឲ្យមានគោលជំហរជឿជាក់លើយួនដោយបាននិយាយថា បដិវត្តន៍កម្ពុជារំលាយបក្សកុម្មុយនីស្តឥណ្ឌូចិន មានបក្សមួយដោយឡែកទៀត ដូច្នេះ យើងកុំភ្លេច ប្រវត្តិដែលធ្វើបដិវត្តន៍ជាមួយយួនកន្លងមក ព្រោះយួនមានគុណច្រើនណាស់ ដែលបានធ្វើជារាមច្បងដឹកនាំវាយបារាំង ដូច្នេះត្រូវចងសាមគ្គីជាមួយយួនតទៅទៀត ព្រោះយួនមានអាវុធសម្បូរបែប ថ្ងៃក្រោយរួមសហការវាយចក្រពត្តិបារាំងឈ្នះ ក៏យើងនៅតែចងសាមគ្គីជាមួយយួនគ្មានងាករេ ព្រោះអនាគត យើងរំដោះប្រទេសកម្ពុជា លាវ យួនខាងត្បូង ហើយរួមប្រទេសទាំងបីឲ្យទៅជាសហព័ន្ធឥណ្ឌូចិន ដែលមានបក្សតែមួយដឹកនាំ គឺបក្សពលកររៀតណាម ។ កែវ អាន បានបន្ថែមថា ពេលនោះនឹងបានសប្បាយ ហើយចំពោះ សា វិន និងបានបុណ្យស័ក្តិមានមុខមានមាត់ធំដំថែមទៀត ។ បន្ទាប់មក កែវ អាន ក៏បានខ្ទេសនាមបញ្ចូល សា វិន ជាបក្សពលកររៀតណាម នៅភូមិត្រពាំងរាំង ឃុំព្រៃស្វាយ មានឈ្មោះ បាការ (គណៈយោធាកងទ័ពឥស្សរៈយួន) ជាអ្នកទទួលស្គាល់ ។ ភារកិច្ចរបស់បក្សពលកររៀតណាមគឺៈ

១) យើងជាបក្សពលកររៀតណាម ត្រូវសហការជាមួយរៀតណាមដាច់ខាត មិនត្រូវឲ្យបដិវត្តន៍អូសទាញគោលជំហរបានដាច់ខាត ទោះមានកម្លាំងបដិវត្តន៍ធំយ៉ាងណាក៏ដោយ ។

២) ពេលមានចលនាបដិវត្តន៍រីកធំធាត់ យើងត្រូវធ្វើឲ្យបែកបាក់ រង្គោះរង្គើផ្ទៃក្នុង កុំឲ្យបដិវត្តន៍រីកចម្រើនបានឆាប់រហ័ស

ដើម្បីអនុវត្តផែនការសហព័ន្ធឥណ្ឌូចិននាពេលខាងមុខ ។

៣) ពង្រីកកម្លាំងក្នុងប្រជាជន ជាបណ្តើរ ដើម្បីត្រៀមទុកសហការជាមួយយួនដណ្តើមរដ្ឋអំណាចពីបដិវត្តន៍ ពេលមានផែនការ ។

៤) ត្រូវឃោសនាប្រជាជនឲ្យមានជំនឿជឿជាក់លើយួនចង់រស់នៅរបៀបយួន ហើយឃោសនាឲ្យមានទំនាស់ជាមួយបដិវត្តន៍ ។

៥) រក្សាការសម្ងាត់យូរអង្វែង ។ រួចហើយ បាការ បាននិយាយជាភាសាយួន ណែនាំបន្ថែមពីភារកិច្ច ដែល កែវ អាន ជាអ្នកបកប្រែ ។ ក្រោយចូលបក្សពលករវៀតណាមរយៈពេលបួនខែមក សង្គ្រាមវាយដេញបារាំងក៏ត្រូវបញ្ចប់ ពេលនោះ កែវ អាន បានណែនាំ សា វិន ឲ្យទាក់ទង សា ផាត ឲ្យជាប់ ហើយបានណែនាំឲ្យខំបំពេញភារកិច្ចបក្សពលករ ។ បន្ទាប់មក កែវ អាន ក៏បានផ្លាស់ទៅកន្លែងផ្សេងទៀត មិនដឹងថាទៅស្រុកណាទេ ។ នៅឆ្នាំ១៩៥៥ សា ផាត ក៏បានណែនាំ សា វិន ឲ្យ ស្គាល់ខ្សែរយៈបក្សពលករវៀតណាមចំនួនប្រាំនាក់មានឈ្មោះ ឃឹម (ស្លាប់ឆ្នាំ១៩៧៣) , យិ (ឆ្នាំ១៩៦៧ ឈឺស្លាប់) , ឈឺន (ស្លាប់ឆ្នាំ១៩៧៦) , ឆឹម (ឆ្នាំ១៩៧១ ឈឺស្លាប់) និង យី (ឆ្នាំ១៩៧៣ ជាប្រធានសហករណ៍ភូមិត្រពាំងធ្លក) ឲ្យខិតខំអូសទាញកម្លាំងក្បត់ និងឃោសនាប្រជាជនឲ្យស្រឡាញ់យួន ។ ក្រោយៗមក សា វិន រួមជាមួយ សា ផាត បានធ្វើការអូសទាញកម្លាំងបានជាហូរហែ ដោយបានបំពាក់គោលជំហរឲ្យប្រឆាំងបដិវត្តន៍កម្ពុជា មិនឲ្យចូលធ្វើបដិវត្តន៍ និងអប់រំឲ្យស្រឡាញ់ពីរបៀបរបបរស់នៅដូចប្រជាជនយួនជាដើម រហូតដល់ឆ្នាំ១៩៧០ ។

ឆ្នាំ១៩៧០ សា វិន និង សំអន បានចាត់កម្លាំងពីរនាក់ដែលជាកម្លាំងចាស់ ឲ្យចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ ។ បន្ទាប់មក សា វិន ក៏បានណែនាំកម្លាំងចាស់ចំនួនប្រាំនាក់ឲ្យ សំអន ចាត់តាំងបញ្ចូលបង្កប់ក្នុងបដិវត្តន៍ ។ លុះដល់ឆ្នាំ១៩៧១ ឈ្មោះ គួន បានចាត់ឲ្យ សា វិន ធ្វើជាប្រធានឃុំម្រាម ក្នុងស្រុករមាសហែក តំបន់២៣ ។ ពេលនោះ សា វិន បានជួបកម្លាំងចាស់ និងបានធ្វើការណែនាំឲ្យធ្វើសកម្មភាពឃោសនាប្រជាជនមិនឲ្យចូលធ្វើបដិវត្តន៍ តាមផែនការដែលបានទទួលពី សា ផាត នៅឆ្នាំ១៩៧០ ដើម្បីដណ្តើមប្រជាជនពីបដិវត្តន៍ កុំឲ្យអង្គការមានកម្លាំងច្រើននៅក្នុងភូមិ កសាងកម្លាំងប្រជាជនឲ្យចូលមកខាងប្រឆាំងបដិវត្តន៍ ហើយចាត់តាំងឲ្យធ្វើសកម្មភាពបន្តទៀត តែត្រូវបេះលាក់ការណ៍សម្ងាត់ ។

ឆ្នាំ១៩៧២ សា ផាត បានហៅគណៈឃុំទាំងអស់ឲ្យទៅប្រជុំនៅមន្ទីរស្រុកក្នុងភូមិដំបូកក្រោល ។ បន្ទាប់មក សា ផាត បានណែនាំពីផែនការរបស់អង្គការឲ្យចាត់តាំងក្រុមប្រវាស់ដៃ ដើម្បីធ្វើការស្រែ ។ ពេលដាក់ផែនការអង្គការហើយ អង្គប្រជុំបានរំសាយបន្ទាប់មក នៅតែបក្ខពួកក្បត់មួយចំនួនប្រជុំបន្តពីផែនការក្បត់ ។ ពេលនោះ សា ផាត បានណែនាំបក្ខពួកឲ្យស្គាល់គ្នា រួមជាកម្លាំងដើម្បីរួមសកម្មភាពតាមផែនការសហព័ន្ធឥណ្ឌូចិន និងត្រូវពង្រីកផែនការចាស់ឆ្នាំ១៩៧១ ពិសេសលើការកសាងកម្លាំង ។ សា ផាត បានប្រាប់ពីសភាពការណ៍កម្លាំង និងខ្សែរយៈដែលជាអ្នកប្រកាន់យកបក្សកុម្មុយនីស្តឥណ្ឌូចិន ដើម្បីប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា ដណ្តើមរដ្ឋអំណាច និងប្រទេសឲ្យទៅជាសហព័ន្ធឥណ្ឌូចិន ។ សា ផាត បានបន្តទៀតថា នៅក្នុងតំបន់២៣នេះក៏មានច្រើន ហើយចាត់តាំងជាកម្មាភិបាលធំៗ លាក់ខ្លួនក្នុងជួរបដិវត្តន៍ជាយូរមកហើយ ។ ពួកនេះ ក៏បានខិតខំពង្រីកកម្លាំងជាបន្តបន្ទាប់ដែរ ហើយទាំងអស់គ្នា ក៏ត្រូវបេះម្ចាស់ការ ពិនិត្យ ស្ទាបស្ទង់ កសាងកម្លាំងឲ្យបានច្រើនដែរ តែប្រយ័ត្នបែកការណ៍ មុននឹងអប់រំនរណាម្នាក់ ត្រូវពិនិត្យឲ្យបានហ្មត់ចត់ (ប្រជុំចប់ក៏បំបែកគ្នា) ។ ក្រោយពេលប្រជុំ សា វិន កសាងកម្លាំងក្បត់បានបីនាក់នៅក្នុងឃុំម្រាមមានឈ្មោះ ទី, មុត និង វ៉ាន់ ។ ក្រៅពីនេះ សា វិន ក៏បានជួបទាក់ទងជាមួយ សំ អន, ឌី សាម៉ៃ, ម៉ុន ហៅ សាមឿន, សំ អួន ហៅ សំអឿន, សារី, សេកអុក និង វិនិច្ឆ័យ ជាញឹកញាប់ទៅតាមរូបភាពផ្សេងៗ ដូចជារកពូជស្រូវឲ្យប្រជាជនដែលចង់បានយកមកធ្វើពូជ និងដើម្បីពង្រឹងជំរុញគ្នាទៅវិញទៅមកពីការកសាងកម្លាំង ដោយឲ្យពិនិត្យពិច័យឲ្យបានច្បាស់លាស់ ដើម្បីកុំឲ្យបែកការណ៍ ។

ឆ្នាំ១៩៧៣ កែវ អាន បានមកប្រជុំនៅមន្ទីរស្រុករមាសហែក ហើយបានប្រកាសចាត់តាំង សាផល ជាលេខាស្រុករមាសហែក, សំ អន ជាអនុលេខាស្រុករមាសហែក និង សា វិន ជាសមាជិកស្រុករមាសហែក ចំណែក សា ផាត ត្រូវបានដកឲ្យធ្វើជាគណៈតំបន់២៣វិញ ។ នៅពេលនោះដែរ កែវ អាន បានណែនាំបន្តថា

ត្រូវនឹងសភាពការណ៍អង្គការចាត់តាំងយើង ជាកម្មាភិបាលស្រុកផង សមមិត្តត្រូវធ្វើជាបង្គោលរឹងមាំក្នុងការអនុវត្តផែនការសហព័ន្ធឥណ្ឌូចិនរបស់យើង ឲ្យបានខ្លាំងក្លា ហើយម្ចាស់ការក្នុងការកសាងកម្លាំងថ្មីឲ្យបានស្អេកស្កះ ហើយម្ចាស់ការក្នុងការប្រជុំសម្ងាត់ ធ្វើយ៉ាងណាកុំឲ្យបែកការណ៍ ។ កែវ អាន បាននិយាយលើកទឹកចិត្តដល់កម្លាំងក្បត់បដិវត្តន៍ថា កម្លាំងយើងមានគ្រប់ស្រុក ដែលសុទ្ធតែជាកម្មាភិបាល ដូចនេះ ថ្ងៃអនាគត យើងអាចឈានទៅម្ចាស់ការកាន់តែខ្ពស់ ហើយក៏ឈានទៅសម្រេចទិសដៅសហព័ន្ធឥណ្ឌូចិនបានជាប្រាកដ ព្រោះយើងមានយួនជារាមច្បងរបស់យើង ជាខ្នងបង្អែកឯបដិវត្តន៍វិញ កម្លាំងតូច ហើយគ្មានអាវុធ សម្ភារសម្បូរបែបដូចយួនទេ ដូចមិត្តឃើញស្រាប់ហើយខ្វះសព្វខ្វះគ្រប់ ដូចនេះហើយមិត្តត្រូវមានជំនឿលើផែនការយើង ហើយខិតខំអនុវត្តតាមការណែនាំពីតំបន់ឲ្យបានហ្មត់ចត់ (ប្រជុំចប់ កែវ អាន បានត្រឡប់ទៅតំបន់២៣វិញ) ។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ សា ផល, សំ អន និង សា វិន បានហៅបក្ខពួកមួយចំនួន រួមនឹងមេឃុំទាំងអស់មកប្រជុំដើម្បីទទួលផែនការចាត់តាំងសហករណ៍តាមទិសរបស់អង្គការ ។ បន្ទាប់ពីចប់ការប្រជុំទៅ អ្នកដែលមិនមែនបក្ខពួកក្បត់បានបំបែកគ្នាអស់ទៅនៅតែបក្ខពួកក្បត់របស់ សា វិន ចំនួន១១នាក់ នៅបន្តការប្រជុំទៀត ដោយពេលនោះ សា ផល បានខ្ទេស្សនាមឲ្យស្គាល់ឈ្មោះ ឈាវ ជាខ្សែរបស់ឈ្មោះ គួន និងបាននិយាយថា ឥឡូវនេះអង្គការបានឲ្យយើងចាត់តាំងសហករណ៍សមូហភាពនៅតាមភូមិឃុំ ដូច្នេះ យើងត្រូវធ្វើការរារាំងខ្លះៗ ចំពោះផែនការនេះ ដើម្បីកុំឲ្យបដិវត្តន៍រីកចម្រើនបានរហ័សពេកគឺ៖

១) ធ្វើយ៉ាងណាឲ្យសហករណ៍កម្រិតទាបដែលចាត់តាំងមុនគេ ឲ្យមានការខ្វះខាតការហូបចុក ស្លៀកពាក់ និងធ្វើឲ្យមានការស្អុកស្អាញដើម្បីឲ្យប្រជាជនមើលឃើញថាមានការលំបាក ហើយចង់រស់នៅជាលក្ខណៈឯកជនតទៅទៀត ។

២) ចាត់តាំងកម្លាំងរបស់យើងនៅតាមភូមិឃុំ បំផុសប្រជាជនឲ្យមានទំនាស់នឹងមាគ៌ា ចាត់តាំងសហករណ៍របស់អង្គការ ដោយលើកថា អង្គការរឹបអូសយកទ្រព្យសម្បត្តិអស់ហើយ ហើយអង្គការមិនដោះស្រាយជីវភាពប្រជាជនឲ្យបានគ្រប់គ្រាន់ទេ បើពីសង្គមចាស់វិញ ដើរខ្ចីគេបាន តែឥឡូវ យើងនៅក្នុងសហករណ៍ ទាល់តែចេះទ្រាំ ខ្វះខាតបន្តិចហើយ ។

៣) ត្រូវចាត់តាំងកម្លាំងតាមភូមិ បំផ្លិចបំផ្លាញស្រូវ និងសម្ភារប្រើប្រាស់ក្នុងសហករណ៍ និងធ្វើឲ្យគោក្របីក្នុងសហករណ៍ស្គម ងាប់ ធ្វើឲ្យសហករណ៍រិចរិល ។ ឆ្លៀតក្នុងឱកាសនោះដែរ សា ផល បានណែនាំឲ្យបក្ខពួកខិតខំកសាងកម្លាំងបន្ថែមទៀត ដើម្បីរួមសកម្មភាពប្រឆាំងបដិវត្តន៍ចំពោះមុខ និងយូរអង្វែងទៅតាមផែនការសហព័ន្ធឥណ្ឌូចិន ។ ក្រោយពីប្រជុំទទួលផែនការមក សា វិន, សំ អន និង ចាន់ ក៏បានចុះអនុវត្តតាមផែនការដែល សា ផល បានដាក់ចុះ ។ ដោយឡែក ការទាក់ទងធ្វើសកម្មភាពតាមផែនការប្រឆាំងបដិវត្តន៍គឺ បានលាក់ទុកចាន ឆ្នាំងបានមួយចំនួនមិនឲ្យប្រជាជនប្រើ ហើយបញ្ជាគោ ក្របី កង់ វិទ្យុ ក៏បានឲ្យប្រជាជនលក់ទៅឲ្យចិន និងយួនអស់មួយចំនួនដែរ ទើបឲ្យចូលសហករណ៍ ។ គោ ក្របីបណ្តោយឲ្យក្មេងតូចៗ ឃ្វាល បានស៊ីស្រូវ ស៊ីដំណាំអស់ច្រើនដែរ ឯបាយហូបខ្វះមុខខ្វះក្រោយ ម្តងដាំតិច ម្តងដាំច្រើន ដើម្បីឲ្យអ្នកហូបក្រោយមានការទំនាស់ជាមួយអ្នកសេដ្ឋកិច្ច ។ នៅពេលនោះដែរ សា វិន និង សំ អន កសាងកម្លាំងក្បត់បានបីនាក់ ។ ក្រោយមក សា វិន បានប្រគល់កម្លាំងដែលកសាងបានទាំងប៉ុន្មានទៅឲ្យ សាផល ក្តាប់ និងដឹកនាំសកម្មភាព ហើយ សា វិន និង ឈៀង ស៊ី ក៏បានទៅស្រុកមានជ័យថ្មី ។ ពេលទៅដល់ភ្លាមក៏បានចូលរួមប្រជុំសន្និបាតស្រុកមានជ័យថ្មីមួយថ្ងៃមួយយប់ ។ ពេលប្រជុំសន្និបាតចប់ឈ្មោះ សូ លេខាតំបន់២៣ បានដឹកនាំ សា វិន និងបក្ខពួកចំនួនដប់ពីរនាក់ប្រជុំនៅមន្ទីរស្រុកមានជ័យថ្មី ស្ថិតនៅក្នុងភូមិកុំព័ទ្ធជ្រូក ឃុំស្វាយយា ។ ពេលនោះ សូ បានប្រកាសចាត់តាំង សា វិន ឲ្យទទួលធ្វើជាសមាជិកស្រុកមានជ័យថ្មីក្តាប់ខាងមុខសញ្ញាប្រធានសន្តិសុខ ដែលមន្ទីរសន្តិសុខស្ថិតនៅភូមិម៉ឺនសាយ ឃុំស្វាយយា និងចាត់តាំង ឈៀង ស៊ី ជាប្រធានក្រសួងឃោសនាការស្រុកមានជ័យថ្មី ដែលមន្ទីរនៅភូមិអង់បុស ឃុំស្វាយយាដែរ ។ សូ បានបន្ថែមថា ចំពោះសមមិត្តដែលចាត់តាំងថ្មីនេះ ត្រូវយល់ថា អ្នកចូលរួមក្នុងអង្គប្រជុំនេះ សុទ្ធតែជាកម្លាំង ជាបង្គោលដ៏រឹងមាំរបស់យើងក្នុងការសម្រេចទិសដៅសម្ព័ន្ធឥណ្ឌូចិន ដែលមានបក្សឥណ្ឌូចិនដឹកនាំ ដូច្នេះតទៅមុខទៀត ត្រូវសហការណ៍គ្នាឲ្យជាប់ក្នុងគោលបំណងតែមួយ ដើម្បីឲ្យប្រទេសក្លាយទៅជាសហព័ន្ធឥណ្ឌូចិន ។ ហេតុនេះ សមមិត្តត្រូវ

ក្តាប់ផែនការពី សាមិត ឲ្យបាន ហើយម្ចាស់ការធ្វើឲ្យបាន កុំឲ្យបែកការណ៍ ពិសេសការពង្រីកកម្លាំងរបស់យើងឲ្យបានស្ទេកស្កុះតទៅទៀត (អង្គប្រជុំចប់ក៏បែកគ្នា) ។

ឆ្នាំ១៩៧៤ សាមិត និង គួន បានហៅ សា វិន, ឈៀង ស៊ី និងបក្ខពួកចំនួនប្រាំបីនាក់ទៀត ចូលរួមប្រជុំ ។ ខ្លឹមសារនៃការប្រជុំនេះ គឺបានណែនាំ សា វិន និង ឈៀង ស៊ី ឲ្យស្គាល់ខ្សែរយៈដែលជាកម្លាំងមួយចំនួនទៀត រួមគ្នាដឹកនាំធ្វើសកម្មភាព ដើម្បីទប់ទល់ចលនាបដិវត្តន៍ និងធ្វើឲ្យរង្គោះរង្គើផ្ទៃក្នុងបដិវត្តន៍ឲ្យខ្លាំងថែមទៀត ហើយត្រៀមខ្លួនរង់ចាំផែនការរបស់ក្រុមក្នុងការដណ្តើមអំណាចពីបដិវត្តន៍ សម្រេចផែនការសម្ព័ន្ធឥណ្ឌូចិន ។ នៅខាងសន្តិសុខបានបួនខែ សា វិន រួមជាមួយ ឈៀង ស៊ី កសាងកម្លាំងបានចំនួនប្រាំនាក់ ។ លុះដល់ពាក់កណ្តាលឆ្នាំ សូ បានប្រកាសនៅក្នុងអង្គប្រជុំដោយបានចាត់តាំង ឈៀង ស៊ី ជាអនុលេខាស្រុកមានជ័យថ្មី ហើយ សា វិន នៅជាសមាជិកដដែលទទួលនាទីខាងឃោសនាការវប្បធម៌ស្រុក និងឈ្មោះ យឹម ជាប្រធានយោធាស្រុកមានជ័យថ្មី ។ ក្រោយពីបានចាត់តាំងហើយ សូ បានណែនាំឲ្យរក្សាការសម្ងាត់ក្នុងការប្រជុំ និងបានណែនាំពីកម្លាំងប្រឆាំងបដិវត្តន៍នៅក្នុងតំបន់២៣ ដោយនិយាយថា បានចាត់តាំងលាក់បំពួនក្នុងជួរបដិវត្តន៍បានភាគច្រើនហើយ ដូច្នេះ តំបន់នេះនឹងក្លាយទៅជាមូលដ្ឋាន ជាបន្អែករបស់យើង ។ រំលងបានពីរថ្ងៃក្រោយពីប្រជុំផែនការវាយខ្លាំងរបស់អង្គការក៏បានមកដល់ ។ បក្ខពួកដែលបានទទួលផែនការពី សាមិត ក៏បានចុះទៅតាមមុខសញ្ញា ចំណែក សា វិន និង ឈៀង ស៊ី បានចុះណែនាំខ្សែរយៈជាប់ ហើយបានទទួលរបាយការណ៍ពីបក្ខពួកក្នុងសមរភូមិវាយខ្លាំងរយៈពេលជាងពីរខែនៅបន្ទាយអូរសំដី ទួលថ្កោក និងស្វាយជ្រុំ ។ របាយការណ៍នោះគឺ៖

◆ ខាងយោធា វាយខ្លាំងមិនស្មើរគ្នា ធ្វើឲ្យបែកការណ៍ពេលចូលកន្ទែងខ្លាំងបណ្តាលឲ្យខ្លាំងបាញ់មុនពលីយុទ្ធជន និងកម្មាភិបាលបដិវត្តន៍ជាបន្តបន្ទាប់ ។

◆ ខាងសេដ្ឋកិច្ច ឈ្មោះ ចិន បានរាយកាណ៍ថា អាហារសម្រាប់ឲ្យកងទ័ពហូប ដាក់តែអំបិល និងប្រហុកជាច្រើនពេល ចំណែក មាន់ ជ្រូក នៅក្នុងសហករណ៍មានច្រើន តែមិនស្មើយកមកធ្វើម្ហូបទេ ។ បើខាងសមរភូមិ ស្នើបាយចំនួន២០០ស្បោង មិនឲ្យគ្រប់តាមសំណើទេ គឺឲ្យតែជាង១០០ស្បោងតែប៉ុណ្ណោះ ។

◆ ខាងពេទ្យ និងអ្នកនាំអ្នករបួស បានរាយការណ៍ថា ប្រើថ្នាំដែលមិនមានគុណភាពដើម្បីសង្គ្រោះអ្នករបួស ធ្វើឲ្យយុទ្ធជនដែលអាចសង្គ្រោះបានពលី១២នាក់ ក្រៅពីអ្នករបួសធ្ងន់ដែលសង្គ្រោះមិនបាន ។ ឯអ្នកសែងអ្នករបួស ទាល់តែដល់ពេលវាយខ្លាំង ទើបរកអង្រឹង រកឈើស្នែង បណ្តាលឲ្យអ្នករបួសស្រាលទៅជាធ្ងន់ដោយខ្សោះឈាម ពលីយុទ្ធជន និងកម្មាភិបាលបដិវត្តន៍ជាបន្តបន្ទាប់ ។

ចុងឆ្នាំ១៩៧៤ និងដើមឆ្នាំ១៩៧៥ សា វិន និង ឈៀង ស៊ី កសាងកម្លាំងបានបួននាក់ ។ ក្រោយពីរំដោះបានទីក្រុងស្វាយរៀង ភ្នាម (ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥) នៅម៉ោង១២យប់ សាមិត បានហៅបក្ខពួកមកប្រជុំក្នុងមន្ទីរស្រុកនៅភូមិកុំព័ទ្ធជ្រូក ឃុំស្វាយយា ។ សាមិត បាននិយាយថា តាមផែនការរបស់ សូ លេខាតំបន់២៣ គឺស្រុកយើងឲ្យលាក់អាវុធឲ្យបានខ្លះ និងគ្រាប់ខ្លះ ដើម្បីទុកត្រៀមបំពាក់ឲ្យកម្លាំងរបស់យើង ពេលមានផែនការវាយបដិវត្តន៍ដណ្តើមរដ្ឋអំណាចទៅថ្ងៃអនាគត ។ ឥឡូវនេះ ខ្លួន (សាមិត) បានឲ្យ យ៉ឹម ដឹកកាំភ្លើង និងគ្រាប់មួយចំនួនតាមឡានយកមកទុកនៅតាមថ្នល់ខាងកើតភូមិកុំព័ទ្ធជ្រូក កាំភ្លើងទាំងនោះរួមមាន អាអ៊ែ១៥ ចំនួន១៩៨ដើម កាំភ្លើង៦០មីលីម៉ែត្រពីរដើម គ្រាប់អាអ៊ែ១៥ ចំនួន២៥ឡាំងដែក គ្រាប់ដាប់នឹងកាសេធជាង១០០កាសេធ និងគ្រាប់៦០មីលីម៉ែត្រចំនួន៦០គ្រាប់ ។ ប្រជុំចប់ សាមិត បានឲ្យ យ៉ឹម, ទូ, សារ៉េត យករទេះមកដឹកកាំភ្លើងទាំងនោះ ទៅលាក់នៅឃ្លាំងយោធាភូមិម៉ឺនសាយទាំងយប់ ហើយអាវុធទាំងនេះ បានឲ្យឈ្មោះ អាង ជាអ្នកទទួលខុសត្រូវ ។

ក្រោយរំដោះភ្នំពេញខែមេសា ឆ្នាំ១៩៧៥ សាមិតបានឲ្យប្រជាជន ដឹកស្រូវចំនួនមួយម៉ឺនថាំងយកទៅឲ្យយួននៅភូមិរបស់ព្រីង ដែលមានឈ្មោះ គឿន ជាអ្នកចាំទទួលយក ។ ខែមិថុនា ក្រោយពីរៀបចំផ្ទះឲ្យប្រជាជនថ្មីដែលជម្លៀសទៅទីនោះរួចរាល់ហើយ សាមិត បានហៅ សា វិន និងបក្ខពួកមួយចំនួនមកប្រជុំ ។ សាមិត បានលើកឡើងថា ផែនការរបស់អង្គការឲ្យរៀបចំសាបស្រូវ ចាំដល់ធ្លាក់ភ្លៀងខ្លាំងស្រូវល្មមដកស្ទូងបាន ហើយឲ្យវាយសម្រុកដកស្ទូងឲ្យអស់លើផ្ទៃដីដែលមាន ដើម្បីដោះស្រាយជីវភាព

ប្រជាជនឲ្យបានឆាប់រហ័ស ។ សាមិត បានបន្តថា ផែនការអង្គការឲ្យសម្រុកខ្លាំង យើងក៏ត្រូវមានទិសប្រឆាំងឲ្យចំណោញមកខាងយើងឲ្យខ្លាំងដែរគឺ ៖

១) ត្រូវបំផ្លាញសំណាបជាគន្លឹះ ក្នុងការធ្វើឲ្យអស់ដី (ដោយចាំភ្លៀងធ្លាក់ខ្លាំង ចាំយើងសម្រុកសាប ដើម្បីឲ្យទឹកភ្លៀងហូរប្រមូលគ្រាប់ស្រូវគរលើគ្នា ខូចសំណាប ។ ធ្វើយ៉ាងនេះ បានបំផ្លាញសំណាបផង បោលដីដែលត្រូវស្ទូង ដែលមិនមានសំណាបគ្រប់គ្រាន់ផង ហើយអាចរក្សាការសម្ងាត់បានផង) ។

២) ការស្ទូង ត្រូវស្ទូងនៅលើដីណាដែលមិនសូវមានជីជាតិមុន បន្ទាប់មកទើបទៅធ្វើនៅលើដីដែលមានជីជាតិ ។ ធ្វើយ៉ាងនេះដើម្បីឲ្យសល់ដីដែលមានជីជាតិ មិនឲ្យស្រូវបានផលច្រើន ។

៣) ទន្ទឹមនឹងសភាពការណ៍ខ្វះខាត បញ្ហាហូប និងស្លៀកពាក់ យើងបន្ថយរបបពីប្រជាជន ឲ្យរឹតតែខ្វះខាត ដើម្បីយើងបំផុសឲ្យប្រជាជនទំនាស់នឹងបដិវត្តន៍មានប្រសិទ្ធភាព ។

៤) បន្តកសាងកម្លាំងឲ្យបានច្រើនថែមទៀត ដើម្បីបន្ទំខ្លួនចូលជ្រៅទៅក្នុងជួរបដិវត្តន៍ ជួរប្រជាជន ធ្វើផែនការយើង បានទាំងចំពោះមុខ និងយូរអង្វែង ។

៥) រក្សាការសម្ងាត់ដាច់ខាត ដើម្បីការពារកម្លាំងរបស់យើង ។

ក្រោយពីដាក់ផែនការហើយ សាមិត បានណែនាំ សា វិន និង ឈៀង ស៊ី ឲ្យចុះជាប់ដើម្បីណែនាំជំរុញសកម្មភាព រក្សាការសម្ងាត់ និងពង្រីកកម្លាំងកម្មាភិបាលឃុំ សហករណ៍ទាញឲ្យមកខាងប្រឆាំងបដិវត្តន៍ ដើម្បីជាកម្លាំងយូរអង្វែង (ពេលប្រជុំចប់ក៏បែកគ្នា) ។ ក្រោយពីបានទទួលផែនការរួចមក សា វិន និងបក្ខពួក បានយកផែនការនោះមកអនុវត្តគឺ នៅភូមិដូងសរ ឈ្មោះ ផាត បានសាបស្រូវកំពុងមានភ្លៀងធ្លាក់ខ្លាំង បណ្តាលឲ្យគ្រាប់ស្រូវរលួយខូចអស់១៥ថ្លាល ហើយបានទុកដីដែលមានជីជាតិល្អនៅក្នុងឃុំជាងម្ភៃហិកតាចោល ។ ការកសាងកម្លាំង គឺកសាងប្រធានសហករណ៍ភូមិបានពីរនាក់ឈ្មោះ យ៉ាប់ និង ម៉ន ។ ផ្នែកខាងសេដ្ឋកិច្ច បានយកអំបិលដាក់ឲ្យត្រូវទឹកភ្លៀងខូចអស់២៥បាវ ខោអាវ និងជ័យភណ្ឌដែលអង្គការបើកឲ្យចែកតាមឃុំ ក៏បានយកទៅលាក់ទុក៦បាវរួមនឹងក្រណាត់ជិត១០០គី ។ ខាងសិប្បកម្ម និងកសិកម្ម បានបំផ្លាញអំបោះ៨០ដុំ ធ្វើកន្ត្រកមិនបានតាមផែនការរបស់អង្គការ ការរកពូជស្រូវល្អៗ និងស្រាវជ្រាវផ្នែកបច្ចេកទេសដាំដុះដំណាំស្រូវ ក៏អត់បានធ្វើ ។ ខាងឃោសនាការ និងវប្បធម៌ មិនបានប្រាប់ឃុំឲ្យធ្វើសាលារៀនទេ គឺឲ្យសិស្សអង្គុយរៀនតាមក្រោមផ្ទះប្រជាជន ឯមនុស្សវ័យកណ្តាល ក៏មិនឲ្យរៀន ដោយនិយាយថា រៀនមិនចេះ មិនបាច់រៀនទេ ។ ផ្នែកយោធាវិញ ទិសអង្គការឲ្យធ្វើស្រែ៣០ហិកតា តែធ្វើបានតែ២៥ហិកតា ដោយបានបំផ្លាញពូជស្រូវអស់២៥ថាំង ហើយបានដើរបំផុសប្រជាជនពីការហូបមិនឆ្អែត ស្លៀកពាក់មិនគ្រប់គ្រាន់ព្រោះអង្គការមិនដោះស្រាយឲ្យ ។ នៅខែធ្នូ ឆ្នាំ១៩៧៥ សាមិត បានហៅបក្ខពួកមកប្រជុំនៅមន្ទីរស្រុកមានជ័យថ្មីនៅភូមិព្រៃដំឡូង ឃុំពោធិ៍រាជ ។ អ្នកចូលរួមប្រជុំមានចំនួន១៩នាក់ ដែលក្នុងនោះក៏មាន សា វិន ដែរ ។ នៅក្នុងពេលប្រជុំ សាមិត បានប្រកាសឲ្យសមាជិកទាំងអស់បានស្គាល់គ្នាជាកម្លាំងដើម្បីរួមសកម្មភាព និងធ្វើការទាក់ទងគ្នាទៅថ្ងៃក្រោយ ។ សាមិត បានបន្តថា យើងត្រូវប្រឆាំងនឹងផែនការរបស់អង្គការ ក្នុងការលើកប្រព័ន្ធភ្លឺស្រែឲ្យបាន៦០ភាគរយក្នុងឆ្នាំ១៩៧៦នេះ ដោយបំបែកកម្លាំងរបស់ប្រជាជននៅតាមមូលដ្ឋាន និងឃុំដើម្បីបង្អាក់ដំណើរការងារនេះមិនសម្រេចតាមផែនការ ។ ចំណែកផែនការធំរបស់យើងជិតមកដល់ហើយ បើតាមខ្លួន (សាមិត) បានទៅចូលរួមប្រជុំនៅតំបន់២៣ ដែលឈ្មោះ សូ បានប្រកាសថា ផែនការផ្ទុះអាវុធវាយបដិវត្តន៍គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ ដោយមានកម្លាំងធំរបស់យោធាភូមិភាគបូព៌ារួមជាមួយនឹងកម្លាំងខាងក្នុងតំបន់ មានទ័ពស្រុក និងតំបន់២៣ របស់យើងចូលរួមដែរ ។ ដូច្នេះ ចំពោះភារកិច្ចរបស់យើងនៅតាមមូលដ្ឋាននេះ ត្រូវម្ចាស់ការខាងស្បៀងគឺត្រូវប្រមូលទុកដាក់ ជាអង្ករ ជាអំបិល និងជ្រូក ។ ខាងសន្តិសុខ និងយោធា ក៏ត្រូវត្រៀមចាំទទួលកងទ័ពតំបន់ និងកងទ័ពភាគមកដល់ យើងចូលរួមវាយបដិវត្តន៍ជាមួយគ្នា ។ ទិសដៅវាយរបស់យើង គឺសំដៅវាយរំដោះតំបន់២៣ និងឈានទៅវាយរំដោះតំបន់២៤ ដើម្បីយកតំបន់នេះធ្វើជាមូលដ្ឋានបង្អែករឹងមាំរបស់យើង ហើយទិសដៅសំខាន់មួយទៀត គឺវាយយកទីក្រុងភ្នំពេញទៀត ដើម្បីបំបាត់ក្បាលម៉ាស៊ីនដឹកនាំរបស់បដិវត្តន៍ ។ នៅពេលដាក់ផែនការចប់ សាមិត បានធ្វើការណែនាំសមាជិក ឲ្យរក្សា

ការសម្ងាត់ដាច់ខាត ហើយក៏បំបែកគ្នាទៅតាមកន្លែងរៀងៗខ្លួន។ បន្ទាប់ពីបានទទួលផែនការហើយ សា វិន និងបក្ខពួកទាំងអស់នៅគ្រប់ឃុំទាំង៩ បានរួមជាកម្លាំងកិនស្រូវបានអង្ករចំនួន៦០០បាវ និងត្រៀមជ្រូក មាន់ ជាចំហបានមួយចំនួន ចំណែកខាងសេដ្ឋកិច្ចបានត្រៀមអង្ករបាន២០០បាវ អំបិល១០គោន សម្រាប់ផ្គត់ផ្គង់ដល់កងទ័ពពេលផ្ទុះអាវុធ។ ឯសកម្មភាពផ្សេងទៀត គឺបានដកកម្លាំងប្រជាជនខ្លះមិនឲ្យទៅលើកភ្លឺស្រែទេ គឺឲ្យទៅដាំបន្លែវិញ បណ្តាលឲ្យផែនការរបស់អង្គការបានសម្រេចតែ៥០ភាគរយប៉ុណ្ណោះ។ ម្យ៉ាងទៀត បានដករបបពីប្រជាជន ហើយបំផុសថា ធ្វើការទាំងយប់ទាំងថ្ងៃ ខំស្ទើរស្លាប់ នៅតែហូបបបរ បើពីសង្គមចាស់វិញ បើខំយ៉ាងនេះ ច្បាស់ជាមានផ្ទះថ្មនៅហើយ។ មួយទៀត បានធ្វើការបំផុសបញ្ហាសីលធម៌ ដោយនិយាយផ្គួផ្គងរបៀបលេងសើច ហើយឲ្យនារី និងយុវជនដេកក្នុងជំរំជាមួយគ្នា បណ្តាលឲ្យកើតមានបញ្ហាសីលធម៌ជាច្រើន ហើយខាងសន្តិសុខក៏ឆ្លៀតឱកាសធ្វើសកម្មភាព មកចាប់មនុស្សកណ្តាលចំណោម ធ្វើឲ្យខូចនយោបាយរបស់អង្គការផង និងធ្វើស្របតាមច្បាប់ផង។

ខែមេសា ឆ្នាំ១៩៧៦ នៅពេលដែល សាមិត មកពីប្រជុំនៅតំបន់វិញ បាននិយាយប្រាប់សមាជិកខ្លួនថា ផែនការវាយបដិវត្តន៍ត្រូវបែកការណ៍ហើយ អង្គការបានចាប់កម្លាំងដឹកនាំរបស់យើងអស់មួយចំនួន ហេតុនេះ ត្រូវប្រញាប់ប្រាប់បក្ខពួកយើងឲ្យបានដឹងគ្រប់ៗគ្នាជាបន្ទាន់ ហើយឲ្យរក្សាការសម្ងាត់ឲ្យបាន រង់ចាំពេលមានផែនការពីតំបន់យ៉ាងណាៗនោះ ចាំយើងអនុវត្តតាមផែនការនោះទៀត។ ក្រោយពីទទួលបានដំណឹងនេះហើយ សា វិន បានចុះធ្វើការណែនាំដល់កម្លាំងរបស់ខ្លួនទាំងអស់ឲ្យបានដឹង ហើយឲ្យជួយលាក់ការណ៍សម្ងាត់ផង។ បន្ទាប់ពីផែនការវាយបដិវត្តន៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ ត្រូវបរាជ័យមក សាមិត បានប្រជុំបក្ខពួករបស់ខ្លួនម្តងទៀត ដើម្បីរៀបចំផែនការវាយបដិវត្តន៍សាឡើងវិញនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦។ សាមិត បានបន្តថា ផែនការវាយបដិវត្តន៍របស់យើងត្រូវបានរៀបចំឡើងវិញ គឺនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ នេះ។ យើងមានកងទ័ពតំបន់ និងបានទាក់ទងជាមួយកងទ័ពវៀតណាម ឲ្យវាយចូលតាមមុខសញ្ញាពីស្រុកប្រសូត្រ ស្រុកចន្ទ្រា និងស្រុកកំពង់រោទិ៍ ដើម្បីរំដោះតំបន់២៣ ធ្វើជាមូលដ្ឋានបង្អែករបស់យើង ដើម្បីឈានទៅវាយកន្លែងផ្សេងទៀត។ ចំពោះភារកិច្ចរបស់យើងនៅតាមឃុំនីមួយៗ ត្រូវម្ចាស់ការរៀបចំឡើងវិញ ទាំងស្បៀង ទាំងផ្នែកដឹកជញ្ជូនសម្ភារ ដើម្បីឧបត្ថម្ភដល់កងទ័ពរបស់យើង។ ខាងពេទ្យត្រូវលាក់ថ្នាំល្អៗឲ្យបានច្រើន ទុកព្យាបាលដល់កងទ័ពយើងពេលមានរបួស (ប្រជុំចប់ក៏បែកគ្នា)។ ក្រោយពេលត្រឡប់មកពីប្រជុំនៅតំបន់វិញ សាមិត បាននិយាយប្រាប់ សា វិន, ឈៀង ស៊ី, ដល្លី, សែម, ចឺន និងសមាជិកផ្សេងៗទៀតថា ផែនការវាយបដិវត្តន៍ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ត្រូវបែកការហើយ ព្រោះអង្គការកំពុងតាមចាប់ខ្លួនកម្មាភិបាលក្បត់មួយចំនួន។ ហេតុនេះ ត្រូវចុះណែនាំកម្លាំងរបស់ខ្លួនរៀងៗខ្លួនជាបន្ទាន់ ឲ្យរក្សាការសម្ងាត់ ហើយឲ្យចែកអង្ករ អំបិល ទៅតាមសហករណ៍ឲ្យអស់ និងចាំទទួលផែនការពីតំបន់២៣ ដើម្បីអនុវត្តជាបន្តទៀត។ ក្រោយពីទទួលបានការណែនាំពី សាមិត ហើយ សា វិន និង ឈៀង ស៊ី បានចុះធ្វើការណែនាំកម្លាំងរបស់ខ្លួននៅតាមឃុំ ដូចការណែនាំរបស់ សាមិត ខាងលើ។

ខែមករា ឆ្នាំ១៩៧៧ ក្រោយពេលត្រឡប់មកពីប្រជុំនៅតំបន់២៣វិញ ឈៀង ស៊ី បានពិភាក្សាជាមួយ សា វិន និង ដល្លី នៅមន្ទីរស្រុកមានជ័យថ្មី តាមផែនការរបស់ សូ គឺចាត់ឲ្យលាក់ស្រូវ និងថ្នាំពេទ្យទុកបណ្តើរៗ ព្រោះផែនការវាយបដិវត្តន៍មានជានិច្ចមិនចេះចប់ទេ ដូច្នេះស្រូវដែលធ្វើបានត្រូវជូនទៅអង្គការមួយចំនួន ហើយយើងទុកមួយចំនួនតាមសភាពជាក់ស្តែងតាមឃុំមួយៗ។ ខែកុម្ភៈ អង្គការបានចាប់ខ្លួនឈ្មោះ យ៉ឹម ប្រធានសន្តិសុខស្រុកមានជ័យថ្មី។ ពេលនោះ ឈៀង ស៊ី បានមកពិភាក្សាជាមួយ សា វិន និង ដល្លី ដោយបានសម្រេចចាត់តាំងឈ្មោះ អោ ឲ្យមកធ្វើជាប្រធានសន្តិសុខស្រុកបន្តពី យ៉ឹម និងបានណែនាំ អោ ឲ្យអនុវត្តផែនការលាក់ស្រូវទុក ដើម្បីត្រៀមអនុវត្តផែនការធ្វើរដ្ឋប្រហារនៅពេលខាងមុខ។ ខែមីនា ក្រោយពីប្រមូលទុកដាក់ផលស្រូវរួចមក សា វិន និង ឈៀង ស៊ី បានដើរពិនិត្យការលាក់ទុកស្រូវនៅតាមឃុំមួយៗ ជាលទ្ធផលសរុប រួមគ្នាលាក់ស្រូវបានចំនួន៧០០០ថាំង ខាងសេដ្ឋកិច្ចលាក់បាន១០០០ថាំង អំបិល៥គោន ក្រណាត់កាគីពណ៌ ស-ខៀវ មួយម៉ឺនម៉ែត្រ។ ចំណែក អោ លាក់

ស្រូវបាន១០០០ថាំង ហើយ ផល្លី លាក់ថ្នាំអំពូលបានប្អូនឡាំង រួមនឹងថ្នាំគ្រាប់-ថ្នាំដបទឹកបានជាច្រើនទៀត ។ បន្ទាប់មក សា វិន, ឈៀង ស៊ី និង ផល្លី បានណែនាំឲ្យបក្ខពួកទាំងអស់ឲ្យរក្សាការសម្ងាត់ និងបានឯកភាពគ្នា មិនដឹកអាងឲ្យគ្រប់តាមផែនការរបស់អង្គការដែលបានដាក់ទិសឲ្យដឹកអាងទឹកឲ្យបានបីនៅក្នុងឆ្នាំ១៩៧៧ នេះជាលទ្ធផល យើងបានដឹកអាងទឹកជូនអង្គការបានតែពីរប៉ុណ្ណោះ ។

ខែកក្កដា ឆ្នាំ១៩៧៧ សយ, ឈៀង ស៊ី, សា វិន និង ផល្លី បានពិភាក្សាគ្នាដើម្បីចាត់តាំងកម្មាភិបាលពាណិជ្ជកម្មថ្មី ព្រោះកម្មាភិបាលមុនត្រូវបានឈ្មោះ សយ ដកយកទៅក្រសួងឃោសនាការហើយ ។ ការពិភាក្សាបានសម្រេចចាត់តាំងឈ្មោះ សាផន ហៅគ្រុយ ឲ្យធ្វើជាប្រធានពាណិជ្ជកម្មស្រុកមានជ័យថ្មីនិងឈ្មោះ សេង ធ្វើជាអនុប្រធានពាណិជ្ជកម្មស្រុកមានជ័យថ្មី (អ្នកទាំងពីរត្រូវបានអប់រំឲ្យចូលក្នុងកម្លាំងក្បត់) ។ បន្ទាប់មក បានដាក់ផែនឲ្យអ្នកទាំងពីរអនុវត្តគឺៈ

១) ការចែកចាយសម្ភារផ្សេងៗ មានប្រហុក និងក្រណាត់ ដែលអង្គការផ្ដល់ឲ្យប្រជាជន ត្រូវទុកឲ្យយូរ ដើម្បីឲ្យប្រជាជនមានការថ្នាំងថ្នាក់ជាមួយអង្គការ ។

២) អង្ករ ក្រណាត់ អំបិល ក៏ត្រូវលាក់ទុកខ្លះ ដើម្បីត្រៀមផែនការវាយបដិវត្តន៍ ត្រូវត្រៀមជាបណ្ដើរៗចាប់ពីពេលនេះទៅ ។ អ្នកទាំងពីរក៏បានយកផែនការនេះទៅអនុវត្តជាបន្តបន្ទាប់ដែរ ហើយនៅឆ្នាំ១៩៧៧ សា វិន និង ឈៀង ស៊ី បានជ្រើសរើសកងទ័ពនារី៣០០នាក់ និងកងទ័ពយុវជន៣០០នាក់ ។

ខែមករា ឆ្នាំ១៩៧៨ ក្រោយពីយួនចេញអស់ពីទឹកដីកម្ពុជា សយ បានទៅប្រជុំនៅតំបន់២៣ ម្ដងទៀត ។ ពេលត្រឡប់មកវិញ សយ បានហៅបក្ខពួកចំនួន១៩នាក់ប្រជុំនៅមន្ទីរ ។ ពេលនោះ សយ បាននិយាយថា ផែនការរបស់យើងចាប់ពីខែតុលា-ធ្នូ ឆ្នាំ១៩៧៧ ត្រូវបរាជ័យ ដោយកម្មាភិបាលមួយចំនួនជាប់រវល់ទៅរៀនសូត្រ បណ្ដាលឲ្យកងទ័ពយើងតាមមុខសញ្ញានីមួយៗ មានការប្របូកប្របល់ ក្ដាប់មុខសញ្ញារបស់ខ្លួនមិនជាប់ ។ បញ្ហាសំខាន់មួយទៀត ដោយមានកងទ័ពអង្គការចូលមកវាយកងទ័ពធំយើង ។ ដូច្នេះ តទៅទៀត យើងត្រូវមានផែនការវាយកងទ័ព អង្គការនៅតាមព្រំដែនជាបណ្ដើរៗ ហើយឈានទៅរកវិធីវាយកម្មាភិបាលធំៗ ដែលដឹកនាំកងទ័ពអង្គការប្រចាំការតាមព្រំដែនធ្វើឲ្យប្របូកប្របល់ជាបណ្ដើរៗ ។ ផែនការរបស់យើង គឺវាយកាត់ផ្ដាច់យកតំបន់២៣-២៤ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ នេះឲ្យបាន ។ យើងបានទាក់ទងទ័ពវៀតណាមឲ្យវាយពីក្រោមកមុន ពេលកងទ័ពអង្គការជាប់តទល់ជាមួយទ័ពវៀតណាម យើងវាយផ្ទប់ពីក្រោយ ហើយត្រូវកាត់ផ្ដាច់ផ្លូវដឹកជញ្ជូនរបស់អង្គការ ដើម្បីកុំឲ្យអង្គការដឹកអាវុធ និងទ័ពមកជួយទាន់ពេល ។ ភារកិច្ចយើងនៅក្នុងស្រុកផ្នែកយោធាត្រូវសហការជាមួយយោធាតំបន់ឲ្យជាប់ ព្រោះ សូនឹងចែកអាវុធមួយចំនួនមកកងទ័ពយុវជន និងទ័ពនារីឲ្យចូលរួមវាយបដិវត្តន៍ជាមួយកម្លាំងធំរបស់យើង ។ ម៉្យាងទៀត តាមឃុំមួយៗ ក៏ត្រូវមានអាវុធបំពាក់ឲ្យឈ្លប ដល់ពេលផ្ទុះអាវុធខ្លាំង បើមានកម្មាភិបាល ឬទ័ពរបស់អង្គការមកបោះនៅក្នុងឃុំណា ឃុំនោះត្រូវចាត់កម្លាំងវាយ ។ ចំពោះប្រជាជន និងកម្មាភិបាលមួយចំនួននៅក្នុងឃុំ ពេលផ្ទុះអាវុធ បើមិនព្រមចុះចូលជាមួយយើង គឺត្រូវកម្ទេចចោល (ប្រជុំចប់ក៏បំបែកគ្នា) ។

បីថ្ងៃក្រោយបន្ទាប់ពីប្រជុំមក ខាងយោធាភ័ស្តុភាតំបន់២៣ បានយកអាវុធ អាអ៊ែរ១៥ សេកាសេ និងកាំប៊ីន ចំនួន៣០០ដើម មកប្រគល់ឲ្យ សយ នៅមន្ទីរសេដ្ឋកិច្ចស្រុក ។ បន្ទាប់មក សយ បានចាត់ សា វិន ឲ្យទៅវាស់វែងដីព្រែកដីក៦មករា ឯភារកិច្ចគឺប្រមូលកងទ័ព និងបំពាក់អាវុធ ។ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ១៩៧៨ អង្គការបានចាប់ខ្លួន ឈៀង ស៊ី ។ លុះប្រាំបួនថ្ងៃក្រោយមក អង្គការបានឲ្យប្រមូលកាំភ្លើងក្នុងស្រុក យកទៅប្រគល់ឲ្យខាងតំបន់វិញ ។

ពេលនោះ សយ បានយកកាំភ្លើងដែលនៅសល់៧៧ ដើម យកទៅទុកនៅមន្ទីរស្រុកមានជ័យថ្មីសិន ចាំប្រមូលអស់ទើបយកទៅប្រគល់ឲ្យតំបន់ ។ មួយថ្ងៃក្រោយពីប្រមូលអាវុធប្រគល់ឲ្យទៅតំបន់គឺនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ អង្គការបានចាប់ខ្លួន សយ ។ ចំណែក សា វិន បានប្រមូលកាំភ្លើងពីកងទ័ពនារីស្រុកបានចំនួន៥៧ដើម យកទៅទុកនៅមន្ទីរសេដ្ឋកិច្ចស្រុកសិនរង់ចាំប្រមូលពីស្រុកអស់សិន ទើបប្រគល់ទៅឲ្យតំបន់ តែត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ តែម្ដងទៅ ។

**ឆេង ម៉េង**

# ដំណឹងយុវជន-យុវនារីបដិវត្តន៍

***ដកស្រង់ចេញពីឯកសារយុវជន និងយុវនារីបដិវត្តន៍លេខពិសេស ខែកញ្ញា ឆ្នាំ១៩៧៧ D២១៤០៣***

***១) យុវជន-យុវនារីភូមិភាគឦសាន ប្ដេជ្ញាវាយសម្រុក បង្កើនផលស្រូវឲ្យបាន៣តោន និង ៦តោន និងដំណាំគ្រប់ប្រភេទឲ្យបានផលច្រើនជាអតិបរមាដាច់ខាត***

*ក្នុងសម័យតស៊ូនយោបាយសម្ងាត់ និងសម័យតស៊ូប្រឆាំងនឹងសង្គ្រាមផ្ទៃក្នុង ប្រតិកិរិយា ក៏ដូចក្នុងសម័យសង្គ្រាមបដិវត្តន៍ប្រឆាំងនឹងសង្គ្រាមឈ្លានពានមហាវិនាសកម្មរបស់ចក្រពត្តិអាមេរិក បរិវារ ជាងប្រាំឆ្នាំកន្លងទៅនេះដែរ យុវជន-យុវនារីយើងនៅភូមិភាគឦសានទាំងមូល ក៏ដូចនៅទូទាំងប្រទេស បានលះបង់អ្វីៗទាំងអស់ ចូលរួមប្រយុទ្ធវាយកម្ទេចចក្រពត្តិសក្តិភូមិ នាយទុនប្រតិកិរិយា និងខ្មាំងសត្រូវឈ្លានពាន លេបទឹកដីគ្រប់ប្រភេទ ឲ្យវាបរាជ័យជាបន្តបន្ទាប់ រហូតលុះត្រាវាបរាជ័យរលំរលាយអស់ទាំងស្រុង និងជាស្ថាពរពីទឹកដីកម្ពុជាយើង នៅថ្ងៃ១៧ មេសា ១៩៧៥ ។*

*ក្នុងសម័យការពារប្រទេស បន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមបច្ចុប្បន្ននេះ យុវជន-យុវនារីយើងនៅភូមិភាគឦសាន បានបន្តប្រពៃណីប្រយុទ្ធលះបង់នេះ កាន់តែក្រហមឆ្អិនឆ្អៅឡើង ដើម្បីវាយសម្រុកសម្រេចភារកិច្ចថ្មីនេះ ឲ្យបានជោគជ័យដាច់ខាត ។ ក្នុងរយៈពេលជាងពីរឆ្នាំកន្លងទៅ បងប្អូនបានពង្រឹងពង្រីកនូវគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ ឲ្យរីកចម្រើនរឹងប៉ឹងខ្លាំងក្លាឡើងជាលំដាប់ ។ ពិសេសបងប្អូន បានពង្រឹងពង្រីកនូវគោលជំហរធ្វើជាម្ចាស់ប្រទេស ម្ចាស់*



*សមាជិកនៅកងចល័តកំពុងចាំងសម្អាតស្មៅ*

បដិវត្តន៍ ម្ចាស់លើជោគវាសនាប្រទេសជាតិខ្លួន ដោយខ្លួនឯងពេញទី ហើយរួមគ្នាប្រយុទ្ធបំពេញភារកិច្ចគ្រប់ផ្នែក ទាំងយប់ទាំងថ្ងៃឥតមានគិតពីការនឿយហត់ផ្ទាល់ខ្លួនឡើយ ។ដូច្នេះហើយ បានជានៅគ្រប់មុខព្រួញភារកិច្ចប្រចាំថ្ងៃ នៅក្នុងភូមិភាគទាំងមូល សកម្មភាពវាយសម្រុករបស់យុវជន-យុវនារីយើង មានសន្ទុះផុលផុស ខ្លាំងក្លាសន្ធោរសន្ធៅណាស់ ។ នៅឆ្នាំ១៩៧៧នេះ បងប្អូនបានយល់ជ្រួតជ្រាបយ៉ាងច្បាស់លាស់ អំពីភារកិច្ចបង្កើនផលស្រូវឲ្យបានបីតោន និងប្រាំមួយតោនរបស់បក្សគ្រប់ពេលវេលា ។ បងប្អូនមានទស្សនៈ គោលជំហរ យ៉ាងច្បាស់លាស់ថា ផលស្រូវបីតោន និងប្រាំមួយតោននេះ ពិតជាទិសដៅមួយដ៏ត្រឹមត្រូវមហាអស្ចារ្យណាស់ ក្នុងកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម ការពារប្រទេស និងកសាងសង្គមនិយមនៅកម្ពុជាយើង ឲ្យកាន់តែខ្លាំងក្លា តាមមាគ៌ាឯករាជ្យម្ចាស់ការរបស់បក្ស ។ ផលស្រូវបីតោន និងប្រាំមួយតោននេះ ពិតជានឹងប្រែក្លាយមុខមាត់មាតុភូមិកម្ពុជាយើង ឲ្យកាន់តែប្រែប្រួលថ្មីសន្ធាងថែមទៀត ធ្វើឲ្យជីវភាពប្រជាជនយើង យុវជន-យុវនារីយើង ឈានទៅសម្បូរធូរធា មានសម្ថភាពបរិបូណ៌ ក្នុងកិច្ចការពារកសាងប្រទេសយើងដោយឯករាជ្យម្ចាស់ការគ្រប់ពេលវេលា ។

ដោយមានទស្សនៈ គោលជំហរយ៉ាងច្បាស់លាស់យ៉ាងនេះហើយ បានជាបច្ចុប្បន្ននេះ នៅលើការដ្ឋានស្រែវស្សាគ្រប់ទីកន្លែងនៃភូមិភាគឦសានទាំងមូល យុវជន-យុវនារីយើង បានវាយសម្រុកភ្ជួររាស់ ដកស្ទូង ទាំងនៅលើដីធ្វើពីរដង ទាំងនៅលើដីធ្វើម្តងដោយស្មារតីប្រយុទ្ធធ្វើការងារ យ៉ាងខ្លាំងក្លាសន្ធោរសន្ធៅ ទាំងយប់ទាំងថ្ងៃ មិនខ្លាចឧបសគ្គធម្មជាតិ ក្តៅរងាររភ្លៀងផ្គរអ្វីទាំងអស់ ។ បងប្អូនប្រយុទ្ធធ្វើការងារ ក្នុងបរិយាកាសវាយសម្រុកខ្លាំងក្លា ស្វាហាប់ ស្មើដៃគ្នា និងដោយសុទិដ្ឋិនិយមជាប់ជានិច្ច ហើយជឿជាក់ថាពិតជានឹងសម្រេចជ័យជម្នះលើសមរភូមិបង្កបង្កើនផល តាមទិសរបស់បក្សពិតប្រាដក ។ ព្រោះនៅក្នុងឆ្នាំនេះ បងប្អូនបានត្រៀមលក្ខណៈសម្បត្តិគ្រប់បែបយ៉ាង ទាំងឧបករណ៍ ទាំងពូជ ជី ថ្នាំកសិកម្មបានច្រើនជាងពីឆ្នាំមុន ។ ឯខាងបច្ចេកទេសធ្វើស្រែទៀត ក៏បងប្អូនបានប្រយុទ្ធឈ្មុសឈ្មុលរៀនសូត្រពិសោធ ដកពិសោធ កែលម្អលើការងារតាមមុខព្រួញនីមួយៗ យ៉ាងទៀងទាត់ ហ្មត់ចត់ជាប់ជានិច្ចដែរ ។ ដោយសារតែកម្លាំងយុវជន-យុវនារីបានដើរតួសំខាន់លើគ្រប់មុខព្រួញបង្កបង្កើននេះ យ៉ាងខ្លាំងក្លា បច្ចុប្បន្ននេះ បងប្អូនបានសម្រេចផែនការធ្វើស្រែនៅលើដីស្រែធ្វើម្តង និងធ្វើពីរដង បានរាប់ពាន់រាប់ម៉ឺនហិកតាហើយ ។ ស្រែដែលស្ទូងរួចហើយ បងប្អូនបានចាត់តាំងកម្លាំងឲ្យប្រយុទ្ធថែទាំ បញ្ចេញបញ្ចូលទឹក បោចស្មៅបាចជី និងបាញ់ថ្នាំការពារស្រូវឲ្យដុះលូតលាស់ល្អ ជាប់ជានិច្ច ។ នៅតាមកន្លែងស្រែនីមួយៗ បងប្អូនបានធ្វើជាយុងរបងការពារស្រូវកុំឲ្យសត្វព្រៃចូលស៊ី និងរកគ្រប់វិធីកម្ចាត់សត្វកណ្តុរ និងសត្វផ្សេងៗទៀត ជាបន្តបន្ទាប់ដើម្បីការពារផលស្រូវឆ្នាំនេះ ឲ្យបានគង់វង្សតាំងពីពេលនេះទៅ ។

ក្រៅពីកម្លាំងធំវាយសម្រុកធ្វើស្រែ កម្លាំងមួយចំនួនទៀតក៏បានវាយសម្រុកដាំដំឡូងឈើ ដំឡូងជ្វា ដំណាំស្បៀងរួមផ្សំ និងបន្លែបង្ការសព្វមុខ នៅគ្រប់ទីកន្លែងដែរ ។ ដំណាំស្បៀងរួមផ្សំទាំងនេះមាន ពេក ពោត សណ្តែកបាយ សណ្តែកសៀង ។ល ។ ឯបន្លែបង្ការសព្វមុខ ដូចជាត្រឡាច សណ្តែកកួ ននោង ត្រប់ ត្រសក់ ត្រកួន ពពាយ ជាដើម ក៏បងប្អូនដាំនៅគ្រប់ទីកន្លែង តាមស្រុកភូមិ តាមចម្ការ តាមខ្ពង់រាប ទាំងអស់ ។ បងប្អូនយកចិត្តទុកដាក់ដាំដំណាំទាំងនេះ ជារង ជាជួរ បានរាប់រយហិកតា ។ បងប្អូនខិតខំដាំពង្រីកវាផង និងយកចិត្តទុកដាក់ថែទាំឲ្យវាដុះ លូតលាស់ល្អជាប់ជានិច្ចផងដើម្បីឲ្យបានផលច្រើន សម្រាប់លើកស្ទួយជីវភាពបងប្អូន និងរួមចំណែកការពារ កសាងប្រទេសឲ្យរឹងប៉ឹងខ្លាំងក្លា និងរីកចម្រើនថែមទៀត ។ បច្ចុប្បន្ននេះ ដំណាំញើសដែលបងប្អូនបានបង្ហូរក្នុងការប្រយុទ្ធបង្កបង្កើនផលនេះ បានចេញជាការជាក់ស្តែង ជាបន្តបន្ទាប់ហើយ ។ ទាំងដំណាំស្រូវ ទាំងដំណាំស្បៀងរួមផ្សំ ទាំងបន្លែបង្ការសព្វមុខ កំពុងតែហុចផល ផ្លែផ្កា ដើម ស្លឹក មើម និងកំពុងដុះលូតលាស់ល្អជាទូទៅ ។ យុវជន-យុវនារីភូមិភាគឦសានទាំងមូល មានជំនឿជឿជាក់ថា ផលស្រូវពិតជាហុចផលល្អ ឈានទៅសម្រេចទិសបង្កើនផលស្រូវ របស់បក្សបានជាដាច់ខាត ។ ឯដំណាំខ្លះទៀត ក៏ពិតជានឹងបានផលច្រើន យ៉ាងពិតប្រាកដដែរ ។ ព្រោះឆ្នាំនេះ បើប្រៀបធៀបទៅនឹងឆ្នាំទៅ គឺបងប្អូនបានធ្វើស្រែ និងដាំដំណាំបានច្រើនលើសពីឆ្នាំមុនឆ្ងាយណាស់ ។ លទ្ធផលទាំងអស់នេះ គឺពិតជាបានមកដោយសារកម្លាំងសមូហភាពដ៏ខ្លាំងក្លារឹងប៉ឹង របស់យុវជន-យុវនារីយើង ដែលបានប្រយុទ្ធពុះពារគ្រប់ឧបសគ្គ ទាំងយប់ទាំងថ្ងៃ មិន

ខ្លាចការនឿយហត់ លំបាកវេទនាអ្វីទាំងអស់ ដើម្បីវាយសម្រុកបង្កើនផលឆ្នាំនេះ ឈានទៅសម្រេចផែនការរបស់បក្ស ឲ្យបានជោគជ័យទាំងស្រុង ។

ដោយធ្លាប់ឆ្លងកាត់ការប្រយុទ្ធយ៉ាងតឹងតែង បត់បែនស្លាប់រស់ ទាំងជាមួយខ្មាំងសត្រូវគ្រប់ប្រភេទ ទាំងជាមួយធម្មជាតិក្នុងគ្រប់កាលសម័យតស៊ូបដិវត្តន៍យុវជន-យុវនារី ភូមិភាគឦសានប្តេជ្ញាបន្តពង្រឹងពង្រីកថែម នូវគោលជំហរម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ ម្ចាស់លើជោគវាសនាប្រទេសជាតិខ្លួន ឲ្យកាន់តែក្រហមឆ្អិនឆ្អៅឡើងជាលំដាប់ ដើម្បីបន្តវាយសម្រុកបង្កើនផលស្រូវ ឲ្យបានបីតោន និងប្រាំមួយតោនដាច់ខាត ។ ព្រមជាមួយនេះ បងប្អូនប្តេជ្ញាវាយសម្រុកដាំដំណាំគ្រប់ប្រភេទ ឲ្យបានផលច្រើន សម្រាប់កែប្រែជីវភាពប្រជាជន យុវជន-យុវនារីយើង ឲ្យកាន់តែសម្បូរធូរធាឡើងជាលំដាប់ ។ បងប្អូនប្តេជ្ញា វាយសម្រុកសម្រេចភារកិច្ចបង្កបង្កើនផល នៅឆ្នាំ១៩៧៧នេះ ឲ្យបានសម្រេចតាមផែនការមួយរយភាគរយ និងលើសពីមួយរយភាគរយថែមទៀតដាច់ខាត ។

## ២) គោលជំហរប្រយុទ្ធស្រួចស្រាវបំផុត របស់យុវជន-យុវនារីកងចល័ត ស្រុកថ្មពួក

កាលនៅក្នុងសម័យសង្គ្រាមបដិវត្តន៍ជាងប្រាំឆ្នាំកន្លងទៅ យុវជន-យុវនារីកម្ពុជាយើង ជាកម្លាំងស្រួចក្នុងការប្រយុទ្ធវាយបណ្តេញ និងវាយកម្ទេចចក្រពត្តិអាមេរិក និងបរិវារ រហូតលុះត្រាពួកវាត្រូវបរាជ័យទាំងស្រុង និងជាស្ថាពរ នៅថ្ងៃ១៧ មេសា ១៩៧៥ ។ មកដល់សម័យការពារ និងកសាងប្រទេសបច្ចុប្បន្ននេះ យុវជន-យុវនារីយើង ក៏នៅតែមានតួនាទីជាកម្លាំងស្រួចដដែលក្នុងការសម្រេចភារកិច្ច ការពារ និងកសាងប្រទេសរបស់បក្ស ។ ជាក់ស្តែង នៅឆ្នាំ១៩៧៧នេះ ចំពោះផែនការវាយសម្រុកធ្វើស្រែបង្កបង្កើនផលស្រូវឲ្យបានពី បីតោន និងប្រាំមួយតោនរបស់បក្ស យុវជន-យុវនារីយើង នៅគ្រប់ភូមិភាគ តំបន់ ស្រុក ទូទាំងកម្ពុជាប្រជាធិបតេយ្យយើង បានប្រយុទ្ធទ្រាំទ្រលំបាកវេទនាទាំងយប់ទាំងថ្ងៃ ពុះពារគ្រប់ឧបសគ្គសព្វបែបយ៉ាងទាំងអស់ ដើម្បីសម្រេចផែនការនេះ ឲ្យបានជោគជ័យទាំងស្រុងដាច់ខាត ។

ដោយឡែកតែយុវជន-យុវនារីសហករណ៍យើង នៅស្រុកថ្មពួក ភូមិភាគពាយ័ព្យ ក៏បងប្អូនបានចូលប្រឡូកក្នុងមហាចលនានេះ ជាមួយប្រជាជនសហករណ៍ ធ្វើការងារគ្រប់មុខព្រួញ យ៉ាងខ្លាំងក្លាប្រកបដោយគោលជំហរលះបង់ខ្ពស់បំផុតដែរ ។

លក្ខណៈភូមិសាស្ត្រស្រុកថ្មពួក មិនសូវអនុគ្រោះដល់ការធ្វើស្រែទេ ។ នៅលើវាលស្រែទាំងអស់ក្នុងស្រុកនេះ ភាគច្រើនមានដុះសុទ្ធតែដើមកកោះ ត្រាច ផ្ចឹក សុក្រំ ខ្ទុង ត្បែង រាំងភ្នំ ឈ្លីក ។ ស្ទើរពាសពេញទាំងអស់ ហើយសម្បូរទៅដោយភ្នំជាច្រើនទៀតផង ។ នៅចំពោះមុខលក្ខណធម្មជាតិមិនអនុគ្រោះដល់ការបង្កបង្កើនផលស្រូវយ៉ាងនេះ បងប្អូនយុវជន-យុវនារី និងកសិករសហករណ៍យើងនៅស្រុកថ្មពួក គ្មានរួញរា ស្ទាក់ស្ទើរ ឬចុះញ៉មធម្មជាតិឡើយ ។ ផ្ទុយទៅវិញ បងប្អូនមានជំនឿជឿជាក់ថា និងអាចកែប្រែទឹកដីបងប្អូនបាន ហើយប្តេជ្ញាសម្រេចផែនការបង្កើនផលស្រូវ ឲ្យបានបីតោន និងប្រាំមួយតោនរបស់បក្សឲ្យបានជោគជ័យទាំងស្រុងដូចតំបន់ផ្សេងៗទៀតដែរ ។

ដោយមានជំនឿជឿជាក់យ៉ាងនេះហើយ បានជាចាប់តាំងពីរដូវប្រាំងកន្លងមក យុវជន-យុវនារីយើងនៅស្រុកថ្មពួក បានប្រយុទ្ធលើកទំនប់ ធ្វើអាងទឹកបានជាច្រើនកន្លែង ដូចជាទំនប់គោកខ្វាវ ទប់ស្ទឹងដូនណយ អូរតាស្នួន ទំនប់បារាយណ៍ទប់ទឹកអូរតាអុង និងទំនប់អាងទឹកជើងគ្រួសជាដើម ។ តែក្នុងចំណោមអាងទឹកទាំងអស់ អាងទឹកដែលធំជាងគេ គឺអាងទឹកជើងគ្រួស ដែលចាប់លើកចេញពីប្រាសាទលាវ រហូតទល់នឹងបឹងកក់ ចម្ងាយ៧.០០០ម៉ែត្រ យកទឹកមកពីភ្នំដងរែក និងតាមអូរភ្លោះ ។ ក្រោយពីបញ្ចប់វគ្គដោះស្រាយទឹកហើយ បងប្អូនបានបន្តកាប់គាស់រានដីស្រែថ្មី និងលើកប្រព័ន្ធភ្លឺ បានជាច្រើនពាន់ហិកតាថែមទៀតដូចជានៅអមសងខាងផ្លូវលំមកពីស្រុកសេរីសោភណ្ឌ និងនៅខាងក្រោមទំនប់ជើងគ្រួស ។ ព្រមជាមួយនេះ កម្លាំងបងប្អូនយើងមួយចំនួនទៀត បានវាយសម្រុកប្រមែប្រមូលផ្សំជីធម្មជាតិបានជាច្រើនពាន់តោនសម្រាប់ដាក់ស្រែកែប្រែគុណភាពដី ។

ដោយសារការប្រយុទ្ធទាំងយប់ទាំងថ្ងៃ ពេញមួយប្រាំងកន្លងទៅនេះ ទឹកដីស្រុកថ្មពួកបានប្រែប្រួលប្លែកយ៉ាងឆាប់រហ័ស ។ ប្លែកម្យ៉ាងគឺមានវាលស្រែធំធេង មានប្រព័ន្ធភ្លឺកាត់ខ្វាត់ខ្វែងពាសពេញ ។ តែប្លែកម្យ៉ាងទៀត គឺមានទំនប់ អាំងទឹកជាច្រើន សម្រាប់ធ្វើស្រែម្តង ស្រែពីរដង បានដោយឯករាជ្យម្ចាស់ការ ។ យុវជន-

យុវនារីកងចល័ត ក៏ដូចជាកសិករសហករណ៍យើងនៅក្នុងស្រុកពួកទាំងមូលដែរ មានការរំភើបរីករាយនឹងមហាជ័យជម្នះនេះណាស់ ។

ឈរលើលក្ខណៈសម្បត្តិដ៏ល្អប្រសើរ នៃជ័យជម្នះនៅរដូវប្រាំង គ្រាន់តែចូលដល់រដូវវស្សាភ្លាម យុវជន-យុវនារីកងចល័តយើង ក៏បានវាយសម្រុកធ្វើស្រែវស្សាបានតាំងពីដើមដៃ ។ ការដ្ឋានស្រែដែលបងប្អូនធ្វើស្រូវបានដើមឆ្នាំ មាននៅវាលពាក់ដីក្នុងសហករណ៍បន្ទាយឆ្មារ វាយរហាល ក្នុងសហករណ៍កាប់ចោរ និងវាលនៅក្នុងសហករណ៍ភូមិថ្មី ។ បច្ចុប្បន្ននេះ បងប្អូនកំពុងវាយសម្រុកភ្ជួររាស់ ដកស្ទូង សាបព្រួសស្រូវវស្សា យើងសស្រោកសស្រាំ ជាបន្តបន្ទាប់ទៀត ដូចជានៅវាលអន្សង់ វាលតាស្មៅក្នុងសហករណ៍គោករមៀត វាលតាដៃ វាលតាកោក្នុងសហករណ៍បន្ទាយឆ្មារ វាលទ្រាល វាលពលសេនាក្នុងសហករណ៍ទ្រាស វាលអន្ទ្រង់ វាលចែងមែងក្នុងសហករណ៍ស្វាយចេក វាលស្លក្រាម វាលអូរវែង វាលផ្ទោលក្នុងសហករណ៍តាប៉ែន វាលខ្លែងព័រ វាលទ័ពសៀមក្នុងសហករណ៍កំណប់ វាលតាសៀវ វាលប្រាសាទក្នុងសហករណ៍យៀងវៀន និងវាលវិល្លយាវ វាលស្រែមេម៉ាយ វាលស្តៅក្នុងសហករណ៍គំរូជាដើម ។ ព្រមជាមួយនេះ កម្លាំងបងប្អូនយើងមួយចំនួនទៀត កំពុងប្រយុទ្ធថែទាំ បញ្ចេញបញ្ចូលទឹកដាក់ជី បាញ់ថ្នាំ បោចស្មៅ និងយាមសត្វព្រៃកុំឲ្យស៊ីស្រូវដែលស្ទូងហើយតាំងពីដើមដៃ យ៉ាងមមាញឹកទៀត ។

ក្នុងឋានៈខ្លួនជាអ្នកបន្តវេនបដិវត្តន៍ ឲ្យក្រហមឆ្អិនឆ្អៅជារៀងរហូត និងក្នុងឋានៈខ្លួនជាកងផលិត ដ៏អង់អាចក្លាហាន យុវជនយុវនារីស្រុកថ្មពួក ប្តេជ្ញាលះបង់អ្វីៗទាំងអស់ ដើម្បីវាយសម្រុកធ្វើស្រែឆ្នាំនេះ បង្កើនផលស្រូវឲ្យបាន បីតោន និងប្រាំមួយតោនរបស់បក្សឲ្យបានទាំងស្រុកដាច់ខាត និងប្តេជ្ញាកែប្រែមុខមាត់ស្រុកភូមិបងប្អូនឲ្យទៅជាសួនស្រូវ សួនដំណាំដ៏ស្រស់បំព្រងគ្រប់រដូវ រួមចំណែកវាយសម្រុកការពារប្រទេស និងកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យយើង ឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លា និងរីកចម្រើនដោយសន្ទុះលោតផ្លោះ ។

**៣) យុវជន-យុវនារីកម្មករបដិវត្តន៍យើង ខាងដឹកជញ្ជូនជើងគោក វាយសម្រុកបំពេញភារកិច្ច ដោយគោលជំហរទទួលខុសត្រូវខ្ពស់បំផុត**

ក្រោមការឃោសនាអប់រំ បំពាក់បំប៉នជាប់ជានិច្ច ពីបក្សកុម្មុយនីស្តកម្ពុជា យុវជន-យុវនារីបដិវត្តន៍កម្ពុជាយើង បានបំពាក់ជាប់នូវគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍កាន់តែរឹងប៉ឹងឡើងៗ ជាលំដាប់ ។ បងប្អូនបានយល់យ៉ាងច្បាស់លាស់ នូវភារកិច្ចស្នូលបច្ចុប្បន្ន ដែលត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យបានជ្រាលជ្រៅ ខ្លាំងក្លា ជាប់ជានិច្ច ដើម្បីការពារប្រទេសឲ្យបានគង់វង្ស ល្អប្រសើរ និងកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យ ឲ្យរីកចម្រើនលោតផ្លោះ យ៉ាងឆាប់រហ័ស ។ ដោយបងប្អូនបានយល់យ៉ាងច្បាស់លាស់ និងជ្រួតជ្រាបទៅក្នុងទស្សនៈគោលជំហរយ៉ាងរឹងប៉ឹងដូច្នេះហើយ បានជាយុវជន-យុវនារីបដិវត្តន៍យើងទាំងអស់ ទាំងនៅតាមសហជីព តាមសហករណ៍ ទាំងនៅតាមអង្គភាពកងទ័ពបដិវត្តន៍ ទាំងនៅតាមក្រសួងមន្ទីរនានា បានវាយសម្រុកបំពេញភារកិច្ចរៀងៗខ្លួន យ៉ាងខ្លាំងក្លា សស្រោកសស្រាំ និងដោយគោលជំហរទទួលខុសត្រូវខ្ពស់បំផុត ។

ដោយឡែកតែយុវជន-យុវនារី កម្មករបដិវត្តន៍យើងខាងដឹកជញ្ជូនជើងគោក បងប្អូនក៏បានវាយសម្រុកបំពេញភារកិច្ចខ្លួនយ៉ាងខ្លាំងក្លាដែរ ។ បងប្អូនសុទ្ធសឹងជាកូនចៅកសិករក្រីក្រ ។ បងប្អូនធ្លាប់តែភ្ជួររាស់ ដកស្ទូង ធ្លាប់តែកាប់ដី រែកដី លី សែង ធ្លាប់តែដើរកាត់ព្រៃភ្នំ បោចវល្លិ៍រកជ័រ ។ ហើយបងប្អូនពុំដែលបានប៉ះពាល់ឡាន បើកឡាន ជិះឡាន ឬស្គាល់នូវប្រព័ន្ធគ្រឿងម៉ាស៊ីនឡានយ៉ាងដូចម្តេចផងទេ ។ តែដោយបងប្អូនបំពាក់ជាប់នូវមាគ៌ាឯករាជ្យ-ម្ចាស់ការ ខ្លួនទីពឹងខ្លួនកម្រិតខ្ពស់របស់បក្ស និងបំពាក់ជាប់នូវគោលជំហរទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ចដែលបក្សប្រគល់ជូន បងប្អូនក៏បានខិតខំប្រយុទ្ធឈ្មុសឈ្មុលរៀនបើកបរឡានផង និងរៀនបច្ចេកទេសជួសជុលឡានផង យ៉ាងមានះ ព្យាយាមរហូតដល់បានសម្រេចជោគជ័យទាំងស្រុងយ៉ាងឆាប់រហ័ស ។ ជាក់ស្តែងសព្វថ្ងៃនេះ បងប្អូនអាចបម្រើការងារដឹកជញ្ជូន បានដោយម្ចាស់ការគ្រប់ពេលវេលា ពុំមានស្ទះ គាំងឡើយ ។ បងប្អូនស្គាល់តាំងពីសំឡេងឡានល្អ ឬសំឡេងឡានចង់ខូចឡើងទៅ ។ ក្នុងការបើកបរឡាន បងប្អូនប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ និងលើកកម្ពស់នូវស្មារតីទទួលខុសត្រូវខ្ពស់គ្រប់ពេលវេលា ។ បងប្អូនបើកបរឡានដឹកជញ្ជូនសម្ភារគ្រប់មុខ និងផលិតផលផ្សេងពីកន្លែងមួយទៅកន្លែងមួយ និងដឹកយកទៅផ្តល់

ជូនកសិករសហករណ៍យើង ទាំងយប់ទាំងថ្ងៃយ៉ាងមមាញឹក ។ បងប្អូនបានប្រយុទ្ធការពារសម្ភារទាំងនោះ មិនឲ្យត្រូវភ្លៀង ឬកំពប់កំពាចខូចខាតចោលដោយប្រការណាមួយឡើយ ។ បងប្អូនតែងសហការជួយគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ។ ដើម្បីសន្សំសំចៃប្រេងជូបបក្សឲ្យបានជាអតិបរមា បងប្អូនមិនប្រើប្រាស់វាខ្ជះខ្ជាយរាយមាយ ឬបើកឡានត្រឡប់មកវិញដោយទទេទេ ។ បងប្អូនច្នៃប្រឌិតប្រើប្រាស់ឡាន យ៉ាងរស់រវើកជាប់ជានិច្ច ។ លើសពីនេះទៅទៀត បងប្អូនបានច្នៃប្រឌិតយករ៉ឺម៉កដែលបងប្អូនកម្មករបដិវត្តន៍យើងធ្វើបាន មកផ្ទុករបស់របរសព្វមុខ បានទ្វេមួយជាពីរថែមទៀត ។ ហើយបងប្អូនបានយកចិត្តទុកដាក់ ថែរក្សាការពារឡានបីដូចកងទ័ពបដិវត្តន៍យើងស្រឡាញ់ និងថែទាំកាំភ្លើងដូច្នោះដែរ ។ មុនពេលបើកបរ និងរាល់ពេលត្រឡប់មកពីបើកបរវិញ បងប្អូនតែងតែដើរពិនិត្យមើលខ្មៅខ្លង ចាក់ប្រេង ដាក់ខ្លាញ់ ចាក់ទឹក និងសំអាតដុសលាងវាជាប្រចាំ ។

ទន្ទឹមនឹងភារកិច្ចបើកបរ ដ៏មមាញឹកនេះ បងប្អូននៅបានឈ្មុសឈ្មុល ច្នៃប្រឌិតធ្វើគ្រឿងបន្លាស់ និងឧបករណ៍ផ្សេងៗ ដែលត្រូវការប្រើប្រាស់ចាំបាច់ បានដោយជោគជ័យទៀត ។ គ្រឿងបន្លាស់ដែលបងប្អូនធ្វើបានកន្លងមកមាន ធុងអាគុយ គម្របដែលកូរទុយយោទឹកដែលមានទំហំ៤៥លី ទៅ៦០លី វ៉ង់គុយឡាស់ ប៊ូឡុងខ្មៅខ្លងទាំងអស់ ពីស្តុងគ្រប់ធុន ឌីណាម៉ូ និងក្បាលចែកភ្លើងជាដើម ។ មិនតែប៉ុណ្ណោះ បងប្អូននៅបានជួសជុលកែច្នៃរបស់របរដែលខូចខាត ដូចជាកូនជ្រូក និងកាឡេឡានជាដើម ឲ្យប្រើប្រាស់បានឡើងវិញទៀតផង ។ ឧបករណ៍ប្រើប្រាស់ទាំងអស់នេះ កាលពីសង្គមចាស់ ពួកអាក្បត់លន់នល់ និងបរិវារវាគ្មានធ្វើកើតទេ ។ ពួកវាទិញចូលពីបរទេសទាំងស្រុង ។ តែយុវជន-យុវនារីបដិវត្តន៍យើង ដែលបានយល់ជ្រួតជ្រាបយ៉ាងច្បាស់លាស់ នូវមាគ៌ាការពារ និងកសាងប្រទេសរបស់បក្ស ហើយប្រកាន់ខ្ជាប់ខ្ជួន នូវគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនកម្រិតខ្ពស់ បងប្អូនក៏បានវាយសម្រុករៀនសូត្រ កែប្រែច្នៃប្រឌិតធ្វើបានគ្រឿងបន្លាស់ផ្សេងៗទាំងនេះ ដោយឯករាជ្យម្ចាស់ការ ហើយប្រើប្រាស់វត្ថុធាតុដើមនៅក្នុងប្រទេសយើងទាំងអស់ ហើយសព្វថ្ងៃនេះ បងប្អូនកំពុងតែស្ទូរំលាយដែក ពិសោធចាក់ធ្វើកាប៊ីនឡាន និងសាក់ស៊ីឡានថែមទៀត ។

អាស្រ័យដោយបងប្អូន មានគោលជំហរទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ច ទាំងគ្រប់ផ្នែកយ៉ាងដូច្នេះហើយ បានជាបងប្អូនបំពេញភារកិច្ចបម្រើបក្ស បម្រើប្រជាជនបានល្អប្រសើរ ពុំដែលមានស្ទះគាំង ឬខូចខាតអ្វីឡើយ ។ ព្រមជាមួយនេះ បងប្អូននៅបានយកចិត្តទុកដាក់ប្រជុំដកពិសោធ និងប្រជុំរៀនសូត្រ នយោបាយសតិអារម្មណ៍ ចាត់តាំងបដិវត្តន៍ និងរៀនវប្បធម៌ បច្ចេកទេសវិទ្យាសាស្ត្រ ជារៀងរាល់ថ្ងៃថែមទៀត ដើម្បីពង្រឹងគោលជំហរទទួលខុសត្រូវ ឲ្យរឹងប៊ឹងទ្វេឡើង លត់ដំកសាងខ្លួន និងផ្សារភ្ជាប់ខ្លួនទៅនឹងមហាចលនាវាយសម្រុកការពារ កសាងប្រទេស និងបន្តធ្វើបដិវត្តន៍សង្គមនិយមរបស់ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍យើង ដែលកំពុងតែវិវត្តទៅមុខលឿនស្លេវ ឲ្យបានស្អិតរមួត និងក្តៅជាប់ជានិច្ច ។

យុវជន-យុវនារីបដិវត្តន៍យើង នៅក្រសួងដឹកជញ្ជូនជើងគោក ក៏ដូចជាយុវជន-យុវនារីបដិវត្តន៍យើង នៅទូទាំងប្រទេសដែរ ប្តេជ្ញាវាយសម្រុកបំពេញភារកិច្ចឲ្យកាន់តែខ្លាំងក្លាថែមទៀត និងពង្រឹងនូវជំហរទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចភារកិច្ចដែលបក្សប្រគល់ជូន ឲ្យបានឆាប់រហ័ស និងល្អប្រសើរ ជាអតិបរមា រួមចំណែកការពារប្រទេស និងកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យយើង ឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លា និងរីកចម្រើន ថ្កុំថ្កើងរុងរឿង ដោយល្បឿនមហាលោតផ្លោះមហាអស្ចារ្យ ។

**ឆេង ទ៉េង**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# វគ្គបណ្ដុះបណ្ដាលគរុសិស្ស មកពីសាលាគរុកោសល្យ
# កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅវិទ្យាស្ថា









# ភូមិភាគបាត់ដំបងស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រ នជាតិអប់រំ ពីថ្ងៃទី១៨ ដល់ ១៩ ខែសីហា ឆ្នាំ២០១៧













WOULD YOU PLEASE
KINDLY SHOW YOUR
RESPECT TO MANY
MILLION PEOPLE
WHO WERE KILLED
POL POT REGIME





# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthsodavy.u@dccam.org* ។





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ម៉ែន ពិចិត្រ ទូរសព្ទលេខ ៖ ០២៣ ២១៨ ០០៩ អ៊ីម៉ែល ៖ truthmpechet@dccam.org*

# កុមារីក្នុងសម័យខ្មែរក្រហម

នៅក្នុងអំឡុងឆ្នាំ១៩៧០ ម្ដាយរបស់ខ្ញុំ ឈ្មោះ យុន សុខណា ដែលកាលនោះនៅជាកុមារី ក្នុងវ័យប្រហែលដប់ឆ្នាំ កើតនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល បានបាត់បង់ឪពុកជាទីស្រឡាញ់ ដោយសារការទម្លាក់គ្រាប់បែកជាច្រើនគ្រាប់មកលើផ្ទះរបស់គាត់ ។ ការទម្លាក់គ្រាប់បែកមិនឈប់ឈរបានធ្វើឲ្យជីវិតរបស់ម្ដាយខ្ញុំរស់នៅក្នុងសភាពភ័យខ្លាច ។ គាត់ និងក្រុមគ្រួសារតែងតែរត់ពីកន្លែងមួយទៅកន្លែងមួយ កាត់ព្រៃកាត់ភក់ ដែលការរត់គេចខ្លួននោះប្រព្រឹត្តទៅនៅពេលយប់ ។

បន្ទាប់ពីការទម្លាក់គ្រាប់បែកបានបញ្ចប់ ដោយសារកងយោធាខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញ នាខែមេសា ឆ្នាំ១៩៧៥ ម្ដាយរបស់ខ្ញុំក៏បានមករស់នៅជុំគ្នាជាមួយជីដូនខ្ញុំ និងបងប្អូនរបស់គាត់នៅផ្ទះកំណើតរបស់គាត់វិញ ។ តែរស់នៅជាមួយគ្រួសារមិនបានប៉ុន្មានផង ម្ដាយខ្ញុំត្រូវបែកគ្នាម្ដងទៀត ដោយជីដូន និងបងរបស់ម្ដាយខ្ញុំត្រូវបានបង្ខំឲ្យទៅធ្វើការងារស្រែចម្ការនៅឆ្ងាយពីផ្ទះ ។ ទោះបីម្ដាយខ្ញុំនៅតូចក៏ដោយ ក៏ខ្មែរក្រហមមិនឲ្យគាត់ នៅទំនេរដែរ ម្ដាយខ្ញុំត្រូវបានខ្មែរក្រហមឲ្យរើសអាចម៍គោនៅពេលថ្ងៃ និងដើរដេញកណ្ដុរកុំឲ្យស៊ីស្រូវនៅពេលយប់ ។ ទីតាំងដែលម្ដាយខ្ញុំត្រូវធ្វើការស្ថិតនៅឆ្ងាយពីផ្ទះ ជួនកាលខ្មែរក្រហមបញ្ជូនគាត់ឲ្យទៅដេញកណ្ដុរនៅទួលរោងដំរី ឬប្រាំកើតជាដើម ។ ម្ដាយរបស់ខ្ញុំកម្រនឹងបានសម្រាកក្នុងភូមិណាស់ ។ ចំណែកឯម្ហូបអាហារវិញមិនមានហូបគ្រប់រដូវនោះទេ ។ ថ្ងៃខ្លះ ខ្មែរក្រហមចែកបបរលាយជាមួយដំឡូងឈើ ថ្ងៃខ្លះបបរលាយត្រកួន ។

ម្ដាយខ្ញុំបានរំឭកប្រាប់ខ្ញុំថា របបអាហារដែលទទួលបានមិនគ្រប់គ្រាន់នោះទេ ។ គាត់បន្តថា ស្រូវ ពោត ដំឡូង និងផ្លែដូង ប្រជាជនបានដាំ និងប្រមូលផលបានច្រើនណាស់ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនហូបទេ ។ ម្ដាយខ្ញុំមិនដឹងថា ខ្មែរក្រហមយកផលដំណាំទាំងអស់នោះទៅណាទេ ។

នៅក្នុងឆ្នាំ១៩៧៨ ម្ដាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមប្ដូរឲ្យទៅធ្វើការជាអ្នកលាយថ្នាំ និងផ្សំថ្នាំនៅមន្ទីរពេទ្យ ក្នុងឃុំវិហារសួគ៌វិញ ។ នៅទីនោះ គាត់ក៏មិនបានសម្រាកគ្រប់គ្រាន់ដែរ ខ្មែរក្រហមតម្រូវឲ្យគាត់ធ្វើការតាំងពីព្រឹកទល់យប់ ។ ចំពោះរបបអាហារក៏មិនខុសគ្នាកាលនៅក្នុងកងកុមារដែរ ពោលគឺបបរលាយត្រកួន និងលាយដំឡូងដដែល ។

នៅ១៩៧៩ នៅពេលដែលរបបខ្មែរក្រហមត្រូវបានផ្ដួលរំលំ ក្រុមគ្រួសាររបស់ម្ដាយខ្ញុំបានមករស់នៅជុំគ្នាវិញ ។ បន្ទាប់មក គាត់ក៏បានរៀបការជាមួយឪពុករបស់ខ្ញុំ ។



របឈរនៅកណ្ដាល ៖ យុត សុខណា ម្ដាយរបស់ សេងហឿន និង សេង ហឿន (រូបទីមួយរាប់ពីស្ដាំ) ថតនៅឆ្នាំ១៩៩៨ នៅក្នុងពិធីបុណ្យមួយ ។

លទ្ធផលនៃការរស់នៅយ៉ាងលំបាកវេទនាអស់រយៈពេលជិតបួនឆ្នាំ ម្ដាយរបស់ខ្ញុំបានបាត់បង់បងប្រុសម្នាក់ ដោយសារការហូបចុកមិនគ្រប់គ្រាន់ និងការធ្វើការហួសកម្លាំង ។ រឿងរ៉ាវទាំងអស់នេះ នៅតែបន្តស្ថិតនៅក្នុងការចងចាំរបស់ម្ដាយខ្ញុំ បើទោះបីជាពេលវេលាបានកន្លងផុតទៅជាងសែសិបឆ្នាំហើយក៏ដោយ ។ **យាង សេងហឿន**

# គ្រូតែងនិពន្ធដែលនៅរស់ជីវិតពីរបបខ្មែរក្រហម

វ៉ែន សុន មានឈ្មោះដើមហៅថា រិត សុន្ទសារី ។ គាត់បានប្តូរមកប្រើឈ្មោះ វ៉ែន សុន នេះបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំនៅឆ្នាំ១៩៧៩ ។ គាត់កើតនៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៣៩ នៅភូមិខ្វ៉ាង ឃុំស្វាយ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ឪពុករបស់គាត់គឺជាអតីតមេស្រុក រីឯម្តាយជាមេផ្ទះ ។ ជាអកុសល ឪពុករបស់គាត់បានស្លាប់នៅឆ្នាំ១៩៤៥ ដោយសារជំងឺអាសន្នរោគ ។ គាត់ជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីបីនាក់ (ស្រី២នាក់) ។ នៅពេលដែលគាត់មានអាយុ៦ឆ្នាំ គាត់ត្រូវបានជីតាខាងឪពុកយកទៅរៀននៅវត្តរហូតដល់អាយុ១៨ឆ្នាំ ទើបគាត់សម្រេចចិត្តបួសជាព្រះសង្ឃ ។ បន្ទាប់ពីបួសរៀនបាន៨ឆ្នាំ គាត់ក៏បានសឹក រួចហើយបានសុំម្តាយមកបន្តការសិក្សានៅទីក្រុងភ្នំពេញ ។ មកដល់ភ្នំពេញ គាត់បានស្នាក់នៅជាមួយព្រះសង្ឃមួយអង្គព្រះនាម ព្រះសេរី សង្គាមមុនី អន ឡាច នៅវត្តកោះ ។ គាត់រៀនបាន៥ឆ្នាំ នៅទីក្រុងភ្នំពេញ ។ ក្រោយមក គាត់ក៏ឈប់រៀនដោយសារតែឃើញម្តាយលំបាក ។ មិនយូរប៉ុន្មាន គាត់បានចូលរៀនផ្នែកតូរ្យតន្ត្រីសម័យ នៅទីស្នាក់ការតន្ត្រីយុវជនរាជសង្គមនិយមខ្មែរ ជាមួយគ្រូ ម៉ៅ វណ្ណា ដែលជាប្រធានក្រុមភ្លេង ព្រមទាំងបានទៅរៀនបន្តនៅក្នុងក្រុមក្លាសិក នៅក្នុងព្រះបរមរាជវាំង ។

នៅឆ្នាំ១៩៦៤ សុន ចាប់ផ្តើមនិពន្ធទំនុកច្រៀងជាមួយគ្រូ ស្វាយ ស នៅក្នុងក្រុមតន្ត្រីព្រះរាជទ្រព្យ ។ នៅក្នុងក្រុមនេះ អ្នកចម្រៀងមាន ដូចជា លោក ដាន់ សុកូ និងអ្នក ស្រី ស៊ិន ណារី ជាដើម ។ ក្រៅពីរៀនតែងនិពន្ធ គាត់បានរៀនអក្សរភ្លេង និងទ្រឹស្តីអក្សរភ្លេងជាមួយគ្រូជនជាតិបារាំងឈ្មោះ រីកូ ។ នៅឆ្នាំ១៩៦៥ គាត់បានចូលបម្រើការងារនៅក្នុងក្រុមតន្ត្រីរាជតម្រួតភិរម្យនៅ



លោកគ្រូ វ៉ែន សុន នៅការិយាល័យរបស់គាត់

ទូលគោក ។ នៅពេលនោះ គាត់ចាប់ផ្តើមដើរដង្ហែតាមសម្តេចព្រះនរោត្តម សីហនុ ទៅគ្រប់ទិសទីដើម្បីចែកអំណោយ និងសម្ពោធសាលារៀនជាដើម ។ គាត់ធ្វើការបណ្តើរ រៀនបណ្តើរ និពន្ធចម្រៀង និងលេងភ្លេងជាមួយគ្រូ មែរ ប៊ុនណា និងគ្រូ ហាស់ សាឡន ។ គាត់លេងឧបករណ៍សាក់សូហ្វូន ហើយគាត់ក៏បាននិពន្ធចម្រៀងមួយចំនួនថតនៅក្នុងស្ទូឌីយូវិទ្យុជាតិ ដែលច្រៀងដោយអ្នកស្រី សូ សាវឿន អ្នកស្រី ហៃ សុខុម លោក ផាន់ សុកូ លោក ជិន វ៉ាន់ធួន អ្នកស្រី យន់ ស៊ីណាត កែវ សុខា និងលោក ទេព សង្វារ ជាដើម ។ បទចម្រៀងដែលគាត់បាននិពន្ធនៅពេលនោះរួមមាន ខ្ញុំមលោហិតរន្ទះប៉ុអរ ជាដើម ។ សុន បានរម្លឹកថា នៅក្នុងក្រុមរបស់គាត់នៅពេលនោះមានសមាជិកប្រហែល៣០នាក់ ទាំងអ្នកភ្លេង អ្នកចម្រៀង និងអ្នកកំប្លែង ដូចជា ទេព សង្វារ (អ្នកចម្រៀងបច្ចុប្បន្នរស់នៅខេត្តសៀមរាប) សាន គឹមសៀន (អ្នកលេងហ្គីតាសូឡូ បច្ចុប្បន្នជាប្រធានសហព័ន្ធល្បុក្កតោ) ផាន់ សុកូ ជិន វ៉ាន់ធួន កែ សុខា ហៃ សុខុម នួន សុខឿន សូ សាវឿន និង ពៅ សុផេន ។ល ។

នៅឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ក្រុមទាហាន លន់ នល់ បានរឹបអូសយកឧបករណ៍ភ្លេង និងបានបញ្ជូនគាត់ទៅអប់រំរយៈពេលមួយខែ ។ បន្ទាប់ពីទទួលការអប់រំ គាត់បានចូលបម្រើការនៅក្នុងវិទ្យុផ្សាយសំឡេង យុទ្ធជន៥ឆ្នាំនៅវិទ្យុជាតិ ។ នៅពេលនោះ គាត់បានរៀបចំកម្មវិធីបី ។ កម្មវិធីទីមួយគឺ កម្មវិធីកំណាព្យ ដែលសិស្ស និស្សិត និងព្រះសង្ឃ ផ្ញើមក ។ មុននឹងចាក់ផ្សាយ គាត់បានកែសម្រួលឃ្លោងឃ្លាកំណាព្យទាំងនោះ ។ ប្រសិនបើកំណាព្យដែលផ្ញើមកកម្មវិធីមិនគ្រប់ចំនួន គាត់ត្រូវសរសេរបន្ថែមដោយខ្លួនឯង ។ កម្មវិធីទីពីរគឺ កម្មវិធីរឿងកំប្លែងខ្លី និងកម្មវិធីទីបីគឺ កម្មវិធីបទភ្លេងប្រពៃណីខ្មែរ ។ នៅអំឡុងពេលនោះក៏ចាប់ផ្តើមមានការផ្លោងគ្រាប់ពីសំណាក់យោធាខ្មែរក្រហមរៀងរាល់ថ្ងៃចូលមកទីក្រុងភ្នំពេញដែរ ។

នៅឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ គាត់បានស្នាក់នៅផ្ទះ ខាងក្រោយវត្តនាគវ័ន្ត ។ នៅព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ប្រហែលម៉ោង៥ ឬ ៦ព្រឹក យោធាខ្មែរក្រហមបានមកដល់ផ្ទះរបស់គាត់ ព្រមទាំងបានបង្ខំ និងប្រាប់គាត់ឲ្យចាកចេញពីទីក្រុងដើម្បីអង្គការបោសសម្អាតខ្មាំង ។ នៅ



លោកគ្រូ វ៉ែន សុន ត្រូវបានជ្រើសរើសជាជ័យលាភី ប្រចាំប្រទេសកម្ពុជា ក្នុងមហោស្រពកវីអាស៊ាន នៅទីក្រុងបាងកក ប្រទេសថៃ។

ពេលនោះ កូនរបស់គាត់នៅតូចៗ នៅឡើយ ។ កូនច្បងបង្អស់របស់គាត់មានអាយុ៧ឆ្នាំ ។ គាត់ និងក្រុមគ្រួសារ បានធ្វើដំណើរសំដៅទៅស្ពានជ្រោយចង្វារ ។ នៅតាមផ្លូវ គាត់បានជួបព្រះសង្ឃមួយអង្គដែលស្គាល់គ្នា ។ ព្រះសង្ឃអង្គនោះបានសួរគាត់អំពីគោលដៅនៃការធ្វើដំណើរ ប៉ុន្តែគាត់មិនទាន់បានឆ្លើយប្រាប់ផង ក៏ត្រូវបានយោធាខ្មែរក្រហមភ្ជង់កាំភ្លើងបង្ខំឲ្យបន្តដំណើរទៅមុខ ។ ស្ថានភាពជម្លៀសប្រជាជននៅពេលនោះមានសភាពណែនណាន់តាន់តាប់ ។ គាត់មិនបានធ្វើដំណើរទៅឆ្ងាយពីស្ពានជ្រោយចង្វារប៉ុន្មានទេ ដោយសារតែគាត់គិតថា បីថ្ងៃក្រោយ ខ្មែរក្រហមនឹងឲ្យប្រជាជនវិលចូលមកក្រុងវិញជាមិនខាន ។ ប៉ុន្តែ ខ្មែរក្រហមបែរជាបន្តដេញប្រជាជនឲ្យធ្វើដំណើរទៅមុខ ។ គាត់បានធ្វើដំណើរតាមផ្លូវជាតិលេខ៥ ។ នៅតាមផ្លូវ គាត់បានឃើញយោធាខ្មែរក្រហមសម្លាប់អ្នកយាមរោងចក្រទឹកក្រូចមួយ នៅម្តុំឫស្សីកែវ ។

សុន បានរៀបរាប់ថា បីថ្ងៃក្រោយមកពីខ្មែរក្រហមរំដោះភ្នំពេញ លុយលែងមានតម្លៃដូចពីមុនហើយ ។ ប្រសិនបើប្រជាជនចង់បានអ្វីហូប ប្រជាជនត្រូវតែយកមាស ឬរបស់របបផ្សេងៗទៅដូរជាមួយ ។ ពេលធ្វើដំណើរទៅដល់ព្រែកក្តាម គាត់និងក្រុមគ្រួសារបានសម្រាកនៅវត្តគ្រោះមួយយប់ ។ គាត់មានបំណងធ្វើដំណើរកាត់តាមខេត្ត ដើម្បីបានជួបជុំជាមួយម្តាយរបស់គាត់ ។ ប៉ុន្តែខ្មែរក្រហមបានបញ្ជាឲ្យគាត់ឆ្លងទន្លេទៅត្រើយម្ខាងទៀត ។ ខ្មែរក្រហមមិនបានផ្តល់ទូកសម្រាប់ឆ្លងទន្លេនោះទេ ។ គាត់ត្រូវរកទូកឆ្លងដោយខ្លួនឯង ។ នៅពេលនោះ គាត់បានឃើញប្រជាជនអុំទូកទើបគាត់សុំឲ្យម្ចាស់ទូកជួយចម្លងទៅកាន់ត្រើយម្ខាងទៀត ដោយបានឲ្យអង្ករទៅម្ចាស់ទូកម្នាក់ពីរកំប៉ុង ។ បន្ទាប់ពី ឆ្លងទន្លេ គាត់បានធ្វើដំណើរទៅដល់ស្រុកបាធាយ ខេត្តកំពង់ចាម ។ នៅទីនោះ ខ្មែរក្រហមបានសួរប្រវត្តិរូបប្រជាជនជម្លៀស រួមទាំងគ្រួសារគាត់ ។ គាត់បានប្រាប់ខ្មែរក្រហមថា គាត់ជាកម្មករនៅភ្នំពេញ ។ គាត់ឆ្លើយដូច្នោះ ដោយសារតែបងជីទួតមួយរបស់គាត់ដែលរស់នៅទីនោះបានប្រាប់ និងណែនាំគាត់មិនឲ្យផ្លាស់ប្តូរចម្លើយនោះឡើយ ។ បន្ទាប់មក ខ្មែរក្រហមបានឲ្យគាត់រស់នៅភូមិប្រសូត ខាងជើងស្រុកបាធាយ ខេត្តកំពង់ចាម ។ បន្ទាប់ពីរស់នៅទីនោះបានរយៈពេលមួយខែ គាត់បានស្នើសុំអង្គការចេញពីភូមិ ពីព្រោះពេលនោះអង្គការបានបែងចែកប្រជាជន រវាងប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ។ ប៉ុន្តែ មេភូមិដែលមានចិត្តមេត្តាបានឃាត់គាត់ឲ្យបន្តរស់នៅទីនោះមួយរយៈសិន ព្រោះអង្គការចាប់ផ្តើមសម្លាប់មនុស្សយកខោអាវ ។ មួយអាទិត្យក្រោយមក គាត់បានសុំការអនុញ្ញាតពីប្រធានភូមិម្តងទៀត ហើយប្រធានភូមិក៏បានយល់ព្រម និងបានប្រាប់គាត់ឲ្យធ្វើដំណើរតាមផ្លូវផ្សេង ។

នៅពេលទៅដល់ភូមិខ្វ៉ាង ឃុំស្វាយ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង អង្គការបែងចែកប្រជាជនឲ្យទៅរស់នៅខ្ទមតាមវាលស្រែ ។ ផ្ទះសម្បែង និងវត្តអារាមត្រូវបាន ខ្មែរក្រហមដុតបំផ្លាញចោល ដោយឡែកគម្ពីរសាស្ត្រាផ្សេងៗក៏ខ្មែរក្រហមមិនរក្សាទុកដែរ ។ នៅពេលនោះ គាត់បានជួបជុំជាមួយម្តាយរបស់គាត់ ។ ពេលម្តាយរបស់គាត់ ឃើញគាត់ភ្លាម មុខរបស់ម្តាយគាត់បានប្រែទៅជាស្លាំង ព្រោះស្មានថា គាត់ស្លាប់បាត់បង់ជីវិតទៅហើយ ។ បន្ទាប់ពីដុតផ្ទះសម្បែងប្រជាជន និងវត្តអារាម ខ្មែរក្រហមបានជម្លៀសប្រជាជនទៅខាងលិចផ្លូវរថភ្លើង ។ គាត់ត្រូវបានអង្គការចាត់ឲ្យទៅធ្វើការនៅក្នុងកងទី៩ នៅសហករណ៍ឃុំ ដែលប្រជាជននៅក្នុងកងភាគច្រើនជាប្រជាជនជាប់និន្នាការពីសង្គមចាស់ ។ មុនដំបូង អង្គការបានចាត់តាំងគាត់ឲ្យទៅភ្ជួរស្រែ ។ បើទោះបីជាគាត់ធ្លាប់រស់នៅស្រុកស្រែ តែគាត់មិនធ្លាប់ធ្វើការងារនោះទេ ។ ប៉ុន្តែគាត់មិនហ៊ានប្រកែកនឹងបញ្ជារបស់អង្គការដែរ ។ នៅពេលគាត់កំពុងភ្ជួរ នង្គ័លបានទាក់ជាប់ស្មៅទៅមុខមិនរួច ពេលនោះ គាត់បានយកជើងធាក់ស្មៅចេញពីផាលនង្គ័ល ។ តែដោយសារមិនបានប្រយ័ត្ន គាត់ក៏បានមុតជើងនឹងផ្លែនង្គ័ល ។ ក្រោយមក អង្គការបានបញ្ជូនគាត់ឲ្យទៅធ្វើជាជាងឈើ សង់ផ្ទះ ផលិតកណ្តៀវ និងរនេះវិញ ។ សុន បានរម្លឹកថា ថ្ងៃមួយ នៅពេលដែលគាត់កំពុងធ្វើគ្រែ គាត់បានស្តាប់ឮខ្មែរក្រហមជជែកគ្នាថា «បើយើងទុកអាម្នាក់ហ្នឹងក៏មិនខាតដែរ ដាក់ឲ្យធ្វើអីធ្វើបានហ្នឹង» ។ បន្ទាប់ពីស្តាប់ឮសម្តីខ្មែរក្រហមនិយាយដូច្នេះ គាត់មិនហ៊ាននិយាយស្តីអ្វីទាំងអស់ក្រៅអំពីខិតខំប្រឹងប្រែងធ្វើការតាមបញ្ជារបស់អង្គការដើម្បីរក្សាជីវិត ។

រហូតដល់ឆ្នាំ១៩៧៩ គាត់បានឃើញខ្ទម្ភាគចក្រហោះសំដៅទៅទិសខាងជើង ។ ស្ថានភាពនៅពេលនោះចាប់ផ្តើមចលា

ចល ។ អង្គការបានជម្លៀសប្រជាជនទៅភ្នំជម្រាយ និងបានបង្គាប់ឲ្យគាត់ទៅជួសជុលរោងម៉ាស៊ីនកិនស្រូវនៅអណ្តូងប្រេង ខាងលិចរូងខ្លា ។ គាត់បានគិតថា ការធ្វើដំណើរលើកនេះហាក់ដូចជាប្លែក ដោយសារតែអង្គការបានមកស្រង់ប្រវត្តិរូបរបស់គាត់ឡើងវិញ ។ គាត់យល់ថា ប្រហែលជាអង្គការមានបំណងចង់បញ្ជូនគាត់ទៅសម្លាប់ ។ នៅពេលទៅដល់ទីនោះ ខ្មែរក្រហមបានសួរគាត់ថា មកទីនេះធ្វើអ្វី? គាត់បានឆ្លើយថាមកជួសជុលរោងម៉ាស៊ីនកិនស្រូវ ។ សំណាងល្អ កងទ័ពរំដោះបានផ្ទោងគ្រាប់មកធ្លាក់នៅខាងលិចរូងខ្លា ធ្វើឲ្យខ្មែរក្រហមរត់គេចខ្លួនអស់ ។ ឃើញដូច្នេះ គាត់ក៏បានរត់ត្រឡប់មកជួបជុំគ្រួសារនៅភ្នំជម្រាយវិញ ។

បន្ទាប់ពីជួបជុំគ្រួសារហើយ គាត់បាននាំគ្នាទៅរស់នៅខាងលិចផ្សារត្រាច ។ គាត់បានបាត់បង់សាច់ញាតិអស់មួយចំនួននៅក្នុងរបបខ្មែរក្រហម ដូចជា ឪពុកមាឈ្មោះ រ៉ុត ណៃ ប្អូនជីដូនមួយឈ្មោះ កាន់ ណេន និងក្រុមគ្រួសារបងថ្លៃរបស់គាត់ ។ រីឯប្អូនជីដូនមួយ ឈ្មោះ កាន់ ប៉ាក់ ក៏បាត់ខ្លួនរហូតដល់សព្វថ្ងៃដែរ ។

លុះដល់ខែមេសា ឆ្នាំ១៩៧៩ គាត់បានត្រឡប់មកភ្នំពេញវិញ ។ នៅខែតុលា ឆ្នាំ១៩៧៩ គាត់បានដាក់ពាក្យចូលបម្រើការផ្នែកសិល្បៈកងទ័ព ។ នៅពេលនោះ គាត់ត្រូវបាន ចាត់តាំងឲ្យធ្វើការនៅក្នុងក្រុមត្រៃទ័ព ដែលមាននាទីជាអនុប្រធានភ្លេងត្រៃទ័ព ចំណែកលោក អ៊ុន ស៊ូយ៉េត ជាប្រធាន ។ ក្រុមរបស់គាត់បានប្រមូលឧបករណ៍ភ្លេងចាស់ៗមកជួសជុល និងប្រមូលសមាជិកដែលសល់ពីការកាប់សម្លាប់របស់ខ្មែរក្រហមបានចំនួន៣៥នាក់ និងបានចូលរួមសម្តែងនៅក្នុងក្បួនព្យុះហយាត្រាលើកទី១ នៅឆ្នាំ១៩៧៩ ។ បន្ទាប់មក តា ជ័យ សុភា អគ្គស្នងការនយោបាយបានផ្ទេរក្រុមភ្លេងត្រៃទ័ពទៅឲ្យមន្ទីរនយោបាយក្រុង នៅក្នុងក្រុមសិល្បៈមហាជន ។ គាត់ត្រូវផ្លាស់មកគ្រប់គ្រងសិល្បៈមហាជនយោធាក្រុង ។ សុន បានមានប្រសាសន៍ថា នៅពេលនោះ ក្រុមសិល្បៈមហាជនបានជំរុញឲ្យមានការបង្កើតក្រុមសិល្បៈមហាជនគ្រប់ខេត្ត ព្រមទាំងបានបង្កើតសិល្បៈយោធាក្រុង សិល្បៈសម័យ និងល្ខោននិយាយតាមវិទ្យុ ។ គាត់បានបង្កើតស្នាដៃជាច្រើន ដូចជានិពន្ធល្ខោននិយាយតាមវិទ្យុរឿង "ចំណងដៃទឹកភ្នែក" និងខ្សែភាពយន្តរឿង "ផ្កាដុះលើថ្ម" ។ បន្ទាប់មកគាត់បានរៀន និងធ្វើការជាមួយគ្រូ ស៊ាយ ស ជាអ្នកដឹកនាំក្រុមភ្លេងសម័យរបស់យោធាក្រុង ព្រមទាំងបានទៅរៀននៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ផ្នែកនិពន្ធរៀបរៀងបោះពុម្ពសៀវភៅ ដឹកនាំសិល្បៈ មហាជន និងនិពន្ធដឹកនាំរឿងល្ខោននិយាយ ។ បទភ្លេងទំនុកចម្រៀងល្បីរបស់គាត់ពេលនោះ គឺបទ "កន្សែងប៉ាក់ដរ" ។

នៅឆ្នាំ១៩៨៧ គាត់បានផ្លាស់ទៅបម្រើការនៅអគ្គស្នងការនយោបាយ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ដោយបានបង្កើតវគ្គបណ្តុះបណ្តាលដូចដែលគាត់បានរៀនសូត្រខាងលើ ។ មិនតែប៉ុណ្ណោះ គាត់បានបន្តរៀនជាមួយគ្រូ ឃី ធន់ គ្រូ ពេជ ទុំក្រវិល គ្រូ ជ័យ ចាប និងគ្រូ វ៉ាន់ ឌីកាអុន ផ្នែកអក្សរសិល្ប៍ ក្នុងវគ្គបណ្តុះបណ្តាលអ្នកនិពន្ធទូទាំងកងទ័ព ។ បន្ទាប់ពីរៀនចប់ គាត់បានចូលរួមប្រឡងមហោស្រពកំណាព្យទូទាំងប្រទេសអំពីកំណាព្យ អប់រំ ដោយទទួលបានមេដាយមាសពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងទទួលបានលិខិតសរសើរពីក្រុមប្រឹក្សារដ្ឋមន្ត្រី ។

នៅឆ្នាំ១៩៩៧ គាត់បានទទួលពានរង្វាន់ពីសមាគមអ្នកនិពន្ធខ្មែរសម្រាប់ស្នាដៃរឿង "ឋានសួគ៌ក្នុងសុបិន" ។ នៅឆ្នាំ២០១០ គាត់បានទទួលពានរង្វាន់អក្សរសិល្ប៍ ទន្លេមេគង្គ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ សម្រាប់ស្នាដៃរឿង "ភ្នំព្រះនាងកែវ" ដែលជា កំណាព្យអក្សរសិល្ប៍ប្រវត្តិសាស្ត្រ ។ នៅឆ្នាំ២០១៣ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានជ្រើសរើសគាត់ជាជ័យលាភីប្រចាំប្រទេសកម្ពុជា នៅក្នុងមហោស្រពកវីអាស៊ាន នៅទីក្រុងបាងកក ប្រទេសថៃ ។ ក្រៅពីពានរង្វាន់ដូចដែលបានរៀបរាប់ខាងលើ គាត់បាននិពន្ធកំណាព្យ រឿងខ្លី និងអត្ថបទវប្បធម៌ជាង៣០ចំណងជើង ព្រមទាំងរៀបរៀងបោះពុម្ព សៀវភៅអក្សរភ្លេងបានមួយភាគ ។

បច្ចុប្បន្ន ទោះបីគាត់បានចូលនិវត្តហើយក៏ដោយ ក៏គាត់នៅតែបន្តចែករំលែកចំណេះដឹងផ្នែកតែងនិពន្ធដល់និស្សិតមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងនាមជាគ្រូបង្រៀនជាប់កិច្ចសន្យា ។ គាត់បានឲ្យដឹងថា "នរណាក៏អាចតែងនិពន្ធបានដែរ ប៉ុន្តែអ្វីដែលជាឧបសគ្គចម្បង គឺគំនិតបង្កើតថ្មី" ។

**រ៉េន ពិចិត្រ**

# ប្រសិនបើអំបិលផ្អែម ជីវិតនៅតែមានសង្ឃឹម

ស្ថិតក្នុងវ័យ៧៨ឆ្នាំ ហុក ហាក់ ដែលជាស្ត្រីមេម៉ាយម្នាក់ រស់នៅជាមួយកូនស្រី និងចៅៗជាច្រើននាក់ទៀត មានផ្ទៃមុខពោរពេញដោយស្នាមជ្រួញ លាយឡំជាមួយសក់ស្កូវព្រោង បាននិទានរឿងរ៉ាវឈឺចាប់ដែលគាត់លាក់ទុកក្នុងចិត្តជាមួយទឹកមុខស្រងូត ស្រងាត់ បាប្រប់មកកាន់ខ្ញុំថា៖ ប្ដីរបស់គាត់បានស្លាប់បាត់បង់ជីវិត កាលពីសម័យខ្មែរក្រហម ដោយសារខ្មែរក្រហមចោទប្ដីគាត់ថា បានលួចផ្ដល់បាយទៅឲ្យខ្មាំងហូប ។

ក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់កាប់អំណាច ហុក ហាក់ រស់នៅជួបជុំជាមួយប្ដី និងកូនៗរបស់គាត់ក្នុងភូមិគ្រាំងធ្នៃ ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ ទោះបីជាដូច្នេះក្ដី ភាគច្រើនគាត់មិនបានស្នាក់នៅផ្ទះក្រុមគ្រួសារនោះទេ ដោយសារគាត់ស្ថិត ក្នុងកងចល័ត ដែលត្រូវធ្វើការនៅការដ្ឋានសាងសង់ ហើយស្នាក់នៅទីនោះតែម្ដង ។ ហាក់ ត្រូវចាប់ផ្ដើមទៅធ្វើការតាំងពីព្រលឹមស្រាងៗរហូតដល់យប់ជ្រៅជារៀងរាល់ថ្ងៃ ។ ពេលថ្ងៃអង្គការតម្រូវឲ្យគាត់ធ្វើការក្នុងស្រែដូចជា ដក ស្ទូង ច្រូតកាត់ ធ្វើដីកំប៉ុសជាដើម ចំណែកពេលយប់វិញ គាត់ត្រូវជីកប្រឡាយ ហើយត្រូវដើរពីកន្លែងធ្វើការវិលត្រឡប់មកផ្ទះវិញជាមួយអ្នកឯទៀតក្នុងចម្ងាយប្រមាណ២០គីឡូម៉ែត្រ ។ ហាក់ បានបញ្ជាក់បន្ថែមថា “ខ្ញុំព្រួយបារម្ភខ្លាចគេយកសម្លាប់ចោល ជាពិសេសបន្ទាប់ពីខ្មែរក្រហមបានសម្លាប់ប្ដីរបស់ខ្ញុំ ។ ខ្ញុំកាន់តែមាន ការភិតភ័យថែមមួយកម្រិតទៀត នៅពេលដែលខ្ញុំដឹងច្បាស់ថា ខ្មែរក្រហមនឹងសម្លាប់ខ្ញុំចោល ។



យាយ ហាក់ ហុក កំពុងដាំបាយនៅផ្ទះរបស់គាត់ នៅភូមិគ្រាំងធ្នៃ ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។



អំបិលជាអាហារដ៏មានតម្លៃនៅក្នុងរបបខ្មែរក្រហម

ខ្ញុំមិនមានជំនឿទៅលើព្រះនោះទេ ខ្ញុំមិនជឿថាព្រះអាចជួយខ្ញុំបានទេនាពេលនោះ ។ ទោះបីជាពេលនោះខ្ញុំមិនជឿក៏ដោយ តែខ្ញុំនៅតែមានក្តីសង្ឃឹមក្នុងចិត្តជានិច្ចថា ថ្ងៃណាមួយនឹងមានមនុស្សមកជួយដើម្បីបញ្ចប់របបដ៏ឃោរឃៅមួយនេះ ។ លើសពីនេះទៀត ខ្ញុំសង្ឃឹមថា ខ្ញុំអាចមានបាយ និងអំបិលហូបគ្រប់គ្រាន់ ។

បើនិយាយពីសម័យកាលក្នុងរបបខ្មែរក្រហម បើមានអំបិលហូបនោះគឺវិសេសវិសាលណាស់ វាផ្អែម ផ្អែមដូចជាស្ករអ៊ីចឹង ។

ដោយសារភាពអត់ឃ្លាននេះហើយ ទើបធ្វើឲ្យ ហាក់ មិនខ្លាចអ្វីទាំងអស់ ។ ហាក់ បានបន្តថា «ពេលនោះ គាត់បានលួចរបស់ហូបជាច្រើនផង ដើម្បីចម្អែតក្រពះ គាត់លួចស្លូចត្រី លួចផ្លែល្ហុង ហើយលួចចាប់មាន់ស្ងោរហូបទៀតផង ។ គាត់ដឹងថា ប្រសិនបើខ្មែរក្រហមចាប់គាត់បាន ច្បាស់ជាខ្មែរក្រហមចងគាត់យកទៅសម្លាប់ចោលហើយ តែគាត់មិនខ្វល់នោះទេ ទោះត្រូវស្លាប់ក៏ដោយចុះ ឲ្យតែបានឆ្អែតក្រពះ គ្រាន់បើជាងស្លាប់ដោយអត់អីហូបដែរ» ។

សព្វថ្ងៃ ដោយសារ ហាក់ គោរពប្រតិបត្តិព្រះពុទ្ធសាសនា គាត់តែងតែទៅវត្ត និងបួងសួងសុំសេចក្តីសុខ និងសូមឲ្យជួបតែសំណាងនៅជាតិខាងមុខ ។ គាត់មិនចង់ជួបប្រទះការឈឺចាប់ ដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមដូចជាតិនេះទេ ។

**ប៉ោ គីមហុក**



យាយ ហាក់ ហុក ជាមួយនឹងចៅនៅភូមិក្រាំងធ្នុង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

# អតីតគ្រូរបាំបុរាណ និងចម្រៀង

នារសៀលថ្ងៃមួយ វេលាដែលមេឃក្តៅផង និងរកកលចង់ភ្លៀងផង ខ្ញុំ និងវណ្ណ វិរៈបុត្រ និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅជួបជាមួយអ្នកគ្រូ ស៊ិន សាម៉ាដឹកនូ ដែលជាអ្នកគ្រូរបាំបុរាណ និងចម្រៀងមួយរូប ។ សព្វថ្ងៃ អ្នកគ្រូមានអាយុ ៧៧ឆ្នាំ ។

នៅពេលដែលយើងទាំងពីរដើរទៅដល់ផ្ទះរបស់គាត់តាមផ្លូវតូចចង្អៀតមួយ អ្នកគ្រូកំពុងតែសម្រាកនៅលើកន្ទេល បានស្ទុះងើបទទួលរាក់ទាក់យើងទាំងពីរនាក់ដោយក្តីរីករាយ ។ អ្នកគ្រូបានសួរខ្ញុំទាំងពីរថា «ទៅណានាង?» បើយោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យ«នាង» ជាពាក្យមួយសម្រាប់និយាយទៅរកមនុស្សស្រី ឬ ប្រុស ដែលមានចំណាស់ថយជាងខ្លួនច្រើន ដោយដំណើរលំអុតលំឱន ឬសម្រាប់ហៅកូនប្រុសបង្កើត កូនស្រីបង្កើត ដោយលំអុត ។

យើងទាំងពីរនាក់បានលើកដៃជម្រាបសួរអ្នកគ្រូ និងបានជជែកលេងជាមួយអ្នកគ្រូ មួយសន្ទុះ អំពីសុខភាពរបស់គាត់ និងបង្ហាញគាត់នូវខ្សែអាត់សំឡេង ដែលអ្នកគ្រូបានច្រៀងជាមួយលោក ស៊ិន ស៊ីសាមុត ដូចជាបទ សៀងប៉ាក់គួយ ចិនចុះទូក និងបទចិនបាំងតាំងយូជាដើម ។ ភ្លាមៗនោះ អ្នកគ្រូបានច្រៀងបន្ទរពីក្រោយ បន្ទាប់ពីឮចម្រៀងចេញពី ទូរសព្ទដៃ ។ ទិដ្ឋភាពនេះហាក់ដូចជាបានរម្លឹកអ្នកគ្រូនូវរឿងរ៉ាវកាលពីពេលដែលគាត់ធ្លាប់ហាត់



រូបពីឆ្វេងទៅស្តាំ ៖ វណ្ណ វិរៈបុត្រ, ស៊ិន សាម៉ាដឹកនូ និងក្មួយស្រី នៅវត្តខណ្ឌាឡោម ក្រុងភ្នំពេញ

រៀនសិល្បៈ នៅក្នុងព្រះបរមរាជវាំងជាមួយសម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈនារីរ័ត្ន និងជាមួយម្តាយចិញ្ចឹមរបស់គាត់ឈ្មោះ ដឹកពារ ។

បន្ទាប់ពីបានសំណេះសំណាលជាមួយអ្នកគ្រូបានមួយស្របក់ យើងសង្កេតឃើញថា ការចងចាំរបស់គាត់ហាក់ដូចជាមិនសូវល្អនោះទេ ។ នេះប្រហែលមកពីវ័យជរារបស់គាត់ រីឯសុខភាពវិញក៏កាន់តែទ្រុឌទ្រោម ។ ប៉ុន្តែ អ្នកគ្រូនៅតែខំប្រឹងនិយាយមកកាន់យើងទាំងពីរ ។

អ្នកគ្រូ ដឹកឆូ កើតនៅឆ្នាំ១៩៤០ នៅរាជធានីភ្នំពេញ ។ ម្តាយបង្កើតរបស់អ្នកគ្រូ ឈ្មោះ ស៊ិន ម៉ៅ ។ ជាអកុសល អ្នកគ្រូមិនអាចចាំឈ្មោះឪពុកបង្កើតរបស់គាត់នោះឡើយ ។ អ្នកគ្រូគ្រាន់តែចាំបានថា ឪពុកបង្កើតរបស់គាត់គឺជាចៅកែស្រូវម្នាក់ ។ តាំងពីតូចក្រូចឆ្មារ មក ម្តាយចិញ្ចឹមរបស់អ្នកគ្រូ បានយកគាត់ទៅរស់នៅជាមួយនៅក្នុងព្រះបរមរាជវាំង ដើម្បីបានហាត់រៀនរបាំ និងសិល្បៈបុរាណ ។

នៅក្នុងព្រះបរមរាជវាំង អ្នកគ្រូហាត់របាំពេលព្រឹក និងរៀនអក្សរពេលល្ងាច ។ អ្នកគ្រូ ដឹកឆូ រំលឹកថា ដោយសារតែរូបរាងរបស់គាត់មិនសូវសោភា គ្រូរបស់គាត់បានចាត់តាំង ឲ្យគាត់ហាត់តួស្វា ។ លុះដល់អ្នកគ្រូមានវ័យចម្រើនធំឡើង គ្រូរបស់គាត់បានបង្គាប់ឲ្យគាត់ ហាត់តួយក្ស បន្ទាប់មក តួឆោះ ។ អ្នកគ្រូ ដឹកឆូ ដឹងថា ដោយសារតែរូបសម្រស់របស់ខ្លួន មិនសូវគាប់ប្រសើរ អ្នកគ្រូមិនសូវបានគ្រូរបាំផ្សេងៗចាប់អារម្មណ៍ខ្លាំងនោះទេ ។ ប៉ុន្តែ អ្នកគ្រូជាសិស្សខស្សាហ៍ព្យាយាមមួយរូប ហេតុដូច្នេះ អ្នកគ្រូបានប្រឹងប្រែងលួចហាត់រៀន ចំណេះសិល្បៈផ្សេងៗពីគ្រូដទៃនៅខាងក្រៅថ្នាក់រៀន ដើម្បីបង្កើនចំណេះដឹងខ្លួនឯងផង និងដើម្បីពង្រឹងសមត្ថភាពខ្លួនឯងផង ។ រៀងរាល់ព្រឹកវេលាម៉ោង៤ទៀបភ្លឺ អ្នកគ្រូតែងតែ ក្រោកពីដំណេក ដើម្បីហ៊ឹកហាត់គ្រវីដងបង ។ អ្នកគ្រូមិនហ៊ានគ្រវី នៅលើឥដ្ឋឡើយ ដោយសារតែអ្នកគ្រូខ្លាចរំខានដល់សិស្សដទៃ ។ អ្នកគ្រូហាត់គ្រវីនៅលើស្មៅដែលមានដក់ទឹកសន្សើម នៅពេលព្រឹក បានធ្វើឲ្យសំលៀកបំពាក់របស់អ្នកគ្រូទទឹកជោគ ។ បន្ទាប់ពីហ៊ឹកហាត់រួច អ្នកគ្រូបានចូលទៅសម្រាកវិញ ទម្រាំដល់ម៉ោងរៀន ។ អ្នកគ្រូប្រឹងប្រែងបំប៉នខ្លួនឯងរហូត បានក្លាយជាសិស្សដែលពូកែគ្រវីដងបងជាងគេ ។ អ្នកគ្រូបានបង្ហើបថា ការហាត់សិល្បៈបុរាណតម្រូវឲ្យចេះចាំក្បួនខ្នាត និងក្បាច់បាតជាដើម ឲ្យបានច្បាស់លាស់ សូម្បីតែកាយវិការនីមួយៗក៏មានអត្ថន័យផ្ទាល់ខ្លួនដែរ ។ ឧទាហរណ៍ កាយវិការសើចមានច្រើនបែប កាយវិការសើចបែបសប្បាយចិត្ត ញញឹម ឬអស់សំណើច ។ កាយវិការទាំងអស់តម្រូវឲ្យសិស្សរៀន ។ អ្នកគ្រូរំពឹងថា នៅថ្ងៃអនាគតគាត់នឹងអាចក្លាយជាគ្រូសិល្បៈមួយរូប ។

អ្នកគ្រូបង្ហាញទឹកមុខសប្បាយរីករាយ នៅពេលរំលឹកដល់អនុស្សាវរីយ៍ទាំងឡាយ ដែលមាននៅក្នុងព្រះបរមរាជវាំង ។ អ្នកគ្រូមានមិត្តជិតដិតមួយរូប គឺលោក សុះ ម៉ាត់ ។ រីឯ លោក ស៊ិន ស៊ីសាមុត វិញ អ្នកគ្រូហៅគាត់ថា«បង» ដោយសារតែគាត់មានអាយុច្រើនជាង ។ ក្នុងនាមជាមិត្តនឹងគ្នា លោក សុះ ម៉ាត់ និងអ្នកគ្រូតែងតែជួយគ្នាទៅវិញទៅមក គ្រាមានបញ្ហាលំបាកផ្សេងៗ ពោលគឺ អ្នកទាំងពីរចេះយកអសារគ្នាទៅវិញទៅមក ។ ទន្ទឹមនឹងនោះ អ្នកគ្រូបានច្រៀងបទមហោរីមួយចំនួនជាមួយលោក ស៊ិន ស៊ីសាមុត ដូចជាបទ សៀងប៉ាក់គួយ ចិនចុះទុក និង ចិនបាំងតាំងយូជាដើម ។

ជាអកុសល អនុស្សាវរីយ៍ល្អៗស្ថិតនៅមិនបានយូរទេ រដ្ឋប្រហារទម្លាក់សម្តេចព្រះបាទ នរោត្តម សីហនុ ក៏បានផ្ទុះឡើងនៅឆ្នាំ១៩៧០ ។ បើទោះបីជាអ្នកគ្រូនៅបន្តហាត់សិល្បៈនៅដំណាក់ចន្ទឆាយាក្នុងព្រះបរមរាជវាំងក៏ដោយ ក៏អ្នកគ្រូលែងបានស្នាក់នៅក្នុងវាំងទៀតហើយ ។ អ្នកគ្រូបានទៅរស់នៅជាមួយម្តាយនៅក្បែរដំណាក់ទក្សិណាភិរម្យ ។

នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចនៅឆ្នាំ១៩៧៥ អ្នកគ្រូត្រូវបានខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញ ។ អ្នកគ្រូបានយកគ្រឿងអលង្ការតាមខ្លួនមួយចំនួន ដោយនឹកគិតថាបីថ្ងៃក្រោយនឹងបានត្រឡប់ចូលទីក្រុងវិញ ។ នៅតាមផ្លូវធ្វើដំណើរ អ្នកគ្រូបានវង្វេងបាត់ម្តាយ និងគ្រួសារ ដោយសារតែខ្មែរក្រហមចេះតែរុញប្រជាជនឲ្យបន្តដំណើរទៅមុខ ។ ជាងនេះទៅទៀត អ្នកគ្រូបានបែកពីប្តីរបស់គាត់ ដែលជាមន្ត្រីយោធាមួយរូប នៅពេលគាត់កំពុងធ្វើការ ។ អ្នកគ្រូមិនដឹងថា ប្តីរបស់គាត់ត្រូវបានបញ្ជូនទៅណានោះទេ ។ អ្នកគ្រូគិតថា ដោយសារតែកុសលផលបុណ្យរបស់

គាត់ នៅតាមផ្លូវ អ្នកដំណើរដូចគ្នា តែងតែលួចខ្សឹបប្រាប់គាត់កុំឲ្យនិយាយប្រាប់ត្រង់ ប្រសិនបើខ្មែរក្រហមសួរនាំប្រវត្តិរូបរបស់គាត់ ។ មិនតែប៉ុណ្ណោះ គាត់ត្រូវបានណែនាំឲ្យរក្សាចម្លើយដែលគាត់ឆ្លើយប្រាប់ខ្មែរក្រហម ។ គាត់ឆ្លើយប្រាប់ខ្មែរក្រហមថា ប្តីរបស់គាត់ជាអ្នកលាយបាយជ្រូកនៅព្រែកលាប ចំណែកឯរូបគាត់វិញជាអ្នកសម្តែងល្ខោនបាសាក់ ។

អ្នកគ្រូបានធ្វើដំណើរដល់ភូមិរំដួល ឃុំគោករំដួល ខេត្តកំពង់ធំ ។ នៅទីនោះ ខ្មែរក្រហមបានចាត់តាំងឲ្យគាត់ធ្វើការផារស្រែចម្ការ ។ អ្នកគ្រូជាមនុស្សម្នាក់ ដែលខ្លាចសត្វឈ្លើង ។ នៅពេលដែលសត្វឈ្លើងតោងជើងគាត់ម្តងៗ គាត់រត់ចុះឡើងរកជំនួយ ។ ជួនកាលអ្នកគ្រូបានជួបអ្នកធ្លាប់ហាត់សិល្បៈជាមួយគ្នានៅក្នុងសហករណ៍ ។ ប៉ុន្តែ អ្នកគ្រូ មិនបាននិយាយគ្នាច្រើននោះទេ គ្រាន់តែសួរនាំគ្នាបន្តិចបន្តួច ក៏បែកទៅធ្វើការរៀងៗខ្លួន វិញ ។ អ្នកគ្រូបានរៀបរាប់ថា របបអាហារមិនគ្រប់គ្រាន់ទេ បបរមួយកំប៉ុងសម្រាប់គ្នារាប់សិបនាក់ ហេតុដូច្នេះ នៅពេលសម្រាកពីការផារ អ្នកគ្រូបានទៅលួចដឹកត្រពាំង ដំឡូង យកមកហូប ដើម្បីទ្រទ្រង់ជីវិត ។ នៅពេលនោះ អ្នកគ្រូមិនបានភិតភ័យថានឹងអាចមានសត្វពស់មកចឹកទេ ឲ្យតែបានឆ្អែត ។ ជាងនេះទៅទៀត អ្នកគ្រូមិនហ៊ានដើរទៅណាផ្តេសផ្តាសនោះទេ  ដោយសារតែខ្លាចខ្មែរក្រហមចោទប្រកាន់ថាលួចរត់នោះ ខ្មែរក្រហមនឹងចាប់យកទៅសម្លាប់ចោល ។ អ្នកគ្រូធ្លាប់ឮថា ប្រជាជនមួយចំនួនត្រូវបានខ្មែរក្រហមសម្លាប់ ត្បិតប្រជាជនទាំងនោះលួចរត់ចេញពីសហករណ៍ ។

នៅឆ្នាំ១៩៧៩ នៅពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ អ្នកគ្រូ ដឹកឆ្ងូ បានធ្វើដំណើរត្រឡប់មកទីក្រុងភ្នំពេញវិញ ។ ប៉ុន្តែផ្ទះដែលគាត់ធ្លាប់រស់នៅមុនរបបខ្មែរក្រហម ត្រូវបានប្រជាជនដទៃចូលទៅរស់នៅ ។ បច្ចុប្បន្នអ្នកគ្រូរស់នៅជាមួយក្មួយស្រីមួយរូប ។ រីឯប្តីរបស់គាត់នៅតែបាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ **ម៉ែន ពិចិត្រ**

# ដំណឹងស្វែងរកពូ និងមីង



នាងខ្ញុំឈ្មោះ កប ដាវី ជាកូនរបស់លោកឪពុកឈ្មោះ ពៅ កប ។ ឪពុកខ្ញុំកើតនៅឆ្នាំ១៩៣០ នៅភូមិសូសិតក្រោម ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ។ គាត់មានឪពុកឈ្មោះ ពៅ កាន់ និងម្តាយឈ្មោះ អ៊ុំ ឆិន ។

ឪពុកខ្ញុំ ពៅ កប បានចូលរួមក្នុងចលនាខ្មែរឥស្សរៈនៅជំនាន់អាណានិគមនិយមបារាំង ។ ក្រោយមក គាត់បានទៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

នៅឆ្នាំ១៩៥៤ គាត់បានរៀបការជាមួយប្រពន្ធជនជាតិវៀតណាម និងមានកូនស្រីពីរនាក់ ។ នៅឆ្នាំ១៩៧០ គាត់បានចូលមកកម្ពុជាវិញ ដើម្បីវាយប្រឆាំងនឹងអាមេរិក ហើយក្រោយមកទៀត ខ្ញុំគ្រាន់តែដឹងថា គាត់ត្រូវបានខ្មែរក្រហមសម្លាប់ ។

ជាចុងក្រោយ ខ្ញុំគ្រាន់តែដឹងថា ឪពុករបស់ខ្ញុំមានប្អូនប្រុសឈ្មោះ ពៅ ហ៊ុន និងប្អូនស្រីឈ្មោះ ពៅ ហ៊ម ។ សព្វថ្ងៃ ខ្ញុំនៅតែចង់ជួប និងសង្ឃឹមថា ពូមីង នឹងបានឃើញខ្ញុំ ហើយអាចមករកខ្ញុំ (ក្មួយ) នៅមន្ទីរពេទ្យធំ (ព្រះកេតុមាលា) ព្រោះសព្វថ្ងៃខ្ញុំជាគ្រូពេទ្យមធ្យមនៅមន្ទីរពេទ្យនេះ ។ **ពីក្មួយ កប ដាវី**

# ទោះជាក្មេងកំព្រាក៏នៅតែពុះពារ

កាលពីខែកក្កដាកន្លងមក អ្នកគ្រូ ស្វាយ សោម៉ា បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលសាស្ត្រាចារ្យសាកលវិទ្យាល័យ ស្ដីអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកគ្រូយល់ឃើញថា វគ្គបណ្ដុះបណ្ដាលបានផ្ដល់ឱកាសដ៏កម្រ



អ្នកគ្រូ សោ ម៉ា ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីវិធីសាស្ត្របង្រៀន ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា កាលពីខែសីហា ឆ្នាំ២០១៧

មួយដល់គាត់ ដើម្បីទទួលបាននូវចំណេះដឹងបន្ថែមអំពីរបបខ្មែរក្រហម តាមរយៈបទបង្ហាញរបស់សាស្ត្រាចារ្យ វាគ្មិន លោកគ្រូ-អ្នកគ្រូ និងសិក្ខាកាមដទៃទៀតដែលធ្វើដំណើរមកពីខេត្តផ្សេងៗ ។ សោម៉ា ជាកូនកំព្រា បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្ដួលរំលំនៅឆ្នាំ១៩៧៩ ។ ឪពុក និងបងស្រីរបស់គាត់ត្រូវបានខ្មែរក្រហមសម្លាប់ ។ ចំណែកម្ដាយរបស់គាត់បានកើតពិសនៅក្នុងរបបខ្មែរក្រហម ហើយបានស្លាប់មួយឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមបានបញ្ចប់ ។ បើទោះបីជា សោម៉ា បានបាត់បង់សមាជិកនៅក្នុងក្រុមគ្រួសារអស់ក៏ដោយ ក៏គាត់នៅតែប្រឹងប្រែងពុះពារតស៊ូរៀនសូត្ររហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបានក្លាយជាគ្រូមុខវិជ្ជាសីលធម៌-ពលរដ្ឋ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ។ ប្ដីរបស់អ្នកគ្រូឈ្មោះ វ៉ែន ប្រណី ជាអនុប្រធានមន្ទីរអប់រំខេត្តព្រៃវែង ។ បច្ចុប្បន្ន សោម៉ា មានកូនស្រីពីរនាក់ ដែលកូនស្រីច្បងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងកំពុងធ្វើការងារនៅក្នុងអង្គការក្រៅរដ្ឋាភិបាល ។ ចំណែកកូនស្រីពៅរបស់គាត់កំពុងសិក្សានៅវិទ្យាល័យ ។ សោម៉ា បានបញ្ជាក់ប្រាប់ថា ទម្រាំតែគាត់ទទួលបាននូវអ្វីដែលគាត់មានសព្វថ្ងៃ គាត់បានឆ្លងខបសគ្គទាំងនៅក្នុងរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហម ។

សោម៉ា បានរំឭកពីជីវិតរបស់គាត់ដូចតទៅ ៖ គាត់កើតនៅឆ្នាំ១៩៧១ នៅភូមិទន្លេបាទី ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ។ ឪពុករបស់គាត់ឈ្មោះ ស្វាយ ធុច ជាអតីតបុគ្គលិកបម្រើការនៅព្រលានយន្តហោះ ។ ម្ដាយរបស់គាត់ឈ្មោះ ឡុង លៀច ។ គាត់ជាកូនពៅ នៅក្នុងចំណោមបងប្អូនបីនាក់ ។

មុនរបបខ្មែរក្រហមចូលមកដល់ បងប្រុសច្បងរបស់ សោម៉ា បានស្លាប់ដោយលង់ទឹក ។ នៅពេលនោះ សោម៉ា មិនបានចូលរៀនទេ ព្រោះគាត់នៅក្មេងនៅឡើយ ម្យ៉ាងទៀតប្រទេសជាតិកំពុងកើតសង្គ្រាមស៊ីវិល ។

នៅពេលដែលក្រុមកុម្មុយនីស្ដខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ ឪពុករបស់គាត់បានសម្រេចចិត្តធ្វើដំណើរជាមួយយាយតាសំដៅទៅខេត្តឧត្ដរមានជ័យ ។ នៅទីនោះ

ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅក្នុងកងបុរស ។ ម្តាយធ្វើការនៅក្នុងកងនារី ។ បងស្រីរបស់គាត់ធ្វើការនៅក្នុងកងចល័តនារី ។ ចំណែកគាត់អង្គការតម្រូវឲ្យរស់នៅក្នុងកងកុមារ ដើររើសអាចម៍គោ និងកាប់ដើមទន្ទ្រានខែត្រដើម្បីយកមកធ្វើជី ។

នៅឆ្នាំ១៩៧៧ ឪពុករបស់គាត់បានកើតជំងឺគ្រុនចាញ់ បន្ទាប់ពីគាត់ទៅព្រៃកាប់បង្គោល ។ មិនយូរប៉ុន្មាន ឪពុករបស់គាត់បានស្លាប់ដោយសារតែគ្មានថ្នាំសង្កូវសម្រាប់ព្យាបាល ។ នារាត្រីមួយបន្ទាប់ពីឪពុករបស់គាត់ស្លាប់ គាត់បានលួចរត់ទៅជួបម្តាយនៅផ្ទះ ព្រោះនឹកម្តាយខ្លាំងពេក ។ ម្តាយរបស់គាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលឃើញគាត់ ។ ម្តាយរបស់គាត់បានប្រាប់គាត់លាយឡំជាមួយក្តីបារម្ភថា “គាត់មិនគួររត់មកផ្ទះទេ ព្រោះខ្មែរក្រហមអាចនឹងចាប់គាត់យកទៅពិន័យ” តែសំណាងល្អខ្មែរក្រហមមិនដឹង ។

បន្ទាប់មក បងស្រីរបស់គាត់បានលួចរត់ចេញពីកង នៅពេលដែលកងរបស់បងស្រីគាត់ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅតំបន់ផ្សេង ។ ខ្មែរក្រហមបានតាមរកបងស្រីរបស់គាត់ ហើយចាប់បានបងស្រីរបស់គាត់យកទៅ ។ តាំងពីពេលនោះមក គាត់មិនដែលបានឃើញបងស្រីរបស់ទៀតទេ ។ សោម៉ា គិតថា បងស្រីរបស់គាត់ប្រហែលជាត្រូវបានខ្មែរក្រហមយកទៅសម្លាប់ហើយ ។ សេចក្តីសោកសង្រេង បានធ្វើឲ្យម្តាយរបស់គាត់ទប់ស្មារតីលែងបាន ។ ម្តាយរបស់គាត់បានស្រែកយំ និងជេរប្រមាថខ្មែរក្រហមដែលបានចាប់បងស្រីរបស់ សោម៉ា ។ ប៉ុន្តែ ខ្មែរក្រហមមិនបានចាប់ម្តាយរបស់គាត់យកទៅធ្វើទារុណកម្មទេពេលនោះ ។

ថ្ងៃមួយនារដូវស្រូវទុំ ឆ្នាំ១៩៧៨ សោម៉ា ត្រូវបានខ្មែរក្រហមចាប់ខ្លួន បន្ទាប់ពីគាត់បានលួចបូតស្រូវដាក់នៅចង្កេះខោ ។ ខ្មែរក្រហមបានចងគាត់ផ្អោបទៅនឹងដើមឈើមួយដើមដែលមានសុទ្ធតែសំបុកអង្ក្រង ដើម្បីឲ្យអង្ក្រងខាំគាត់ ។ លុះដល់ថ្ងៃត្រង់ ខ្មែរក្រហមបានស្រាយចំណង និងបានអនុញ្ញាតឲ្យគាត់ហូបបបរ ។ នៅពេលនោះ គាត់បានសម្រេចចិត្តរត់ត្រឡប់ទៅផ្ទះវិញ ។ ប៉ុន្តែ ម្តាយរបស់គាត់មិននៅផ្ទះទេ ។ ម្តាយរបស់គាត់កំពុងប្រូតស្រូវនៅវាលស្រែ ។ ខ្មែរក្រហមបានដេញតាម ព្រមទាំងបានឡើងទៅលើផ្ទះដើម្បីស្វែងរកគាត់ ។ សោម៉ា បាននិយាយថា ដោយសារតែអាយុរបស់គាត់មិនទាន់អស់ នៅពេលដែលខ្មែរក្រហមបើកទ្វារក៏បាំងខ្លួនគាត់ដែលនៅកន្លៀតទ្វារធ្វើឲ្យខ្មែរក្រហមមើលគាត់មិនឃើញ ។ ភ្លានោះ ខ្មែរក្រហមក៏ត្រឡប់ទៅវិញ ។ សោម៉ា បានសម្ងំនៅលើផ្ទះតែម្នាក់ឯងរហូតម្តាយរបស់គាត់ត្រឡប់មកពីស្រែ ។ ម្តាយរបស់គាត់បានយំលួងលោមគាត់ ព្រមទាំងបានណែនាំគាត់កុំឲ្យលួចរបស់អង្គការទៀត ។ ម្តាយរបស់គាត់ខ្លាចគាត់គេចមិនផុតពីសេចក្តីស្លាប់ ប្រសិនបើគាត់នៅតែបន្តលួច ។

នៅចុងឆ្នាំ១៩៧៨ ម្តាយរបស់ សោម៉ា បានមុតបន្លាផ្ទី បណ្តាលឲ្យកើតជំងឺពិសដើរពុំរួច ។ រហូតដល់ពេលដែលកងទ័ពរំដោះបានចូលមករំដោះនៅដើមឆ្នាំ១៩៧៩ ពូខាងឪពុករបស់ សោម៉ា បានជួយរុញរទេះដែលម្តាយរបស់គាត់ជិះពីខេត្តឧត្តរមានជ័យ ត្រឡប់មកស្រុកកំណើតនៅខេត្តតាកែវវិញ ដោយពេលនោះម្តាយរបស់គាត់បានយកធាតុឪពុកដាក់ក្នុងហោប៉ៅអាវមកជាមួយដែរ ។ ជំងឺពិសរបស់ម្តាយគាត់មិនបានជាសះស្បើយឡើយ ។ សោម៉ា បានបញ្ជូនម្តាយរបស់គាត់ទៅព្យាបាលជំងឺនៅអតីតមន្ទីរពេទ្យចិន ទល់មុខវិទ្យាល័យព្រះយុគន្ធរ ។ សោម៉ា បានរំឭកថា នៅពេលនោះ ទីធ្លានៅខាងក្រោយពេទ្យចិនពោរពេញទៅដោយផ្នូរខ្មោច និងដើមអំពៅ ។ ជាអកុសល នៅឆ្នាំ១៩៨០ ម្តាយអ្នកគ្រូបានស្លាប់បាត់បង់ជីវិត ដោយសារតែគាត់ពុំមានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយទៅលើថ្នាំពេទ្យដែលមានតម្លៃថ្លៃ ។

បន្ទាប់ពីម្តាយរបស់គាត់ស្លាប់ទៅ សោម៉ា បានរស់នៅជាមួយបងស្រីជីដូនមួយរបស់គាត់ឈ្មោះ ព្រំ សារី ដែលបានស្លាប់នៅឆ្នាំ២០០៨ ។ គាត់បានចូលរៀនថ្នាក់ទីមួយ និងបានចូលរៀនបន្តថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅឆ្នាំ១៩៨៩ ។ នៅពេលដែលគាត់រៀននៅទីក្រុងភ្នំពេញ គាត់បានជួបប្រទះនូវបញ្ហាជីវភាពខ្វះខាតជារឿយៗ ។ ពេលខ្លះ គាត់ចង់បោះបង់ចោលការសិក្សារបស់គាត់ ដ្បិតគាត់ពុំមានថវិកាដើម្បីទ្រទ្រង់ក្នុងការសិក្សា ។ ប៉ុន្តែ សាច់ញាតិរបស់គាត់បានជួយផ្គត់ផ្គង់ រហូតដល់គាត់បានបញ្ចប់ការសិក្សាដោយជោគជ័យ ។ សោម៉ា បានបន្តថា នៅក្នុងភាពជោគជ័យនោះ ប្តីរបស់គាត់ក៏បានចូលរួមចំណែកដែរ ដែលបានជួយលើកទឹកចិត្តគាត់ឲ្យខំប្រឹងប្រែង ។

អនុស្សាវរីយ៍ជាច្រើនរវាងគាត់ និងប្តីរបស់គាត់បានបន្សល់ទុកមករហូតដល់សព្វថ្ងៃដែលអ្នកគ្រូមិនធ្លាប់បានបំភ្លេច ។

នៅឆ្នាំ១៩៩៣ បន្ទាប់ពីគាត់បញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ គាត់បានក្លាយជាគ្រូបង្រៀននៅវិទ្យាល័យត្បូងឃ្មុំ អតីតខេត្តកំពង់ចាម ។ ពីរឆ្នាំក្រោយមក គាត់បានផ្លាស់ទៅបង្រៀននៅវិទ្យាល័យព្រះអង្គឌួង ខេត្តព្រៃវែង បន្ទាប់ពីគាត់បានរៀបការ ។ នៅឆ្នាំ២០០៥ សោម៉ា បានប្តូរទៅបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋ ដល់គរុសិស្សនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ។

ក្រៅពីបង្រៀនសិស្ស សោម៉ា ធ្លាប់បានទៅចូលរួមស្តាប់សវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួនពីរដង ។ គាត់មិនសប្បាយចិត្តទេ នៅពេលដែលគាត់បានស្តាប់ឮមេដឹកនាំខ្មែរក្រហមបដិសេធការទទួលខុសត្រូវរបស់ខ្លួនចំពោះសោកនាដកម្ម ដែលបានកើតឡើង ។ មិនតែប៉ុណ្ណោះ គរុសិស្សរបស់គាត់មួយចំនួនបានថ្លែងប្រាប់ថា រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមហាក់ដូចជាឃោរឃៅដែលពិបាកនឹងជឿថាអាចកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ សោម៉ា បានសម្តែងការព្រួយបារម្ភនៅពេលដែលស្តាប់ឮសិស្សរបស់គាត់និយាយដូច្នេះ ។ គាត់បានប្រាប់ថា ដោយសារតែយុវជនជំនាន់ក្រោយកើតមិនទាន់របបខ្មែរក្រហម ហេតុដូច្នេះភារកិច្ចមួយរបស់អ្នករស់រានមានជីវិត ត្រូវធ្វើគឺបន្តចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនដល់កូនចៅ ដើម្បីយុវជនជំនាន់ក្រោយបានស្វែងយល់បន្ថែមនៅខាងក្រៅថ្នាក់រៀន ។ ជារឿយៗ អ្នកគ្រូតែងតែដំណាលប្រាប់កូនៗរបស់គាត់ អំពីបទពិសោធន៍ដែលគាត់ធ្លាប់ជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។ សោម៉ា ជឿជាក់ថា ការនិយាយ ប្រាប់អំពីរឿងរ៉ាវឃោរឃៅកាលពីអតីតកាល គឺជាមធ្យោបាយមួយក្នុងការទប់ស្កាត់អំពើឃោរឃៅទាំងឡាយមិនឲ្យកើតឡើងសាជាថ្មីម្តងទៀត ។

**ម៉ែន ពិចិត្រ**



រូបកណ្តាល ៖ អ្នកគ្រូ សោ ម៉ា បានផ្តល់បទសម្ភាសន៍ដល់ ម៉ែន ពិចិត្រ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា កាលពីខែសីហា ឆ្នាំ២០១៧

# ឆ្លងត្រីកញ្ហុះ

គិម ផាន់ ជានាយិការងនៃវិទ្យាល័យ ហ៊ុន សែន អង្គរធំ ។ ផាន់ កើតនៅក្នុងឆ្នាំ១៩៧០ នៅភូមិព្រៃធ្លក ឃុំខ្នាត់ ស្រុកពួក ខេត្តសៀមរាប នៅក្នុងគ្រួសារអ្នកស្រែចម្ការ ។ ផាន់ គឺជាកូនទី២ ក្នុងចំណោមបងប្អូនចំនួន៦នាក់ ។ ផាន់ មានម្តាយឈ្មោះ កង សៀត រីឯឪពុកឈ្មោះ គិម អ៊ាក ។

គិម ផាន់ មានអាយុ៥ឆ្នាំនៅពេលដែលយោធាខ្មែរក្រហមបានចូលមកដល់ភូមិរបស់គាត់ ។ ផាន់ បានចងចាំរឿងរ៉ាវជាច្រើនដែលបានកើតឡើងក្នុងរបបខ្មែរក្រហមថា ក្នុងអំឡុងឆ្នាំ១៩៧៥ គាត់នៅក្នុងផ្ទះជាមួយគ្រួសារ ។ គាត់បានឃើញមនុស្សមួយក្រុមស្លៀកពាក់ខ្មៅដើរកាត់តាមមាត់ស្ទឹងជិតផ្ទះរបស់គាត់ ។ ក្រោយមកទើបគាត់បានដឹងថាក្រុមនោះ គឺជាក្រុមខ្មែរក្រហម ។ នៅថ្ងៃដំបូងបន្ទាប់ពីខ្មែរក្រហមបានចូលមកដល់ក្នុងភូមិ ខ្មែរក្រហមបានប្រមូលគ្រឿង ឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់របស់អ្នកភូមិទាំងអស់ មានដូចជា ចាន ឆ្នាំង ស្លាបព្រា និង វែក ដាក់នៅកន្លែងមួយសម្រាប់ប្រើប្រាស់ជាសមូហភាព ។ នៅថ្ងៃនោះ គ្រួសាររបស់ ផាន់ មិនមានអង្ករ ឬម្ហូបសម្រាប់បរិភោគទេ ។ គ្រួសាររបស់ ផាន់ បានទៅដកដំឡូងឈើដែលនៅឆ្ងាយពីផ្ទះ យកមកស្ងោរហូបដើម្បីបំពេញនូវសេចក្តីស្រេកឃ្លាន ។ បន្ទាប់ពីបរិភោគដំឡូងជំនួសអាហារពេលល្ងាចរួចមក គ្រួសាររបស់គាត់បានពុលដំឡូងនោះទាំងអស់គ្នា បណ្តាលឲ្យអាការក្តៅខ្លួនខ្លាំង ។ មួយរយៈក្រោយមក សមាជិកគ្រួសាររបស់ ផាន់ ក៏បានធូរស្រាលវិញ ។



អ្នកគ្រូ គិម ផាន់ និង យាង សេងហៀង និស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា ថតនៅមុខទីចាត់ការវិទ្យាល័យ ហ៊ុន សែន នគរធំ ខេត្តសៀមរាប ។

ពីរបីថ្ងៃក្រោយមក អង្គការ បានដាក់ការងារឲ្យប្រជាជនគ្រប់ៗគ្នាធ្វើ ។ សមាជិកនៅក្នុងគ្រួសាររបស់ ផាន់ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការងារផ្សេងៗ ដូចជា ឪពុករបស់ ផាន់ ត្រូវដឹកខុស និងឲ្យទៅលើកទំនប់នៅការដ្ឋានឆ្ងាយៗ បងប្រុសរបស់ផាន់ តម្រូវឲ្យទៅភ្ជួរស្រែ ហើយម្តាយរបស់ ផាន់ ធ្វើការងារនៅកងផ្សេង ។ ចំណែកឯ ផាន់ និងកុមារដទៃទៀត ត្រូវបានអង្គការចាត់តាំងឲ្យសែងលាមកមនុស្ស ដឹកដីដំបូក និងកាត់ដើមទន្ទ្រានខែត្រដាក់ក្នុងរណ្តៅដើម្បីលាយធ្វើជាជី ។ សមាជិកកងទាំងអស់ត្រូវធ្វើការតាំងពីព្រលឹមទល់ព្រលប់ទើបបានវិលទៅជួបជុំគ្រួសារវិញ ។

រៀងរាល់ថ្ងៃមុនពេលហូបអាហារថ្ងៃត្រង់ អង្គការតម្រូវឲ្យ ផាន់ និងកុមារផ្សេងទៀត រៀនអក្សរ និងច្រៀងចម្រៀងបដិវត្តន៍ ។ លុះដល់រដូវប្រមូលផល? កាត់ កងកុមាររបស់ ផាន់ ត្រូវបានអង្គការចាត់តាំងឲ្យដើររើសកួរស្រូវនៅតាមវាលស្រែបន្ថែមលើការងារ

ដែលធ្វើរាល់ថ្ងៃ ។ អង្គការបានបង្ខំប្រជាជនឲ្យធ្វើការងារធ្ងន់ និង មិនមានពេលវេលាសម្រាកទេ ។ ពុំមាននរណាម្នាក់ហ៊ានប្រឆាំង ឬមិនស្តាប់បញ្ជារបស់អង្គការឡើយ ។ ជាអកុសល ម្តាយរបស់ ដាន់ បានរលូតកូននៅក្នុងផ្ទៃ ដោយសារតែធ្វើការងារធ្ងន់ហួសកម្លាំង ។

ដាន់ បានរំឭកថា នៅក្នុងរបបខ្មែរក្រហម គាត់ហូប និង សម្រាកមិនបានគ្រប់គ្រាន់ទេ ។ អង្គការបានចែកបបរម្នាក់មួយចាន ដែលមានបរិមាណដ៏តិចតួច ដូច្នេះ គាត់ក៏បានយកចានដែលហូបរួចទៅលាងឲ្យជ្រះ ដើម្បីបន្តទៅយកបបរម្តងទៀត ។ ដាន់ បានបន្តពីរបីដង ។ ក្រោយមក អ្នកដួសបបរបានដឹងពីល្បិចរបស់ ដាន់ ហើយបានគំរាមគាត់ឲ្យបញ្ឈប់ទង្វើនោះទៀត បើមិនដូច្នេះទេ នឹងត្រូវទទួលរងការដាក់ទោសទណ្ឌជាមិនខាន ។

ថ្ងៃមួយ មែកឈើបានធ្លាក់លើ ដាន់ បណ្តាលឲ្យគាត់បែកក្បាល ។ ដាន់ មិនបានទៅធ្វើការងារទេ ។ លុះដល់យប់ឡើង ម្តាយ និងបងរបស់ ដាន់ បានលួចទៅបេះបន្លែមកធ្វើម្ហូបឲ្យ ដាន់ ហូប ព្រោះ ដាន់ ឃ្លានខ្លាំងណាស់ ។ ដាន់ បានបញ្ជាក់ថា ការលួចធ្វើម្ហូប នៅក្នុងរបបខ្មែរក្រហម ត្រូវបិទបាំងកុំឲ្យមានផ្សែង ឬភ្លើងចេញទៅក្រៅដើម្បីជៀសវាងកងឈ្លបឃើញ ។ ប៉ុន្តែ នៅពេលដែល កំពុងហូប កងឈ្លបបានមកទាន់ ។ កងឈ្លបបានទាត់ម្ហូបអាហារកំពប់អស់ ព្រមទាំងបានចាប់ ដាន់ ទៅសួរនាំ ។ សំណាងល្អ កងឈ្លបមិនបានវាយធ្វើបាប ដាន់ តែបានព្រមាន ដាន់ កុំឲ្យធ្វើដូច្នេះទៀត នៅថ្ងៃក្រោយ ។

រឿងមួយដែល ដាន់ បងចាំមិនភ្លេច គឺការស្លាប់របស់បងប្រុស ដែលបណ្តាលមកពីការស្លាក់ធុងត្រីកញ្ចុះ ។ ដាន់ បានរៀបរាប់ថា បងប្រុសរបស់គាត់មានមាឌធំ និងហូបច្រើន ។ រៀងរាល់ថ្ងៃ បងប្រុសរបស់គាត់មិនដែលហូបឆ្អែតទេ ។ ល្ងាចថ្ងៃមួយ បងប្រុសរបស់គាត់ បានលួចចាប់ត្រីកញ្ចុះយកមកដុតហូប បន្ទាប់ពីត្រឡប់មកពីភ្ជួរស្រែវិញ ។ នៅពេលដុតត្រី បងប្រុសរបស់គាត់មិនបានសម្អាតត្រីឲ្យស្អាតនោះទេ គឺគាត់យកត្រីទៅដុតទាំងធុង ។ បន្ទាប់ពីត្រីឆ្អិន គាត់បានយកត្រីមកហូប ។ រំពេចនោះ ស្រាប់តែគាត់ឮស្នូរជើងមនុស្សដើរមក បងប្រុសរបស់ ដាន់ គិតថាជាកងឈ្លប ។ ដោយសារភ័យខ្លាំងពេក បងប្រុសគាត់បានហូបត្រីទាំង មូលបណ្តាលឲ្យគាត់ស្លាក់ធុងត្រីកញ្ចុះ ។ ពេលនោះ ម្តាយរបស់ ដាន់ បានប្រញាប់ប្រញាល់យកបងប្រុសរបស់ ដាន់ ទៅព្យាបាលនៅពេទ្យ ។ ជាអកុសល ពេទ្យមិនអាចជួយសង្គ្រោះបងប្រុសរបស់គាត់បាន ។ មិនយូរប៉ុន្មាន បងប្រុសរបស់ ដាន់ ក៏បានស្លាប់នៅពេលនោះទៅ ។

នៅឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ឪពុករបស់ ដាន់ ដែលអង្គការបញ្ជូនទៅធ្វើការនៅតំបន់ឆ្ងាយ បានត្រឡប់មកផ្ទះវិញ ។ រហូតមកដល់ឆ្នាំ១៩៨០ ដាន់ បានចូលរៀនថ្នាក់បឋមសិក្សានៅពួក ។ រៀងរាល់ព្រឹក ដាន់ ធ្វើដំណើរពីផ្ទះទៅសាលាដែលមានចម្ងាយប្រមាណ១៥គីឡូម៉ែត្រ ។ ដាន់ មិនមានប្រាក់សម្រាប់ទិញចំណីបរិភោគទេ ។ នៅឆ្នាំ១៩៨២ ដាន់ បានទៅសុំស្នាក់នៅផ្ទះបងប្អូនដែលនៅជិតសាលាដើម្បីងាយស្រួលក្នុងការធ្វើដំណើរមកសាលា រហូតដល់គាត់ប្រឡងជាប់មធ្យមសិក្សាបឋមភូមិនៅឆ្នាំ១៩៨៨ ។ បន្ទាប់មក ដាន់ បានបន្តការសិក្សានៅវិទ្យាល័យ ១០ មករា ។

នៅឆ្នាំ១៩៩២ ដាន់ បានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ។ ប៉ុន្តែ ដោយសារតែជីវភាពគ្រួសារមានភាពខ្វះខាត ទើបគាត់មិនបានបន្តការសិក្សាថ្នាក់មហាវិទ្យាល័យ ។ ដាន់ បានចូលបម្រើការងារនៅសណ្ឋាគារមួយ ។ ក្រោយពីបម្រើការងារបានពីរឆ្នាំសណ្ឋាគារក៏រំសាយបុគ្គលិក គាត់ក៏សម្រេចចិត្តទៅធ្វើជាអ្នកគម្បាញ ។ ប្រមាណពីរឬបីឆ្នាំក្រោយមក ដាន់ បានប្រឡងធ្វើជាគ្រូបឋមសិក្សាតាមការណែនាំរបស់ឪពុក ។

នៅឆ្នាំ១៩៩៧ ដាន់ បានប្រឡងជាប់គ្រូបឋមសិក្សា ដែលតម្រូវឲ្យគាត់ទៅសិក្សាវគ្គគរុកោសល្យ នៅសាលាគរុកោសល្យខេត្តសៀមរាប ។ ក្រោយមក ដាន់ ក៏បានទៅបង្រៀននៅសាលាក្នុងស្រុកអង្គរធំ ។

បើទោះបីជាគាត់បានក្លាយជាគ្រូបង្រៀនហើយ ក៏ដោយ ក៏គាត់នៅតែបន្តការសិក្សារហូតបានប្រឡងជាប់គ្រូឧត្តមសិក្សា ។ នៅឆ្នាំ២០១១ ដាន់ ត្រូវបានសមាជិកនៅក្នុងមន្ទីរអប់រំខេត្តសៀមរាប បោះឆ្នោតជ្រើសតាំងគាត់ជានាយិការងវិទ្យាល័យ ហ៊ុន សែន អង្គរធំ ។

**ឃាង សេងហឿន**

# សហព្រះរាជអាជ្ញា បន្តធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ បញ្ចប់កិច្ចពិភាក្សាដេញដោល

ថ្ងៃទីពីរនៃការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២វគ្គ០២ បានប្រព្រឹត្តទៅជាធម្មតា ។ លោកប្រធានចៅក្រម និល ណុន បន្តកិច្ចដំណើរការសវនាការនៅម៉ោង៩ព្រឹក ហើយក្រឡាបញ្ជីសវនាការបញ្ជាក់ប្រាប់ទៅអង្គជំនុំជម្រះ គ្រប់ភាគីនៅក្នុងរឿងក្តីមានវត្តមាន លើកលែងតែជនជាប់ចោទ នួន ជា មិនមានវត្តមានដោយមានបញ្ហាឈឺខ្នងមិនអាចអង្គុយយូរបាន ។ ជនជាប់ចោទ នួន ជា បានលះបង់សិទ្ធិក្នុងការចូលរួមសវនាការនៅក្នុងថ្ងៃនេះ ដោយសារបញ្ហាសុខភាព ប៉ុន្តែលោកបញ្ជាក់យ៉ាងច្បាស់ថា លោកនឹងមិនលះបង់សិទ្ធិក្នុងដំណើរស្វែងរកយុត្តិធម៌ ឬក៏តតាំងជាមួយភស្តុតាងដែលដាក់មកអង្គជំនុំជម្រះនោះទេ ។ អង្គជំនុំជម្រះទទួលយកសំណើរបស់ នួន ជា និងអនុញ្ញាតឲ្យលោកចូលរួមស្តាប់សវនាការពីចម្ងាយ ។

លោកប្រធានចៅក្រម បានប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ជា លាង ដើម្បីបញ្ចប់សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ។

លោកស្រី ជា លាង ថ្លែងអំណរគុណអង្គជំនុំជម្រះ និងបានលើកយកទិដ្ឋភាពទូទៅនៃឧក្រិដ្ឋកម្មក្នុងសំណុំរឿង០០២វគ្គ០២ ដែលបានធ្វើឲ្យប្រជាជនកម្ពុជាទទួលរងនូវភាពឈឺចាប់ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកស្រីសហព្រះរាជអាជ្ញាបានបង្ហាញថា ឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានដូចជា ការអត់ឃ្លាន ការធ្វើការហួសកម្លាំង ជំងឺ សកម្មភាពអមនុស្សធម៌ ការរំលោភសេពសន្ថវៈ ប្រល័យពូជសាសន៍លើជនជាតិចាម និងវៀតណាម ការបង្ខំឲ្យរៀបការ ការឃុំឃាំង ការ


ខៀវ សំផន នៅក្នុងសវនាការលើកស្តុតាង (រូបថតៈ អ.វ.ត.ក)

បន្ទុំឲ្យធ្វើពលកម្ម ហើយនិងការធ្វើទារុណកម្មលើមនុស្សរាប់លាននាក់ នៅការដ្ឋានការងារ និងមន្ទីរសន្តិសុខ ។

លោកស្រី ជា លាង បានពន្យល់ថា ហេតុផលសម្រាប់វគ្គទីពីរនៃការជំនុំជម្រះ និងដោយយោងទៅលើសាលក្រមនៅក្នុងផ្នែកទី១ គឺថា យុត្តិធម៌នៅតែមានបន្តសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះ ។ លោកស្រីសហព្រះរាជអាជ្ញាបានឲ្យដឹងថា ដំណើរការស្វែងរកយុត្តិធម៌មិនមែនជារឿងឆាប់រហ័ស និងងាយស្រួលនោះទេ ។

នៅចុងបញ្ចប់សារណា លោកស្រី ជា លាង បានលម្អិតអំពីកិច្ចខិតខំប្រឹងប្រែងប្រមូលភស្តុតាងនៅក្នុងរឿងក្តីនេះ ។ រវាងឆ្នាំ២០០៧ និង២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មក្នុងសំណុំរឿង០០២ ។ ក្នុងអំឡុងពេលនោះ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានត្រួតពិនិត្យលើបទសម្ភាសរបស់សាក្សី១.០០០នាក់ និងទទួលបានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាង៨.០០០នាក់ ។ លោកស្រីសហព្រះរាជអាជ្ញា បានធ្វើសេចក្តីសង្ខេបអំពីប្រវត្តិនីតិក្រមនៃសំណុំរឿង០០២វគ្គ០១ និង០០២វគ្គ០២ ។ បើយើងយកសំណុំរឿង០០២វគ្គ០១ និង០០២វគ្គ០២ បញ្ចូលគ្នា យើងឃើញថា អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីចំនួន២៧៨នាក់ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ និងបានទទួលយកឯកសារជាង១៦.០០០ឯកសារ ។ ឯកសារទាំងនោះរួមមានឯកសារក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យ ដូចជា សារទូរលេខ ហើយនិងរបាយការណ៍ដែលផ្ញើពីតំបន់ទៅថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា កិច្ចប្រជុំ ទស្សនាវដ្តីទង់បដិវត្តន៍ យុវជនយុវនារីបដិវត្តន៍ របាយការណ៍ពីមន្ទីរសន្តិសុខស-២១ និងស្រុកត្រាំកក់ បទសម្ភាសន៍សុន្ទរកថា សេចក្តីថ្លែងការណ៍របស់ នួន ជា ខៀវ សំផន និងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត បទសម្ភាសរបស់សាក្សី ដែលធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេត មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការផ្សេងៗ ហើយនិងការបោះពុម្ពផ្សាយរបស់អ្នកជំនាញដែលធ្វើការសិក្សាស្រាវជ្រាវពីរបបកម្ពុជាប្រជាធិបតេយ្យ ។

លោកស្រីសហព្រះរាជអាជ្ញា បានលើកឡើងពីការជំទាស់និងការអះអាងរបស់ក្រុមការពារក្តី ។ នៅក្នុងករណីនេះ យើងនិយាយអំពីភស្តុតាង ដែលមិនមែនជារឿងនិទានទេ ហើយភស្តុតាងទាំងនេះនឹងបង្ហាញពីការពិត និងបញ្ជាក់ថា ឧក្រិដ្ឋកម្មមួយពិតជាបានកើតឡើង ដែលទាំងនេះ គឺជាការទទួលខុសត្រូវរបស់ជនជាប់ចោទ ។ លោកស្រីបន្តថា ភស្តុតាងនេះ នឹងជាអ្វីដែលត្រូវផ្តោតទៅលើនៃការដាក់ឯកសាររបស់សហព្រះរាជអាជ្ញានៅពេលពីរថ្ងៃបន្ទាប់ ។ លោកស្រីសហព្រះរាជអាជ្ញាសង្កត់ធ្ងន់ថា ភស្តុតាងទាំងនេះ នឹងជាមូលដ្ឋានគ្រឹះដល់ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះ ។

លោកស្រីសហព្រះរាជអាជ្ញា នឹងពិភាក្សាលើឧក្រិដ្ឋកម្មនៅការដ្ឋានការងារ រួមមានការដាក់ឲ្យទៅជាទាសករ សកម្មភាពអមនុស្សធម៌ផ្សេងៗ ការធ្វើទុក្ខបុកម្នេញទាក់ទងនឹងពុទ្ធសាសនិក ហើយនឹងការបង្ខំឲ្យរៀបការ និងការរំលោភ ។ សហភាគីរបស់លោកស្រីសហព្រះរាជអាជ្ញា នឹងពិភាក្សាលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរសន្តិសុខ ប្រល័យពូជសាសន៍ និងបញ្ហាសំខាន់ៗផ្សេងៗទៀត ។

## ការដាក់ឲ្យទៅជាទាសករ និងការដ្ឋានការងារ

លោកស្រីសហព្រះរាជអាជ្ញាលើកឡើងថា ការដាក់ឲ្យទៅជាទាសករនៅការដ្ឋានការងារ សហករណ៍ គឺជាឧក្រិដ្ឋកម្មដែលជះឥទ្ធិពលដល់ប្រជាជនកម្ពុជាដែលរស់នៅសហករណ៍ និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មនេះ គឺលើសពីអ្វីដែលយើងអាចនិយាយបាន ហើយជះឥទ្ធិពលដល់ ការងារបុគ្គល កន្លែងធ្វើការ ផ្ទះ សាសនា ជីវិតគ្រួសារ និងការទំនាក់ទំនង ។ ជាក់ស្តែង គ្រប់ផ្នែកនៃជីវិតប្រជាជនកម្ពុជា ពីមួយថ្ងៃទៅមួយថ្ងៃ ត្រូវបានដកហូតដោយបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងគោលបំណងផ្លាស់ប្តូរទាំងគំហុកឲ្យក្លាយទៅជាប្រទេសសង្គមនិយម ។ ទោះបីជាកម្មករទាំងនោះបានធ្វើមុនខែមេសា ១៩៧៥ក៏ដោយ ក៏ពួកគេត្រូវបង្ខំឲ្យលះបង់ជីវិតជាកម្មករសាមញ្ញ ឲ្យក្លាយទៅជាកម្មករកសាងទំនប់ និងធ្វើស្រែ ។

ជនជាប់ចោទត្រូវទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅការដ្ឋានការងារចំនួន៤ គឺ ទំនប់ត្រពាំងថ្ម សហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង ។

លោកស្រី ជា លាង ពិភាក្សាដំបូងអំពីចរិតនៃឧក្រិដ្ឋកម្មដែលប្រឆាំងនឹងជនជាប់ចោទ ។ ការដាក់ឲ្យទៅជាទាសករ គឺជា

ឧក្រិដ្ឋកម្មនៃការប្រើឥទ្ធិពល ឬអំណាចរបស់ខ្លួន លើអ្នកដទៃ ដែលទាក់ទងនឹងភាពជាម្ចាស់ ដោយការយកផលប្រយោជន៍ពីអ្នកទាំងនោះ សម្រាប់ការបង្កើនសេដ្ឋកិច្ច តាមរយៈការបង្ខំឲ្យធ្វើពលកម្ម គ្រប់គ្រងការប្រព្រឹត្ត និងបរិយាកាសការងាររបស់ប្រជាជន ដកហូតសិទ្ធិសេរីភាពរបស់ប្រជាជន បញ្ចៀសការរត់គេចណាមួយរបស់ប្រជាជនពីការពិនិត្យដោយបង្ខំឲ្យធ្វើពលកម្ម ទោះបីជាបានបង្ហាញថា ជនរងគ្រោះទាំងនោះមិនមានជម្រើសក្នុងការមិនធ្វើការ ។ សកម្មភាពអមនុស្សធម៌ផ្សេងទៀត ត្រូវបានប្រព្រឹត្ត ឬបំភ្លេចចោល ដែលបានធ្វើឲ្យមានការឈឺចាប់ ឬរបួសដល់ជនរងគ្រោះយ៉ាងខ្លាំង ដូចជា ការដាក់ប្រជាជនឲ្យរស់នៅក្នុងលក្ខខណ្ឌមួយដែលមិនអាចទទួលយកបាន ។

លោកស្រីសហព្រះរាជអាជ្ញា បានពិភាក្សាលើការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ ។ លោកស្រីបានបង្ហាញថា នួន ជា ហើយនឹង ខៀវ សំផន គឺស្ថិតនៅក្នុងក្រុមតូចមួយនៃមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលអាចធ្វើការសម្រេចចិត្តក្នុងការដាក់ឲ្យប្រជាជនកម្ពុជាទៅជាកសិករ ឬកម្មករ នៅក្នុងការដ្ឋានការងារ និងសហករណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសម្រេចចិត្តទាំងអស់នេះ ត្រូវបានធ្វើឡើងក្នុងសមាជបក្ស និងការប្រជុំគណៈអចិន្ត្រៃយ៍ ដែលចូលរួមដោយជនជាប់ចោទទាំងពីរ រួមមានប្រជុំវាយតម្លៃ នៅក្នុងខែឧសភា ១៩៧៥ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងអំណាច ។ ជនជាប់ចោទទាំងពីរបានសារភាពថា ប្រជាជនត្រូវបានបង្ខំឲ្យទៅធ្វើការសហករណ៍ ហើយនឹងគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ ។ នួន ជា បានសារភាពបែបនេះ នៅក្នុងសក្ខីកម្មរបស់គាត់នៅ អ.វ.ត.ក ហើយ ខៀវ សំផន បានសារភាពបែបនេះ នៅក្នុងកិច្ចសម្ភាសន៍សាធារណៈមួយកាលពីមុន ។

លោកស្រី ជា លាង បានបង្ហាញថា ចំណុចគន្លឹះនៃឧក្រិដ្ឋកម្មនៃការដាក់ឲ្យទៅជាទាសករ គឺការគ្រប់គ្រងធ្វើឲ្យប្រជាជនរងគ្រោះ ។ លោកស្រីបាននិយាយថា ភ័ស្តុតាងបានបង្ហាញថា ការគ្រប់គ្រងគឺជាហេតុផលចម្បងនៃការប្រតិបត្តិរបស់បក្សកុម្មុយនីស្តកម្ពុជានៅសហករណ៍ ។ នៅក្នុងការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា "ទង់បដិវត្តន៍" ដែលសរសេរដោយ ខៀវ សំផន បានលើកឡើងថា សហករណ៍ គឺមានកាតព្វកិច្ចគ្រប់គ្រងបង្កើតផលិតផលស្រូវ សម្រាប់ប្រទេស និងប្រជាជន ។ នួន ជា បានសរសេរនៅក្នុងសៀវភៅរបស់គាត់ថា តម្រូវការក្នុងការត្រួតពិនិត្យ និងដកហូតពីប្រជាជន ធ្វើឡើងតាមរយៈសហករណ៍ ។

លោកស្រីសហព្រះរាជអាជ្ញាបានពន្យល់ថា បក្សកុម្មុយនីស្តកម្ពុជា បានអនុវត្តគោលនយោបាយផលិតស្រូវ៣តោនក្នុង១ហិកតា ស្របពេលដែលគម្រោងនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធកំពុងតែធ្វើក្នុងល្បឿនដ៏គ្រោះថ្នាក់មួយ ។ គោលនយោបាយនេះត្រូវបានហៅថា "មហាលោតផ្លោះ" ។ ខៀវ សំផន បានរៀបរាប់នៅក្នុងផែនការបដិវត្តន៍របស់ខ្លួន ក្នុងពេលប្រជុំគណៈអចិន្ត្រៃយ៍ នៅវត្តប្រាក់ថា តម្រូវការកសាងគម្រោងទាំងអស់នេះជាប្រញាប់ ។ នួន ជា ក៏យល់ស្របនឹងផែនការកសាងហេដ្ឋារចនាសម្ព័ន្ធឲ្យបានឆាប់រហ័សនេះដែរ ។

លោកស្រី ជា លាង លើកឡើងថា ជនជាប់ចោទដឹងអំពីតម្លៃនៃការសាងសង់ឲ្យឆាប់រហ័ស និងបង្កើនផលិតផលកសិកម្មដ៏គំហុកមួយ ។ ជនជាប់ចោទដឹងថា ជនជាប់ចោទកំពុងបង្ខំប្រជាជនធ្វើការធ្ងន់ ហើយប្រជាជនទាំងនោះ មិនមានអាហារ ឬសេវាសុខភាពគ្រប់គ្រាន់ ហើយរស់នៅក្នុងលក្ខខណ្ឌមួយដែលអាចនាំឲ្យប្រជាជនស្លាប់ ។ ប្រជាជនត្រូវធ្វើការ១៥ម៉ោងក្នុងមួយថ្ងៃ ស្របពេលដែលរបបអាហារ និងថ្នាំកាន់តែខ្សត់ទៅ ដែលបណ្តាលឲ្យមានជំងឺ ការឈឺចាប់ និងអាហារមិនគ្រប់គ្រាន់ ។

ទោះបីជាលក្ខខណ្ឌនៅការដ្ឋានការងារយ៉ាងនេះក៏ដោយ ក៏មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅតែបន្តចលនាមហាលោតផ្លោះរបស់ខ្លួនដដែល ។ លោកស្រី ជា លាង ថ្លែងថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបង្កើនគោលដៅរហូតដល់៣តោនកន្លះ ក្នុង១ហិកតា ហើយបង្ខំឲ្យប្រជាជនធ្វើការរឹតតែខ្លាំងជាងមុន និងឲ្យជីកទំនប់កាន់តែធំជាងមុន ។

លោកស្រីព្រះរាជអាជ្ញាបានពន្យល់ថា ជនជាប់ចោទបានដឹងជាមុនរួចមកហើយអំពីស្ថានភាពនៅការដ្ឋានការងារ ។ ជាឧទាហរណ៍ នៅក្នុងវគ្គអប់រំកសាងមួយ ជនជាប់ចោទទាំងពីរ ខៀវ សំផន និង នួន ជា បានអប់រំណែនាំកម្មាភិបាល ធ្វើយ៉ាងដូចម្តេចសម្គាល់ថា ប្រជាជនដែលឈឺមួយចំនួន គួរតែចាត់ទុកជាខ្មាំង ហើយអ្នកទាំងពីរណែនាំកម្មាភិបាល ធ្វើដូចម្តេចក្នុងការគាបសង្កត់

ការងារ និងលក្ខខណ្ឌរស់នៅ ដើម្បីស្វែងរកខ្មាំង ។ សាក្សីមួយរូបបានប្រាប់អំពីការដែលគាត់បានទៅចូលរួមប្រជុំ ហើយនឹងដឹងអំពីគោលនយោបាយនៃការកំណត់ប្រជាជនណាដែលមិនប្រឹងប្រែងធ្វើការងារ ឬក៏ខ្ជិលធ្វើការ និងត្រូវចាត់ទុកជាខ្មាំង ។

លោកស្រីសហព្រះរាជអាជ្ញា បានផ្តល់ជាឧទាហរណ៍ថាតើជនជាប់ចោទសារភាពខ្លួនឯង អំពីគោលនយោបាយដែលធ្វើឲ្យឈឺចាប់ដល់ប្រជាជនកម្ពុជាយ៉ាងដូចម្តេច? ។ ខៀវ សំផន បាននិយាយនៅក្នុងបទសម្ភាសន៍ជាមួយវិទ្យុសំឡេងសហរដ្ឋអាមេរិកដែលគាត់បានពិពណ៌នាអំពីការគិតរបស់គាត់ក្នុងការបង្ខំឲ្យប្រជាជនធ្វើការធ្ងន់ដើម្បីសម្រេចផែនការដែលបានដាក់ចេញ ។ គាត់បាននិយាយថា គាត់ដឹងថា បក្សកុម្មុយនីស្តកម្ពុជានឹងមិនអាចសម្រេចតាមផែនការទេ លុះត្រាតែប្រជាជនខំប្រឹងធ្វើខ្លាំងឡើងៗ ហើយប្រជាជនធ្វើការជាមួយភាពអត់ឃ្លាន និងអាហារ ថ្នាំពេទ្យបន្តិចបន្តួច ហើយ ខៀវ សំផន បានដឹងរឿងទាំងអស់នេះ ពីព្រោះគាត់ជាអ្នករៀបចំថ្នាំពេទ្យ ។ នៅក្នុងបទសម្ភាសជាមួយអ្នកកាសែតអាល្លឺម៉ង់ក្នុងឆ្នាំ២០០៧ នួន ជា ក៏បានដឹងពីបញ្ហាទាំងនេះដែរថា ដំណើរការគឺឆាប់រហ័ស ហើយតម្រូវឲ្យប្រជាជនលះបង់ខ្ពស់ ។ គាត់បានប្រាប់ទៅ ថេត សម្បត្តិ អំពីជីវប្រវត្តិរបស់គាត់ថា បក្សកុម្មុយនីស្តកម្ពុជាត្រូវបានដួលរលំដោយសារចលនាមហាលោតផ្លោះ អនុវត្តលឿនពេក ។

បន្ទាប់មក លោកស្រី ជា លាង បានរម្លឹក និងបង្ហាញអំពីការជំទាស់តវ៉ារបស់ជនជាប់ចោទចំពោះការទទួលខុសត្រូវទាំងអស់នេះដែលជនជាប់ចោទបដិសេធថា ជនជាប់ចោទមិនបានដឹងអំពីការអត់ឃ្លាន និងលក្ខខណ្ឌរស់នៅដ៏អាក្រក់យ៉ាងនេះដែរ ។ លោកស្រីសហព្រះរាជអាជ្ញា លើកយកសេចក្តីថ្លែងការណ៍របស់អ្នកផ្សេងទៀត ។ ក្នុងសេចក្តីថ្លែងការណ៍នោះ បានបង្ហាញថា ជនជាប់ចោទទាំងពីរបានធ្វើដំណើរទូទាំងប្រទេស ដើម្បីពិនិត្យការដ្ឋាន ហើយក៏ជាឱកាសអាចមើលឃើញដោយផ្ទាល់ភ្នែកចំពោះលក្ខខណ្ឌរស់នៅ ។

ទទ្ទឹករណ៍ចំពោះការលើកឡើងនេះ លោកស្រី ជា លាង បានផ្តល់ជាភស្តុតាង អំពីសម្តេចឪព្រះនរោត្តម សីហនុ ទ្រង់បានផ្តល់បទសម្ភាសន៍ដែលពិពណ៌នាអំពីការធ្វើដំណើររបស់ទ្រង់ជាមួយ ខៀវ សំផន នៅប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៦ ហើយនឹងបានពិពណ៌នាអំពី ខៀវ សំផន ដែលបានឃើញ និងទទួលស្គាល់ពីការប្រព្រឹត្តទៅនៃការងារពេញមួយថ្ងៃរហូតដល់យប់ ។ លក្ខខណ្ឌទាំងនេះ ដូចជាជាជំរំប្រមូលផ្តុំ អាហារមិនគ្រប់គ្រាន់ ហើយរបបអាហារកាន់តែអាក្រក់ទៅៗ ។ លោកស្រី ជា លាង បានកត់សម្គាល់ថា អ្វីដែលសម្តេចសីហនុ ទតឃើញ ខៀវ សំផន ក៏ឃើញដូចគ្នា ។ លើសពីនេះទៀត លោកស្រីសហព្រះរាជអាជ្ញា បានកត់សម្គាល់ទៀតថា នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ នៅក្នុងបន្ទប់សវនាការដដែលនេះ ខៀវ សំផន បានពិពណ៌នាថា គាត់បានឃើញប្រជាជនធ្វើដំណើរទៅវាលស្រែនៅម៉ោង៤ព្រឹក ។

ជាមួយគ្នានេះ សេចក្តីថ្លែងការណ៍ទាំងអស់នេះ ត្រូវបានធ្វើឡើងដោយជនជាប់ចោទទាំងពីរ ។ លោកស្រី ជា លាង បានរម្លឹកពីឯកសារភស្តុតាងលើលក្ខខណ្ឌការងារ នៅការដ្ឋានការងារ ដែលជនជាប់ចោទដឹងជាមុនថា ជាការដាក់ទម្ងន់លើប្រជាជនកម្ពុជា ។ លោកស្រី ជា លាង បានលើកឡើងថា ការរាយការណ៍ក្នុងអំឡុងពេលនោះគឺមានភាពទូលំទូលាយ ។ តំបន់បានផ្ញើរបាយការណ៍ និងកំណត់ត្រាទៅមេដឹកនាំមជ្ឈិមបក្សនៅភ្នំពេញ ជាទៀងទាត់ ។ ទោះជាយ៉ាងណាក៏ដោយ មេដឹកនាំមជ្ឈិមបក្សបានបំផ្លាញកំណត់ត្រាទាំងអស់នេះមុនរត់គេចខ្លួនក្នុងឆ្នាំ១៩៧៩ ហើយក៏មានកំណត់ត្រាជាច្រើននៅសេសសល់ដែរ ។

លោកស្រី ជា លាង ដាក់ជូននូវកំណត់ត្រាទាំងនេះ ដើម្បីបង្ហាញថា នួន ជា និង ខៀវ សំផន ត្រូវបានគេរាយការណ៍អំពីការអត់ឃ្លាន ការសម្លាប់ និងការចាប់ខ្លួន ក្នុងអំឡុងពេលដែលខ្លួនគ្រប់គ្រង ។ ជនជាប់ចោទទាំងពីរ បានទទួលរបាយការណ៍ដែលបង្ហាញថា ប្រជាជននៅជនបទទទួលរងនូវផលប៉ះពាល់ពីជំងឺ ការអត់ឃ្លាន កង្វះថ្នាំពេទ្យ អាហារ និងការធ្វើការលើសកម្លាំង ។ ជាឧទាហរណ៍ លេខាតំបន់បានរាយការណ៍អំពីប្រជាជនពីតំបន់មួយ ទៅតំបន់មួយ ដែលទទួលផលប៉ះពាល់ពីជំងឺរាក ក្តៅខ្លួនខ្លាំង ហើយនឹងស្នើកាត់បន្ថយម៉ោងធ្វើការ ។ ភូមិភាគពាយ័ព្យ បានរាយការណ៍ថាមានការខ្វះខាតគ្រប់បែបយ៉ាង ហើយប្រជាជនទទួលបានតែរបបបបររាវៗប៉ុណ្ណោះ ។ ភូមិភាគនិរតី បានរាយការណ៍ថា មានភាពខ្វះខាតច្រើន ហើយប្រជាជនមានជំងឺអាសន្នរោគ និងស្លាប់ ។

លោកស្រី ជា លាង បានពន្យល់អំពីរបាយការណ៍ដែលត្រូវ

បានសរសេរនេះថា ជនជាប់ចោទបានទទួលរបាយការណ៍ដោយផ្ទាល់នៅការិយាល័យគ្រប់គ្រងនៅភ្នំពេញពីមេដឹកនាំភូមិភាគ និងតំបន់ ដែលឡើងមករាយការណ៍ និងទទួលការណែនាំ ។ សាក្សី បានចូលរួមក្នុងការប្រជុំនេះ ជាកម្មាភិបាលមកពីមន្ទីរ ក-១ ដែលជាប្រធានតំបន់មួយ បានពិពណ៌នាអំពីការធ្វើដំណើររបស់គាត់មកភ្នំពេញដើម្បីប្រជុំជាមួយ ប៉ុល ពត ខៀវ សំផន នួន ជា និង សុនសេន ។ ទោះបីជាមានសមាជិកនៃគណៈមជ្ឈិមបក្សតែពីរបីនាក់ដែលរួចរស់ជីវិត ដែលមកធ្វើជាកសិណសាក្សីនៅថ្ងៃនេះថា ការប្រជុំរយៈពេលខ្លីមួយនិយាយអំពីផលិតផលស្រូវ សុខភាពប្រជាជន ភាពខ្វះខាតក្នុងការផ្គត់ផ្គង់អាហារ និងសកម្មភាពរបស់ខ្មាំង ។

ជាចុងបញ្ចប់ លោកស្រីព្រះរាជអាជ្ញា បានលើកឡើងថា មន្ទីរ៨៧០ ដែលរួមមាន ប៉ុល ពត នួន ជា ខៀវ សំផន និង ឌឿន ហើយមន្ទីរនេះ បានទទួលឯកសាររបាយការណ៍អំពីការស្លាប់របស់ប្រជាជនកម្ពុជា ការខ្វះអាហារ ជំងឺ និងការចាប់ខ្លួនខ្មាំង ។ ការឆ្លើយតបពីមន្ទីរ៨៧០ គឺកសាងទំនប់ទឹកបន្ថែមទៀត និងកំណត់របបអាហារ ។

ភស្តុតាងនេះ បានបង្ហាញយ៉ាងច្បាស់ថា នួន ជា និង ខៀវ សំផន ពិតជាបានដឹង និងជាអ្នកគ្រប់គ្រងខ្ពស់បំផុត ចំពោះលក្ខខណ្ឌរស់នៅ និងការងារនៅការដ្ឋានការងារ ។

## ឧក្រិដ្ឋកម្មនៅទំនប់ត្រពាំងថ្ម

បន្ទាប់មក លោកស្រី ជា លាង បានពិភាក្សាទៅលើការដ្ឋានការងារចំនួន៤ផ្សេងទៀត ដែលពិភាក្សាដំបូង គឺទំនប់ត្រពាំងថ្ម ។ ការដ្ឋានការងារនេះ ស្ថិតនៅភូមិភាគនិរតី ដែលរួមមាន ទំនប់ទឹកប្រវែង១៨គីឡូម៉ែត្រទៅទិសខាងកើត និង៨គីឡូម៉ែត្រទៅទិសខាងត្បូង ។ វាគឺជាការដ្ឋានការងារដ៏ធំមួយ ហើយប្រជាជនទាំងអស់ត្រូវបានណែនាំឲ្យបញ្ចប់ការធ្វើទំនប់នៅឆ្នាំ១៩៧៧ ដើម្បីសម្រេចផែនការមហាលោតផ្លោះ ។ យោងទៅតាមលេខាភូមិភាគពាយ័ព្យ អាងទឹកនេះ ត្រូវបានធ្វើឡើងមិនដល់ពីរខែផង ។ ខៀវ សំផន បានលើកឡើងកាលពីឆ្នាំ២០១៣ថា នៅឆ្នាំ១៩៧៦ គាត់បានឃើញប្រឡាយ និងទំនប់ទឹក រួមមាន ទំនប់ត្រពាំងថ្មនេះ មើលទៅហាក់បីដូចជាសមុទ្រនៅក្នុងវាលស្រែ ដែលពីមុនមកជាដីស្ងួតហួតហែង ។ គាត់ក៏បានពិពណ៌អំពីទំនប់នេះ នៅក្នុងសៀវភៅគាត់ដែរ ។

មេដឹកនាំបក្សកុម្មុយនីស្តផ្សេងទៀត ក៏បានមកកាន់ទំនប់ត្រពាំងថ្មនេះដែរ រួមមាន ប៉ុល ពត ហើយភូមិភាគនិរតីបានរាយការណ៍ទៅមន្ទីរ៨៧០ ជាទៀងទាត់ ។ វាត្រូវបានស្គាល់យ៉ាងទូលំទូលាយពីសំណាក់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដូចដែលពួកគេបានពិពណ៌នានៅក្នុងទស្សនាវដ្តី យុវជន យុវនារីបដិវត្តន៍ផ្សាយឆ្នាំ១៩៧៧ ។

លោកស្រី ជា លាង បានកត់សម្គាល់ឃើញថា អំឡុងពេលជំនុំជម្រះនេះ មានអតីតអ្នកធ្វើការ និងកម្មាភិបាល ធ្វើការនៅទំនប់ត្រពាំងថ្ម ចំនួន១៥នាក់ បានមកផ្តល់សក្ខីកម្ម ។ ដូចជា ការដ្ឋានការងារដទៃទៀតដែរ ទំនប់ត្រពាំងថ្ម គឺជាផ្នែកមួយនៃផែនការមហាលោតផ្លោះ ហើយសាក្សីបានពិពណ៌មានអំពីប្រជាជនដែលធ្វើការនៅទំនប់ត្រពាំងថ្មទាំងយប់ទាំងថ្ងៃ និងមានពេលវេលាសម្រាកបន្តិចបន្តួច ។ សហការីរបស់ប្រធាននៅទំនប់ត្រពាំងថ្ម បានផ្តល់សក្ខីកម្មថា អំឡុងពេលប្រយុទ្ធការងារ ប្រជាជនត្រូវធ្វើការដោយមិនបានដេក ហើយពេលខ្លះត្រូវធ្វើជាប់ៗគ្នាពីរបីថ្ងៃទៀតផង ។

ខៀវ សំផន បាននិយាយថា ប្រជាជនធ្វើការពីម៉ោង៣ ឬ ៤ព្រឹក រហូតដល់យប់ជ្រៅ ហើយគាត់បានពិពណ៌នាពីការហត់នឿយយ៉ាងខ្លាំងពីការធ្វើការដោយកម្លាំងចំពោះការងារ រួមមាន តម្រូវការឲ្យម្នាក់ៗរែកដី៣ម៉ែត្រគីបក្នុងមួយថ្ងៃ ការកាត់បន្ថយរបបអាហារ ប្រសិនបើនរណាម្នាក់ធ្វើមិនគ្រប់ផែនការរបស់ខ្លួន ។ របបអាហារ គឺមិនគ្រប់គ្រាន់រួចហើយ និងមានច្រើនបំផុតត្រឹមតែបបររាវៗមួយកូនចាន ។ សាក្សីម្នាក់បាននិយាយថា គាត់ពិតជាឃ្លានខ្លាំងណាស់ ហើយពេលខ្លះគាត់គិតថា ចង់យកជីវិតទៅប្តូរជាមួយនឹងអាហារមួយពេល ដែលមានបាយ និងសាច់មាន់ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ មានការធ្វើបន្សុទ្ធកម្មនៅភូមិភាគពាយ័ព្យ ហើយកម្មាភិបាលភូមិភាគ ត្រូវបានជំនួសដោយកម្មាភិបាលស្មោះត្រង់ដែលមកពីភូមិភាគនិរតី ។ លោកស្រី ជា លាង បានពិពណ៌នាថា មិនមានទឹកស្អាតដែលអាចប្រើប្រាស់បានទេ គឺមានតែទឹកភក់នៅក្នុងត្រពាំង ។ លោកស្រីព្រះរាជអាជ្ញា បានផ្តល់ឯកសារអំពីការដឹងឮរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចំពោះបញ្ហាកង្វះទឹកស្អាតនៅទំនប់ត្រពាំងថ្ម ដែលបានបង្ហាញយ៉ាង

ច្បាស់អំពីកង្វះទឹកស្អាតនៅក្នុងទស្សនាវដ្តី យុវជន យុវនារីបដិវត្តន៍ ផ្សាយលេខខែកក្កដា សីហា ឆ្នាំ១៩៧៧ ។ មានសរសេរនៅក្នុងទស្សនាវដ្តីថា ជាការពិត ប្រជាជនត្រូវប្រឈមមុខនឹងកង្វះទឹក និងបានពិព័ណ៌នាចំណុចនេះជាច្រើនម៉ោង អំពីផលវិបាកនៃលក្ខខណ្ឌការងារ និងការនឿយហត់ខ្លាំងក្នុងពេលធ្វើការនៅទំនប់ត្រពាំងថ្ម ។

សាក្សីមួយចំនួនមានដូចជា អតីតកងការពារ, លេខាស្រុក និងប្រធានអនុសេនាធំ បានផ្តល់សក្ខីកម្មអំពីការឃើញយុវជន យុវនារី និងអ្នកជម្លៀសមកពីភ្នំពេញ នៅឯការដ្ឋានសាងសង់ ដែលមើលទៅស្គមស្គាំង និងមានជំងឺ ។ ផលវិបាកនៃលក្ខខណ្ឌរស់នៅ មានដូចជា កង្វះអាហារ កង្វះការថែទាំអនាម័យ កង្វះបន្ទន់ជំងឺ ការទទួលអាហារមិនគ្រប់គ្រាន់ និងស្លាប់ដោយសារធ្វើការហួសកម្លាំង ។ សាក្សីបានពន្យល់ថា ប្រជាជនបន្តធ្វើការរហូតដល់ដួល ពីព្រោះតែភ័យខ្លាចចំពោះអាយុជីវិតរបស់ខ្លួន ។ សាក្សីមិនត្រូវបានអនុញ្ញាតឲ្យទៅលេងគ្រួសារទេ ហើយកម្មាភិបាលខ្មែរក្រហមបានដើរល្បាតដើម្បីចៀសវាងប្រជាជនលួចរត់ ។

លោកស្រី ជា លាង បន្ថែមទៀតថា លក្ខខណ្ឌរស់នៅនៅទំនប់ត្រពាំងថ្ម ប្រជាជនមានរូបរាងស្គមស្គាំងធ្វើការ១៥ម៉ោងក្នុងមួយថ្ងៃ ជាមួយនឹងរបបអាហារបន្តិចបន្តួច ធ្វើការរហូតដល់ដួល ហើយនឹងត្រូវបាញ់សម្លាប់ដោយកងការពារ ប្រសិនបើប្រជាជនព្យាយាមរត់គេច ។ នេះបានបញ្ជាក់ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះបទឧក្រិដ្ឋកម្មការដាក់ឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ។

លោកស្រី ជា លាង លើកឡើងថា ស្ថានភាពនៅទំនប់ត្រពាំងថ្មក៏បង្ហាញឲ្យឃើញដែរថា ជាបទឧក្រិដ្ឋកម្មរំលោភបំពាននយោបាយ ។ លោកស្រីបានពន្យល់ថា ប្រធានអនុសេនាធំ និងកងវរសេនាតូច ត្រូវបានណែនាំឲ្យស្វែងរកអតីតទាហានលន់ នល់ និងបញ្ញវន្ត ។ ប្រធានទាំងនោះ ត្រូវបានផ្តល់សិទ្ធិអំណាចសម្លាប់អតីតទាហានលន់ នល់ និងនរណាម្នាក់ដែលប្រឆាំងនឹងអង្គការ ។

មកដល់ចំណុចនេះ លោកស្រីសហព្រះរាជអាជ្ញាផ្អាកនូវសេចក្តីថ្លែងការណ៍របស់ខ្លួន ព្រោះដល់ម៉ោងសម្រាក ។

មុននឹងលោកប្រធានចៅក្រម និល ណុន បន្តសវនាការ លោកបានកត់សម្គាល់ឃើញថា លោកស្រីសហព្រះរាជអាជ្ញា មិនបានបញ្ជាក់អំពីលេខទំព័រ ឬលេខឯកសារដែលដាក់បង្ហាញលើកញ្ចក់កុំព្យូទ័រ ក៏ដូចជាខ្សែវីដេអូ ដែលលោកស្រីបានធ្វើបទបង្ហាញទៅអង្គជំនុំជម្រះ ។ លោកប្រធានកត់សម្គាល់ឃើញ មានវីដេអូមួយអំពីសម្តេចសីហនុ ដែលទ្រង់មានបន្ទូលជាភាសាបារាំង ហើយមិនបានផ្តល់នូវការបកប្រែជាភាសាខ្មែរទេ ។ ការលើកឡើងពីបញ្ហានេះ ពីព្រោះតែមិនមានលេខឯកសារ ។ លោកប្រធានចៅក្រមមិនប្រាកដថា តើឯកសារដែលដាក់បង្ហាញលើកញ្ចក់កុំព្យូទ័រកាលពីព្រឹកមិញនេះ ធ្លាប់បានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ និងភាគីដទៃទៀតឬទេ?

លោកស្រី ជា លាង បានតបថា លោកស្រីនឹងផ្តល់លេខឯកសារដល់អង្គជំនុំជម្រះ និងគ្រប់ភាគី ហើយលោកស្រីក៏ធ្វើការកត់សម្គាល់ដែរថា ខ្សែវីដេអូរបស់សម្តេចសីហនុ ដែលទ្រង់មានបន្ទូលជាភាសាបារាំង មិនធ្លាប់បានបកប្រែជាភាសាខ្មែរតាំងពីមុនមក ។ លោកសហព្រះរាជអាជ្ញា នីកូឡាស គាំចាន់ បានផ្តល់លេខឯកសារយោងដល់អង្គជំនុំជម្រះ និងបានពន្យល់ថា វីដេអូរបស់សម្តេចសីហនុមិនទាន់បានបកប្រែ ដូចនេះ លោកសហព្រះរាជអាជ្ញាមានបំណងចង់ឲ្យមានបកប្រែដំណាលគ្នា ដោយអ្នកបកប្រែរបស់អង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការនេះតែម្តង ។

បន្ទាប់មក មេធាវីការពារក្តី នួន ជា លោក វិចទ័រ កូប៉េ បានសង្កត់ធ្ងន់ថា ការធ្វើបទបង្ហាញរបស់សហព្រះរាជអាជ្ញា ក៏មិនបានដាក់បញ្ចូលការយោងទៅលើលេខឯកសារជាមួយនឹងការរំពឹងទុកដូចគ្នាថា នឹងបង្កើនការធ្វើបទបង្ហាញនេះប្រព្រឹត្តទៅដោយរលូន ។ គាត់បានស្នើសុំនូវដំណោះស្រាយចំពោះសំណួរនេះ ។

លោកចៅក្រម ឡាវ៉េញ បានកត់សម្គាល់ឃើញថា អ្វីដែលសំខាន់ចំពោះអង្គជំនុំជម្រះ គឺអង្គជំនុំជម្រះចង់ឲ្យច្បាស់ថា រាល់អ្វីៗដែលបានដាក់មកកាន់អង្គជំនុំជម្រះ គឺត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះរួចហើយ ។ លោក គាំចាន់ បានស្នើដើម្បីផ្តល់ជូនគ្រប់ភាគីនូវបញ្ជីសម្ភារសោតទស្សន៍ជាមួយនឹងលេខយោងនៅពេលបញ្ចប់សវនាការថ្ងៃនេះ ។

លោកស្រីសហព្រះរាជអាជ្ញា ជា លាង បានបន្តនូវបទបង្ហាញរបស់ខ្លួនទៅលើឧក្រិដ្ឋកម្មលើការរំលោភបំពាននយោបាយនៅទំនប់ត្រពាំងថ្ម ។ លោកស្រីបង្ហាញថា សាក្សីបានផ្តល់សក្ខីកម្ម

ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានស្វែងរកប្រជាជនណាដែលជាប់សាច់ញាតិនឹងអតីតទាហាន លន់ នល់ ។ សាក្សីម្នាក់បានផ្តល់សក្ខីកម្មថា ឪពុកម្តាយ និងបងប្អូនស្រីរបស់គាត់ ត្រូវបានយកទៅសម្លាប់ ព្រោះតែឪពុករបស់គាត់ជាអតីតអ្នករដ្ឋការលន់ នល់ ។

នៅភូមិភាគបស្ចិម មានសាក្សីជាច្រើនបានផ្តល់សក្ខីកម្មអំពីការសម្លាប់ ការបាត់ខ្លួន ការចាប់ខ្លួន ការវាយធ្វើបាប និងការរកប់សាកសពដែលត្រូវបានសម្លាប់នៅការដ្ឋានទំនប់ត្រពាំងថ្ម ។ សាក្សីបានផ្តល់សក្ខីកម្មថា ប្រជាជនដែលឈឺត្រូវបានសម្លាប់ ដោយចោទថា មានជំងឺពុតត្បុត ។

## ឧក្រិដ្ឋកម្មនៅការដ្ឋានការងារទំនប់១មករា

បន្ទាប់មក លោកស្រីសហព្រះរាជអាជ្ញា បានពិភាក្សាអំពីការដ្ឋានការងារទំនប់១មករា ។ ១មករា គឺជាទំនប់ដែលមានប្រវែង ៦០គីឡូម៉ែត្រស្ថិតក្នុងភូមិភាគកណ្តាល ។ ដូចជា ទំនប់ត្រពាំងថ្មដែរ ទំនប់នេះត្រូវបានធ្វើឡើងជា "ការដ្ឋានក្តៅ" ដែលមានន័យថា បង្កើនម៉ោងការងារសម្រាប់ប្រជាជន ។ លោកស្រីបានបង្ហាញពីវីដេអូឯកសារពិតមួយនៃប្រជាជនធ្វើការនៅទំនប់១មករា ធ្វើការដោយជើងទទេ រែកដីជាមួយនឹងបង្គីសងខាងស្មា ប្រជាជនដើរជាជួរៗយ៉ាងលឿន ហើយពេលខ្លះរត់ផង ។ ប្រជាជនស្លៀកពាក់ធម្មតា អ្នកខ្លះមានមួក អ្នកខ្លះយកក្រមា ឬក្រណាត់មករុំក្បាល សម្ភារដែលប្រើកាប់ដីគឺគ្រាន់តែជាប៉ែលធម្មតា ហើយក៏មិនមានគ្រឿងចក្រធន់ធ្ងន់ដែរ ។ ការដ្ឋាន គឺធំណាស់ ហើយខ្នងទំនប់ ដែលប្រជាជន ត្រូវឡើង គឺជម្រាល ។

នួន ជា ប៉ុល ពត និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត បានទៅទំនប់ការដ្ឋានទំនប់១មករា ។ លេខាភូមិភាគកណ្តាល បានទៅពិនិត្យការដ្ឋានជាទៀងទាត់ និងបានធ្វើរបាយការណ៍ទៅកាន់បក្សនៅភ្នំពេញ ។

សាក្សីបានផ្តល់សក្ខីកម្មថា នួន ជា បានពិនិត្យការដ្ឋានទំនប់ ឃើញថា សាងសង់មិនល្អ ហើយ នួន ជា បានណែនាំឲ្យបង្កើនការសាងសង់បន្ថែមទៀត ។ វីដេអូផ្សេងទៀត បានបង្ហាញថា នួន ជា បានត្រួតពិនិត្យការដ្ឋាន ហើយគាត់នៅជិតនឹងប្រជាជន ដែលមិនមែនជាការសង្កេតមើលពីចម្ងាយនោះទេ ។ ដូចជា ខៀវ សំផន ដែរ នួន ជា មានឱកាសច្រើន ដើម្បីពិនិត្យការដ្ឋានទំនប់១មករា ។

លោកស្រីសហព្រះរាជអាជ្ញា បានពិពណ៌នាអំពីសុន្ទរកថារបស់ ខៀវ សំផន ដែលបានផ្សាយនៅវិទ្យុ ក្នុងថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ។ នៅក្នុងសុន្ទរកថា ខៀវ សំផន បានបង្ហាញយ៉ាងច្បាស់ពីការដឹងឮអំពីការដ្ឋានការងារ ចំនួនប្រជាជន ហើយនឹងកង្វះខាតគ្រឿងចក្រ ។ សុន្ទរកថានេះ បានបង្ហាញថាការដែល ខៀវ សំផន បានរួមចំណែកក្នុងគម្រោងបក្ស ដើម្បីសាងសង់ការដ្ឋានទាំងនេះ ដោយការធ្វើបាបប្រជាជនកម្ពុជា ។ ត្រង់ចំណុចមួយក្នុងសុន្ទរកថា គាត់បានពិពណ៌នាថា ទំនប់ត្រូវបានសាងសង់ ហើយបានដឹងអំពីគុណភាពនៃការងារនេះ ដោយនិយាយថា វាមិនមែនជាបញ្ហាទេ ប្រសិនបើទំនប់ប្រើពេលសាងសង់៥ឆ្នាំ ។ ខៀវ សំផន បានបញ្ចប់សុន្ទរកថារបស់ខ្លួនដោយបានក្រើនរម្លឹកដល់ប្រជាជន ឲ្យបង្កើនល្បឿនការងារដើម្បីសម្រេចផែនការរបស់បក្ស ។

លោកស្រី ជា លាង បានធ្វើការសរុបថា ខៀវ សំផន ហើយមេដឹកនាំបក្ស មិនពេញចិត្តនឹងគុណភាពនៃទំនប់ ដែលបង្ហាញឲ្យឃើញថា ខៀវ សំផន និងមេដឹកនាំបក្សមិនស្ទាក់ស្ទើរលះបង់ប្រជាជនដើម្បីបក្សកុម្មុយនីស្តកម្ពុជារីកចម្រើន ហើយសុន្ទរកថារបស់ ខៀវ សំផន បានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជា បានចូលរួមធ្វើឲ្យគោលនយោបាយសាងសង់របស់ខ្លួនលឿនជាងពីមុន ដោយមិនបានគិតអំពីតម្លៃជាមនុស្សរបស់ប្រជាជន ។

លោកស្រី ជា លាង បានលើកឡើងថា ប្រជាជននៅទំនប់ ១មករា ដែលរងការឈឺចាប់ពីឧក្រិដ្ឋកម្មនេះ មិនមែនមកពីការធ្វើហួសហេតុ ឬក៏ការធ្វើមិនបានជោគជ័យរបស់អ្នកគ្រប់គ្រងក្នុងតំបន់របស់ខ្លួនទេ ប៉ុន្តែគឺមេដឹកនាំនៅភ្នំពេញ ដែលមានចេតនាដាក់ឲ្យប្រជាជនទៅជាទាសករ ដកហូតសិទ្ធិជាមូលដ្ឋាន បង្ខំឲ្យធ្វើការជាទម្ងន់នៅក្នុងលក្ខខណ្ឌអមនុស្សធម៌ ហើយនឹងលះបង់ជីវិតរបស់ប្រជាជន ដើម្បីសម្រេចនូវគោលដៅរបស់បក្ស ។ អតីតអ្នកធ្វើការនិងកម្មាភិបាលចំនួន១៣ បានផ្តល់សក្ខីកម្មអំពីស្ថានភាពនៅទំនប់ ១មករា ក្នុងនោះមានសាក្សីម្នាក់ដែលមានអាយុ១២ឆ្នាំ នៅពេលដែលគាត់ធ្វើការនៅទំនប់នោះ ។ ការប្រើប្រាស់កម្លាំងពលកម្មកុមារ ត្រូវបានដឹង និងឯកភាពដោយមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងសុន្ទរកថារបស់ ខៀវ សំផន នៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៧៧ បានលើកឡើងពីការប្រើប្រាស់

ពលកម្មកុមារដោយបង្ហាញថា កុមារកម្ពុជាមានសេចក្តីរីករាយក្នុងការប្រមូលដីធម្មជាតិ ហើយនឹងជួយកសាងទំនប់ ទំនប់ការពារទឹកអាងស្តុកទឹក និងប្រឡាយ ។ ក្មួយរបស់ ប៉ុល បត បានផ្តល់សក្ខីកម្មថា គាត់បានឃើញកុមារកំពុងធ្វើការនៅទំនប់១មករា នៅពេលដែលគាត់ទៅពិនិត្យជាមួយ ប៉ុល ពត ។

លោកស្រីសហព្រះរាជអាជ្ញារម្លឹកឡើងវិញអំពីសក្ខីកម្មរបស់សាក្សីពីស្ថានភាពនៅទំនប់១មករា ។ សាក្សីបានផ្តល់សក្ខីកម្មថា ស្ថានភាពនៅទំនប់១មករា គឺដូចគ្នាទៅនឹងការដ្ឋានទំនប់ត្រពាំងថ្ម ។ ប្រជាជនធ្វើការតាំងពីទាបភ្លឺរហូតដល់ពាក់កណ្តាលយប់ អ្នកដែលឈឺត្រូវបានចាត់ទុកថា ខ្ជិល និងត្រូវបានដាក់ពិន័យ (ចាត់ឲ្យធ្វើការយូរ ទទួលបានរបបតិច និងវាយធ្វើបាប) ។ នៅការដ្ឋានមានជំងឺផ្សេងៗដូចជា គ្រុនចាញ់ រាគមួល និងអាសន្នរោគ ។ មិនមានថ្នាំព្យាបាល ឬការថែទាំសុខភាពទេ ។ រុយ មាននៅគ្រប់ទីកន្លែង ហើយគ្រប់វែកដួសសម្ល គឺមានរុយ ។ ស្ត្រីមិនមានការថែរក្សាអនាម័យក្នុងអំឡុងវដ្តនៃរដូវរបស់ខ្លួន ដែលនេះជាការប្រមាថមួយចំពោះស្ត្រី ។ មនុស្សរាប់ពាន់នាក់ដែលធ្វើការនៅទំនប់១មករា តែនៅទីនោះគ្មានបង្គន់ទេ ។ សាក្សីបាននិយាយថា អ្នកមិនអាចលាក់ខ្លួនពីរុយរាប់ពាន់ក្បាលដែលហើរទៅរកអ្នកបានទេ ហើយក៏មិនអាចលាក់ក្លិនលាមកមនុស្ស៣០០០០នាក់ ដែលកំពុងបន្ទោរបង់នៅនឹងដីបានដែរ ។

លោកស្រីសហព្រះរាជអាជ្ញាបានធ្វើការសរុបថា តាមរយៈសក្ខីកម្មនេះបានបង្ហាញឲ្យឃើញថា ប្រជាជនត្រូវបានដាក់ឲ្យទៅជាទាសករ ប្រជាជនមិនមានជម្រើសក្នុងការងារ ហើយគ្រប់យ៉ាងនៃជីវិតរបស់ខ្លួន ត្រូវបានគ្រប់គ្រងដោយបក្ស ។ ប្រជាជនមិនអាចធ្វើដំណើរដោយសេរី ។ យោធាដែលប្រដាប់ដោយអាវុធយាមល្បាតនៅការដ្ឋានដើម្បីចៀសវាងមានការរត់គេច និងប្រាកដថាប្រជាជនធ្វើការខ្ជាប់ខ្ជួន ។ ជោគវាសនារបស់ប្រជាជនដែលមិនអាចទ្រាំទ្របាននឹងផែនការរបស់អង្គការ ត្រូវបានចាត់ទុកថា ជាខ្មាំង ហើយនឹងត្រូវកម្ទេច ដោយសារតែធ្វើឲ្យរាំងស្ទះដល់ដំណើរការសាងសង់ ។

**ខ.ក្រិដ្ឋកម្មនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង**

ការដ្ឋានការងារព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានប្រើប្រាស់សម្រាប់ដាក់ពិន័យ និងកសាងកងទ័ពបដិវត្តន៍កម្ពុជា មកពីតំបន់ដែលអ្នកទាំងនោះត្រូវបានដកសេចក្តីទុកចិត្តពីថ្នាក់ដឹកនាំ ដូចជា កងទ័ពភូមិភាគឧត្តរ និងភូមិភាគបូព៌ា ។ អ្នកធ្វើការនៅការដ្ឋានក៏មានទាហានពិការទៀតផង ។ ប្រជាជនធ្វើផ្លូវពីរដែលមានប្រវែង ២,៨គីឡូម៉ែត្រ ហើយនឹងប្រព័ន្ធផ្លូវទឹកក្រោមដីជាច្រើនដែលចេញពីភ្នំ ដូចជាការដ្ឋានការងារដទៃដែរ ភាគច្រើននៃសមាជិកមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា បានមកពិនិត្យនៅការដ្ឋាននេះមានដូចជា ខៀវ សំផន និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដទៃទៀត ។

លោកស្រី ជា លាង បានធ្វើការសង្ខេបអំពីភ័ស្តុតាងដែលទាក់ទងនឹងសក្ខីកម្មរបស់សាក្សី ។ វាគ្មានថ្ងៃឈប់សម្រាក អាហារត្រូវបានផ្តល់ឲ្យពីរពេលក្នុងមួយថ្ងៃ ហើយប្រជាជនទាំងអស់ធ្លាក់ខ្លួនស្គម និងឈឺ ។ អ្នកគ្រប់គ្រងជនជាតិចិននៅការដ្ឋានមានអាហារយ៉ាងច្រើន និងជប់លៀងរៀងរាល់សប្តាហ៍ ។ សាក្សីបានពិពណ៌នាថា វាពិតជាហត់នឿយខ្លាំងណាស់ ចំពោះការធ្វើការហួសកម្លាំង និងកង្វះម្ហូបអាហារ ។ ប្រជាជនត្រូវធ្វើការរហូតដល់ធ្លាក់ខ្លួនឈឺ ហើយត្រូវបានចោទប្រកាន់ថាជាខ្មាំង ទោះជាប្រឹងធ្វើការរហូតដល់ដួល ដោយសារតែស្គម និងអស់កម្លាំងក៏ដោយ ។ សត្វបៃបានចម្លងមេរោគទៅប្រជាជន ប្រជាជនត្រូវផឹកទឹកព្រែក ដែលជាកន្លែងតែមួយសម្រាប់ផ្គូតទឹក ។ ការបំផ្ទុះរូងភ្នំនៅការដ្ឋានបានធ្វើឲ្យប្រជាជនដែលធ្វើការនៅទីនោះរងរបួស ឬស្លាប់ ដោយសារខ្ទាតកម្ទេចថ្មត្រូវ ពីព្រោះមិនអាចរត់បានលឿនបន្ទាប់ពីការបំផ្ទុះ ។ ការដំឡើងការបំផ្ទុះថ្មនេះ គឺជាវិធីនៃការសម្លាប់មួយ ហើយគ្មាននរណាម្នាក់ខ្វល់ពីសុខភាព ឬសុវត្ថិភាពប្រជាជនទេ ។ ប្រជាជនមិនមានសិទ្ធិចាកចេញពីការដ្ឋានទេ និងត្រូវត្រួតពិនិត្យយ៉ាងតឹងរ៉ឹងពីសំណាក់កងការពារ ។ ប្រជាជនមិនត្រូវបានអនុញ្ញាតផ្លាស់ទីដោយសេរីទេ ដែលធ្វើឲ្យអ្នកទាំងអស់គ្នាហៅការដ្ឋាននេះថា ជាគុកឥតជញ្ជាំង ។ ប្រជាជនតម្រូវឲ្យបញ្ចប់ការងារតាមផែនការកំណត់ ទោះបីជាត្រូវចំណាយពេលយូរយ៉ាងណាក៏ដោយ ។

លោកស្រីសហព្រះរាជអាជ្ញាបានផ្តល់ជាយោបល់ថា ភ័ស្តុតាងនៃការបង្ខិតបង្ខំចំពោះការដាក់ឲ្យទៅជាទាសករ គឺជាឯកសារភ័ស្តុតាងលើអ្វីដែលបានកើតឡើងចំពោះអ្នកដែលព្យាយាម

រត់គេចទាំងនោះ ។ នៅក្នុងរបាយការណ៍ប្រចាំខែមួយ ក្នុងឆ្នាំ ១៩៧៨ ទ័ពតំបន់បានចាប់បានខ្មាំងបីនាក់ ដែលព្យាយាមរត់គេចពីតំបន់ព្រលានយន្តហោះ ។ តំបន់បានរាយការណ៍ថា ទ័ពតំបន់បានបាញ់ប្រហារ ចាប់ខ្លួនអ្នកទាំងនោះ ហើយម្នាក់ក្នុងចំណោមនោះត្រូវបានបញ្ជូនទៅកន្លែងអប់រំ ដើម្បីសួរចម្លើយ ។ ភូមិភាគបស្ចិមរាយការណ៍ រួមមាន ខាងតំបន់ព្យាយាមរត់គេចពីការដ្ឋានការងារ ហើយភូមិភាគពាយ័ព្យរាយការណ៍លម្អិតអំពីការស៊ើបអង្កេត ការតាមចាប់ ការបាញ់ប្រហារ និងការសម្លាប់ខ្មាំងដែលព្យាយាមរត់គេច ។ ទាំងនេះ បានកើតឡើងក្នុងតំបន់ផ្សេងគ្នា និងឆ្នាំផ្សេងគ្នា ។ លោកស្រី ជា លាង បានកត់សម្គាល់ឃើញថា អ្នកទាំងអស់គ្នាបានពិពណ៌នាចម្លើយដូចគ្នាចំពោះការរត់គេចពីការដ្ឋានព្រលានយន្តហោះ ។

## ឧក្រិដ្ឋកម្មនៅសហករណ៍ត្រាំកក់

បន្ទាប់មក លោកស្រី ជា លាង បានរម្លឹកអំពីឧក្រិដ្ឋកម្ម និងភស្តុតាងដែលទាក់ទងនឹងស្រុកត្រាំកក់ ស្ថិតក្នុងភូមិភាគនិរតី ។ នៅឆ្នាំ១៩៧៧ និង១៩៧៨ គណៈកម្មាធិការមជ្ឈិម ផ្តល់កិត្តិយសដល់សហករណ៍សម្រាប់កិច្ចខំប្រឹងប្រែងបង្កើនផលិតផលកសិកម្មរបស់ខ្លួន និងចាត់ទុកវាជាគំរូសម្រាប់ប្រទេសទាំងមូល ។ នៅក្នុងឆ្នាំ១៩៧៧ នួន ជា និង ខៀវ សំផន បានទៅទស្សនាត្រាំកក់ជាមួយនឹង តា ម៉ុក និងអ្នកដទៃទៀត ។ សាក្សីដែលបានមកផ្តល់សក្ខីកម្មអំពីត្រាំកក់ រួមមាន ប្រជាជនមូលដ្ឋាន ប្រជាជនថ្មី អតីតមេឃុំបីនាក់ កម្មាភិបាលដែលជាអតីតប្រធានពេទ្យស្រុក អ្នកទោស អ្នកយាម អ្នកអប់រំកសាងស្រុក ហើយនឹងអតីតលេខាស្រុកពីរនាក់ ។ បន្ថែមលើសក្ខីកម្មរបស់សាក្សី មានឯកសាររាប់រយដែលបង្ហាញថា ឧក្រិដ្ឋកម្មបានកើតឡើងនៅទីនោះ ។

លោកស្រី ជា លាង បានអះអាងថា ភស្តុតាងបានបង្ហាញថា ទីនោះពិតជាត្រូវបានគ្រប់គ្រងដោយអង្គការ ទាំងការងារ អាហារ ជីវិតគ្រួសារ គំនិត និងការបំលាស់ទី ។ សាក្សីម្នាក់បាននិយាយថា សកម្មភាពតែមួយគត់ដែលត្រូវបានអនុញ្ញាតឲ្យធ្វើគឺហូបចុក ដេក និងធ្វើការ ។ សូម្បីតែទៅបន្ទប់ទឹក ក៏ត្រូវតែស្នើសុំការអនុញ្ញាតពីប្រធានកងដែរ ។ ទ្រព្យសម្បត្តិឯកជនត្រូវបានអង្គការដកហូត សូម្បីតែរើសស្វាយ ឬដូង អ្វីផ្សេងទៀតនៅតាមវាល ក៏មិនត្រូវបានអនុញ្ញាតដែរ ។ កូនដែលមានអាយុ១៣ឆ្នាំម្នាក់របស់សាក្សី ត្រូវបានយកទៅសម្លាប់ ព្រោះតែរើសដំឡូង ។ គ្រួសារត្រូវបានបំបែកចេញពីគ្នា ដោយប្តីនៅកងបុរស ប្រពន្ធនៅកងនារី និងកូនៗ នៅកងយុវជន យុវនារី ។ ក្មេងៗត្រូវបានវាយធ្វើបាបចំពោះការព្យាយាមមកជួបឪពុកម្តាយ ។ ស្ត្រីមានផ្ទៃពោះត្រូវបានបង្ខំឲ្យធ្វើការធ្ងន់ ដូចជា រើសអាចម៍គោ ។ សាក្សីម្នាក់ដែលពេលនោះនាងកំពុងមានផ្ទៃពោះបាននិយាយថា នាងឈឺនៅពេលព្រឹក ហើយនាងត្រូវបានចោទថា ពុតឈឺ និងខ្ជិល ។

ដូចជាការដ្ឋានដទៃដែរ របបអាហារ គឺមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ប្រជាជនទេ ប្រជាជនបានត្រឹមតែទទួលរបបបាយមួយស្លាបព្រា និងត្រូវធ្វើការជាទម្ងន់ដើម្បីបបរមួយកូនចាន ។ នៅពេលដែលប្រជាជនធ្លាក់ខ្លួនឈឺ ប្រជាជនត្រូវទទួលភាពកាន់តែលំបាកទៀត ហើយចំពោះអ្នកដែលមិនអាចធ្វើការបាន គឺត្រូវបានកាត់របបអាហារ ។ អតីតអនុប្រធានពេទ្យស្រុកត្រាំកក់ បានផ្តល់សក្ខីកម្មអំពីការផ្តល់អាហារមិនគ្រប់គ្រាន់នៅការដ្ឋានការងារ និងនិយាយថា ការផ្តល់អាហារមិនគ្រប់គ្រាន់រឹតតែអាក្រក់ទៅទៀតបើរបបនេះនៅតែបន្ត ។ គាត់បានប្រាប់ទៅមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាថា មានប្រជាជនច្រើននៅក្នុងមន្ទីរពេទ្យ ពីព្រោះមិនមានអាហារគ្រប់គ្រាន់ ហើយជាលទ្ធផល គាត់ត្រូវចោទប្រកាន់ចំពោះការវាយប្រហារសហករណ៍ ហើយសំណើរបស់គាត់ដើម្បីបង្កើនរបបអាហារត្រូវបានបដិសេធ ។

លោកស្រីសហព្រះរាជអាជ្ញាបានអះអាងថា មនុស្សជាច្រើនត្រូវបានចាប់ខ្លួន និងបាត់ខ្លួន បន្ទាប់ពីតវ៉ាចំពោះស្ថានភាពអមនុស្សធម៌នេះ ។ វាគឺជាឯកសារភស្តុតាងគាំទ្រអំពីការកង្វះអាហារ ការតវ៉ារបស់ប្រជាជន ហើយនឹងការប្រព្រឹត្តចំពោះការតវ៉ារបស់ប្រជាជន ។

លោកស្រី ជា លាង បានសរុបថា ឧក្រិដ្ឋកម្មនៃការដាក់ឲ្យទៅជាទាសករ ហើយនឹងសកម្មភាពអមនុស្សធម៌ផ្សេងៗ ត្រូវបានបង្ហាញយ៉ាងច្បាស់លើសពីវិមតិសង្ស័យ ។

**(តទៅលេខក្រោយ)**

**រ៉ូនិត អារី**

# គរុសិស្សភូមិភាគបាត់ដំបង សិក្សាពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានបើកវគ្គបណ្ដុះបណ្ដាលគរុសិស្ស ស្ដីអំពី «វិធីសាស្ត្រនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ ១៩៧៥-១៩៧៩)» ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៧ នៅសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតក្នុង បរិវេណវិទ្យាស្ថានជាតិអប់រំ អគារ (H) ។ កម្មវិធីនេះ មានការចូលរួមពីសំណាក់សិក្ខាកាម ដែលជាគរុសិស្ស មកពីសាលាគរុកោសល្យភូមិភាគខេត្តបាត់ដំបង និងគ្រូឧទ្ទេសថ្នាក់ជាតិ ក៏ដូចជាអ្នកជំនាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មកធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ទន្ទឹមនេះ សិក្ខាកាមក៏ត្រូវបានផ្ដល់ឱកាសឲ្យទៅទស្សនកិច្ចសិក្សានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងបឹងជើងឯកដែរ ។

វគ្គបណ្ដុះបណ្ដាលនាពេលនេះ នឹងផ្ដល់ដល់សិក្ខាកាមដែលចូលរួមទាំងអស់នូវព័ត៌មាន និងចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាវិធីសាស្ត្រថ្មីក្នុងការបង្រៀន ។ វគ្គបណ្ដុះបណ្ដាលនេះរំពឹងថា សិក្ខាកាមម្នាក់ៗនឹងក្លាយទៅជាអ្នកអប់រំ ដែលមានចំណេះដឹងនៅថ្ងៃអនាគត ដែលអាចបង្រៀនសិស្សអំពីប្រវត្តិសាស្ត្រខ្លួនឯង និងពិភាក្សារឿងរ៉ាវក្នុងអតីតកាលជាមួយនឹងអ្នករស់រានជីវិតពីរបបខ្មែរក្រហម ជាមួយក្រុមគ្រួសារ ក៏ដូចជាសហគមន៍របស់ខ្លួន ។ ការបង្កើតឲ្យមានការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន មិនត្រឹមតែជួយថែរក្សាការចងចាំពីភាពឈឺចាប់របស់អ្នករួចជីវិត និងបាត់បង់ជីវិតប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងជួយទប់ស្កាត់អំពើឃោរឃៅមិនឲ្យវិលត្រឡប់មកវិញដែរ ។ ស្របតាមវត្ថុបំណងនៃវគ្គបណ្ដុះបណ្ដាលរួមមាន ៖ ១) អភិវឌ្ឍចំណេះដឹងគរុសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ២)



គរុសិស្សមកពីភូមិភាគខេត្តបាត់ដំបង ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)» ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៧ នៅសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ។

អភិវឌ្ឍជំនាញគរុកោសល្យដល់គរុសិស្សពីរបៀបបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៣) អភិវឌ្ឍសមត្ថភាពរបស់គរុសិស្សឲ្យចេះប្រើប្រាស់បទពិសោធរបស់សាក្សី ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់ប្រើប្រាស់នៅពេលដែលគរុសិស្សនឹងបង្រៀននៅក្នុងថ្នាក់នាពេលអនាគត ។ ៤) បង្កើនប្រសិទ្ធភាព និងនិរន្តរភាពនៃកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ ជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅតាមសាលាក្នុងសហគមន៍ ។ ៥) បង្កើនប្រសិទ្ធភាព និងនិរន្តរភាពនៃកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ ជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅកម្រិតសកលវិទ្យាល័យ ។ គរុសិស្សមកពីគរុកោសល្យភូមិភាគបាត់ដំបង បានផ្តល់ជាទស្សនៈផ្ទាល់ខ្លួនចំពោះវគ្គបណ្តុះបណ្តាលនេះ ដូចខាងក្រោមៈ

◆ **វ៉ាត់ បញ្ញា ជាគរុសិស្សផ្នែកប្រវត្តិសាស្ត្រ និងភូមិវិទ្យា** បានឲ្យដឹងថា កន្លងមក ខ្ញុំធ្លាប់បានដឹងពត៌មានអំពីរបបខ្មែរក្រហមតាមរយៈឯកសារ ការផ្សព្វផ្សាយ និងចាស់ទុំនិយាយប្រាប់ ។ តាមរយៈការសិក្សាប៉ុន្មានថ្ងៃនេះ ខ្ញុំគិតថា ពិតជាមានសារសំខាន់ណាស់សម្រាប់ខ្ញុំដែលនឹងក្លាយជាគ្រូបង្រៀននៅពេលខាងមុខ ។ ការចូលរួមវគ្គបណ្តុះបណ្តាលនេះ មិនត្រឹមតែឲ្យខ្ញុំទទួលបានចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមប៉ុណ្ណោះទេ ថែមទាំងទទួលបាននូវបទពិសោធន៍ និងវិធីសាស្ត្របង្រៀនល្អៗថែមទៀត ។ ខ្ញុំនឹងយកអ្វីដែលបានរៀននៅក្នុងវគ្គបណ្តុះបណ្តាលនេះទៅអនុវត្តក្នុងវិធីសាស្ត្របង្រៀនរបស់ខ្ញុំ ។

◆ **កៅ សុភាព ជាគរុសិស្សផ្នែកប្រវត្តិវិទ្យា និងភូមិវិទ្យា** បានរៀបរាប់ថា ខ្ញុំបានដឹងពត៌មានអំពីរបបខ្មែរក្រហម តាមរយៈការអានឯកសារ ការនិយាយប្រាប់ពីឪពុកម្តាយ ចាស់ទុំ និងប្រពន្ធផ្សព្វផ្សាយនានា ។ ខ្ញុំបានជ្រើសរើសមុខវិជ្ជាប្រវត្តិវិទ្យា និងភូមិវិទ្យា ព្រោះខ្ញុំចង់ដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន និងការស្រឡាញ់នូវមុខវិជ្ជានេះផង ។ បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលប៉ុន្មានថ្ងៃនេះ ខ្ញុំយល់ថាវគ្គបណ្តុះបណ្តាលនេះល្អខ្លាំងណាស់ ។ តាមរយៈការសិក្សានេះ អាចជួយខ្ញុំពង្រីកចំណេះដឹងរបស់ខ្លួនបន្ថែមទៀត ហើយធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ខ្ញុំគិតថា ក្នុងនាមជាកូនខ្មែរ គឺត្រូវតែដឹងអំពីប្រវត្តិសាស្ត្រពីអតីតកាលរបស់ខ្លួនគ្រប់សម័យកាល តើពីសម័យកាលមួយទៅសម័យកាលមួយមានការប្រែប្រួលយ៉ាងណា ។ មិនត្រឹមតែប៉ុណ្ណោះ វគ្គបណ្តុះបណ្តាលនេះនឹងជួយពង្រឹងសមត្ថភាពខ្ញុំក្នុងការបង្រៀនថែមទៀត ទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

◆ **ឈើយ មួយ ជាគរុសិស្សផ្នែកប្រវត្តិវិទ្យា និងភូមិវិទ្យា** បានផ្តល់ជាទស្សនៈផ្ទាល់ខ្លួនថា វគ្គបណ្តុះបណ្តាលនេះ ពិតជាល្អប្រសើរណាស់សម្រាប់ខ្ញុំ ។ ខ្ញុំទទួលបានបទពិសោធល្អជាច្រើន ទាំងការសិក្សារៀនសូត្រ និងការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំជាក្មេងដែលកើតក្រោយរបបខ្មែរក្រហម ប៉ុន្តែ ខ្ញុំបានដឹងពីរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម តាមរយៈការអានឯកសារផ្សេងៗ ។ ដោយមានការចាប់អារម្មណ៍ខ្លាំងទាក់ទងនឹងប្រវត្តិសាស្ត្រ ទើបធ្វើឲ្យខ្ញុំជ្រើសរើសយកមុខវិទ្យាប្រវត្តិសាស្ត្រ ម្យ៉ាងទៀតដោយខ្ញុំមានចិត្តស្រឡាញ់មុខវិជ្ជានេះ និងមានបំណងបង្រៀនដល់ក្មេងៗជំនាន់ក្រោយឲ្យបានដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ **ធាវ សារៈមុនិន្ទ**

## ស្វែងរកការពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# សំណល់បន្សល់ពីសង្គ្រាម និងសន្តិភាព

**បទពិសោធន៍មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ផ្នែកមួយៈ**

**១) ទាក់ទងនឹងមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា ប្រាសាទព្រះវិហារ និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង**

អ្វីដែលនៅសេសសល់ពីសង្គ្រាម ព្រមទាំងជាសាក្សី ឬភ័ស្តុតាងរម្លឹកដល់បញ្ហានា អតីតកាលបាននោះ មាននៅសព្វទិសទីពេញប្រទេសកម្ពុជា ។ មួយចំនួនគឺជាប្រជាជនដែលធ្លាប់រងទុក្ខនាសម័យខ្មែរក្រហម ហើយគាត់យកបទពិសោធន៍ដែលបានជួបប្រទះមកអប់រំអ្នកជំនាន់ក្រោយ ឬខ្ទង់ទិសដល់អ្នកដែលបាត់បង់ជីវិត តែអកុសលសំណល់មួយចំនួនវិញ ទៅជាផ្តល់សេចក្តីរងទុក្ខលំបាកវេទនាជាបន្តបន្ទាប់នៅពាសពេញប្រទេស ។ សំណល់នេះ គឺសំដៅទៅមីនបង្កប់ក្នុងដីដែលនៅសេសសល់ បានបំផ្លិចបំផ្លាញ គ្រួសារ និងសហគមន៍ជាច្រើនខេត្ត ។ ទោះបីជាប្រទេសកម្ពុជាបានជួបប្រទះសន្តិភាពចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ក្តី ការបោសសំអាតមីនសេសសល់ក្នុងប្រទេសទាំងប៉ុន្មាន ត្រូវការពេលរាប់ទសវត្សរ៍ និងកិច្ចសហប្រតិបត្តិការយ៉ាងយកចិត្តទុកដាក់រវាងស្ថាប័នជាតិ និងអន្តរជាតិ ។



អតីតយោធាខ្មែរក្រហមនៅអន្លង់វែង ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ១៩៩៨

នៅពេលកម្លាំងខ្មែរក្រហមដ៏ធំចុងក្រោយ បានធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលភ្នំពេញនៅឆ្នាំ១៩៩៨ ផ្ទៃដីជាច្រើនគ្របដណ្តប់ដោយមីន ដែលត្រូវបានពង្រាយក្នុងអំឡុងសង្គ្រាមឈ្លបរបស់ទ័ពព្រៃខ្មែរក្រហមនាគ្រានោះ ។ ឆ្នាំ១៩៩២ អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា បានចាត់មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន កម្ពុជាក្នុងការជួយជនភៀសខ្លួនពីស្រុកកំណើតនៅពេលមានសង្គ្រាម ដើម្បីឲ្យប្រជាជន បានត្រឡប់ទៅផ្ទះវិញដោយសុវត្ថិភាព ។ បច្ចុប្បន្ន មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា គឺជាអង្គការកម្ចាត់មីនដ៏ធំជាងគេនៅក្នុងប្រទេសកម្ពុជា ដែលដើរតួឯករាជ្យក្នុងការបន្តបេសកម្មដើម្បីបំបាត់មីន ក្នុងប្រទេស ។ មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា ព្រមទាំងអ្នកឧបត្ថម្ភយល់ថា ការកម្ចាត់មីនគឺមានសារសំខាន់ណាស់ សម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងអភិវឌ្ឍជីវភាពរស់នៅរបស់សហគមន៍ប្រជាជនកម្ពុជា ។

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧ មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជាបានបើកសម្ពោធសារៈមន្ទីរសន្តិសុខនៃសកម្មភាពកម្ចាត់មីននៅខេត្តសៀមរាប និងបានប្រារព្ធពិធីឡើងជាផ្លូវការដើម្បីទទួលវិភាគទានពីរដ្ឋាភិបាលជប៉ុនចំនួន១១លានដុល្លារ ក្នុងកិច្ចការប្រើងប្រែងកម្ចាត់មីន ។ ក្នុងនោះ មានវត្តមានរបស់មន្ត្រីរដ្ឋការនៃរដ្ឋាភិបាលទាំងពីរ ដោយរួមជាមួយរដ្ឋមន្ត្រីការពារជាតិកម្ពុជា ទៀ បាញ់ និងអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជា *Hidehisa Horinouchi* ។ អ្នកស្រុករាប់រយនាក់ដែលមកពីសហគមន៍ជាប់ៗ

គ្នា ក៏មានវត្តមាន ចូលរួមក្នុងកម្មវិធីនេះដែរ ។ សារៈមន្ទីរនឹងផ្តល់ឲ្យអ្នកទស្សនាបានឃើញពីប្រវត្តិសាស្ត្រនៃកិច្ចខំប្រឹងប្រែងកម្ចាត់មីនរបស់មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជាក្នុងសម័យកាលបន្ទាប់ពីសង្គ្រាម ។ សំខាន់ជាងនេះទៅទៀត សារៈមន្ទីរសន្តិសុខនៃសកម្មភាពកម្ចាត់មីន មានគោលបំណងអប់រំដល់អ្នកទស្សនាអំពីផលប៉ះពាល់យូរអង្វែងនៃសង្គ្រាម និងការទាមទារសន្តិភាព ។ មន្ត្រីរដ្ឋការកម្ពុជា និងជប៉ុនបានសរឲ្យឃើញនូវស្មារតីការទូត ដែលអ្នកចូលរួមទាំងអស់បានយកធ្វើជាគំរូ ។ កម្មពិធីនេះតំណាងឲ្យការប្តេជ្ញាចិត្ត ការសហការ និងក្តីសង្ឃឹមនៃបេសកម្មបន្តរបស់មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជាក្នុងការកម្ចាត់មីនដែលនៅសល់នៅកម្ពុជា ។

លក្ខណៈការងារ និងគោលដៅនៃមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនដើម្បីសន្តិភាព និងភាពចម្រុងចម្រើន គឺមានភាពស្រដៀងគ្នាទៅនឹងគោលដៅរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ ការផ្តួចផ្តើមគំនិតរបស់វិទ្យាស្ថានស្ទីកវីតចំពោះអន្លង់វែង គឺកសាងឡើងដោយឈរទៅលើគោលការណ៍នៃភាពលូតលាស់អភិវឌ្ឍយូរអង្វែង និងមានលទ្ធភាពទ្រទ្រង់ខ្លួនឯង ហើយអាចប្រតិបត្តិការចុះសម្រុងយ៉ាងរលូនជាមួយសហគមន៍ និងដែនដី ។ ដើម្បីទាក់ទាញវិស័យទេសចរណ៍ ព្រមទាំងជួយដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ វិទ្យាស្ថានស្ទីកវីត នឹងផ្តោតការយកចិត្តទុកដាក់លើកិច្ចខំប្រឹងប្រែងបន្តរបស់មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនក្នុងការកម្ចាត់មីននៅក្នុងតំបន់ និងផ្តល់សុវត្ថិភាព និងសន្តិភាពផ្លូវចិត្តដល់សហគមន៍ ។

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងស្ថិតនៅលើភ្នំដងរែក ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ ។ តំបន់នេះ គឺចម្លែកស្រស់ស្អាត ទោះបីជាធ្លាប់ខ្ទេចខាំដោយសារសង្គ្រាម និងត្រូវបានប្រកាន់ដោយសង្គមសព្វថ្ងៃ ។ តំបន់ប្រវត្តិសាស្ត្រទាំង១៨កន្លែង ជាស្លាកស្នាមនៃបន្ទាយចុងក្រោយរបស់ខ្មែរក្រហម និងថ្នាក់ដឹកនាំកំពូល ប៉ុល ពត និងមេបញ្ជាការ តាម៉ុក ។ ភូមិដែលនៅជុំវិញពោរពេញដោយអតីតកម្មាភិបាលខ្មែរក្រហមជាច្រើន ដែលបានធ្វើចំណាកស្រុកមករស់នៅតំបន់នេះដើម្បីបង្កើតគ្រួសារ និងភូរពាស់ដីសម្រាប់កសិកម្ម ។ ប្រាសាទព្រះវិហារ ដែលជាកន្លែងមួយក្នុងបញ្ជីប្រវត្តិសាស្ត្រទាំង១៨ ស្ថិតនៅលើភ្នំលើព្រំប្រទល់ថៃ និងកម្ពុជា ។ ប្រាសាទនេះគឺធ្លាប់ជាទីកន្លែង និងប្រធានបទនៃជម្លោះព្រំប្រទល់ និងសង្គ្រាមស៊ីវិល ។ តំបន់នេះក៏ត្រូវបានជឿថាជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម មុនពេលដែលខ្មែរក្រហមត្រូវបានដេញពីរាជធានីនៅឆ្នាំ១៩៧៩ ។ ទោះបីជាយ៉ាងណា តំបន់នេះមិនត្រូវបានបើកជូនសាធារណជនរហូតដល់ឆ្នាំ១៩៩៨ ពីព្រោះតែកងទ័ពព្រៃបានបន្តប្រយុទ្ធនៅលើភ្នំដងរែក ។ សារសំខាន់ប្រវត្តិសាស្ត្ររបស់ប្រាសាទនេះ កាន់តែកើនឡើង ទោះបីទ្រង់ទ្រាយវាត្រូវបានខូចខាត និងផ្លាស់ជាដរាបដោយសារសង្គ្រាម និងជម្លោះរាប់ទសវត្សរ៍ ។

ការអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអន្លង់វែង គឺជាឱកាសក្នុងការលើកកម្ពស់នៃការយល់ដឹងបន្ថែមទៀតរបស់ចលនាខ្មែរក្រហម ។ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះ វាគឺជាឱកាសសម្រាប់ផ្សារភ្ជាប់សហគមន៍អន្លង់វែងទៅប្រទេសទាំងមូល និងចុងក្រោយទៅសហគមន៍អន្តរជាតិ ។ ការសហការជាមួយនឹងទីភ្នាក់ងារដូចជាមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា ដែលជាអ្នកចែករំលែកនូវគោលបំណងរួមនៃសន្តិភាព និងការអភិវឌ្ឍ បង្កើតភាពរឹងមាំដល់កិច្ចខំប្រឹងប្រែងរបស់វិទ្យាស្ថានស្ទីកវីតនៅអន្លង់វែង ។ ដោយមានការអះអាងថាដែនដីមាន សុវត្ថិភាព និងអាចរស់នៅបានឱកាសសម្រាប់ធ្វើដំណើរ និងទេសចរណ៍ក៏មានការកើនឡើងដូចគ្នា ។ ជាចុងបញ្ចប់សហប្រតិបត្តិការរួមនៅក្នុងតំបន់នេះនឹងជួយធ្វើសមាហរណកម្មសហគមន៍អន្លង់វែង ឲ្យចូលគ្នាជាមួយតំបន់ដទៃទៀតក្នុងប្រទេសកម្ពុជា ថែមទាំងផ្តល់ ការយល់ដឹងកាន់តែខ្ពស់ ការចេះយល់ចិត្តគ្នា និងការផ្សះផ្សាគ្នាចំពោះប្រទេសមួយដែល នៅតែកំពុងព្យាយាមកំណត់អត្តសញ្ញាណខ្លួនបន្ទាប់ពីសង្គ្រាមរាប់ទសវត្ស ។

**បទពិសោធន៍មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ផ្នែកពីរ ៖**

នៅពេលខ្មែរក្រហមត្រូវបានបណ្តេញចេញនៅឆ្នាំ១៩៧៩ សមាជិកជាច្រើនរួមទាំង ប៉ុល ពល បានរត់ជ្រកខ្លួននៅលើភ្នំដងរែក និងបន្តប្រយុទ្ធជាកងទ័ពព្រៃនៅផ្នែកខាងជើង ខាងក្រៅខេត្ត ។ កងទ័ពការពារដែលនៅសល់ទាំងប៉ុន្មានបានចុះចូលនឹងរដ្ឋាភិបាលកម្ពុជា នៅប្រាសាទព្រះវិហារឆ្នាំ១៩៩៨ ។ ទោះបីជាសកម្មភាពរបស់កងទ័ពបានបញ្ចប់ អតីតសមាជិកខ្មែរក្រហម និងគ្រួសារ នៅតែរស់នៅតំបន់ឆ្ងាយៗ ។ ខ្មែរក្រហមត្រូវបានផ្តាច់ឲ្យឆ្ងាយពីសង្គមកម្ពុជា ប៉ុន្តែខ្មែរក្រហមនៅតែប្រឈមមុខនឹងការលំបាកដដែល

ដើម្បីរស់ និងអភិវឌ្ឍឡើងវិញនៅក្នុងតំបន់ដែលបានហែកចែកដោយសង្គ្រាមរាប់ទសវត្សរ៍ ។ សមាជិកបក្សជាច្រើននាក់រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលជាកន្លែងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងតាំងនៅ ។ ទោះបីជាស្នាមប្រឡាក់របស់ខ្មែរក្រហម ឧក្រិដ្ឋកម្មសង្គ្រាម និងការសម្លាប់យ៉ាងឃោរឃៅតាមលងតំបន់នេះក៏ដោយ អ្នកភូមិនៅក្នុង សហគមន៍ទាំងនេះសម្តែងនូវភាពកក់ក្តៅ និងចិត្តសប្បុរស ដោយមិនអាចកាត់ថ្លៃបាន ។

អ្នកខ្លះបានពណ៌នាការផ្តាច់ខ្លួនរបស់អន្លង់វែងគឺជាលទ្ធផលនៃប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត ។ ហេតុផលគឺប្លែកៗគ្នាពីម្នាក់ទៅម្នាក់ ហើយស្មុគស្មាញខ្លាំង ។ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ ឱកាសសេដ្ឋកិច្ច និងប្រវត្តិជម្លោះព្រំដែនជាមួយប្រទេសថៃក៏រួមចំណែកដែរ ។ បច្ចុប្បន្នដោយការចិញ្ចឹមជីវិតមានភាពខ្សោយក្នុងផ្នែកជាច្រើននៅក្នុងតំបន់នោះ ប៉ុន្តែសក្តានុពលនៃការអភិវឌ្ឍ និងការបន្តសមាហរណកម្មគឺមានភាពច្បាស់លាស់ ។ ការងាររបស់សហការីអន្លង់វែងបានជួយរំលែកហើយទៅកាន់សហគមន៍ និងការរួមបញ្ចូលដូចជា ឱកាសអប់រំ និងសេដ្ឋកិច្ច ។ ការផ្លាស់ប្តូរនេះអាចត្រូវបានក្លាយជាសាក្សីនៅក្នុងការងាររបស់វិទ្យាស្ថានស្ទីករីត ដែលក្រុមការងារបានចុះសម្ភាសន៍ជាបុគ្គលជាមួយនឹងប្រជាជននៅអន្លង់វែង និងបង្កើតកម្មវិធីអប់រំសម្រាប់សិស្សនៅក្នុងស្រុក ។

ការបោះពុម្ពប្រវត្តិសាស្ត្រអំពីសម័យខ្មែរក្រហមគឺប្រធានបទដ៏ធំទូលាយ និងមិនពេញលេញ ព្រោះជាអំឡុងនៃសង្គ្រាម និងជម្លោះ ។ សហការីនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងស្វែងរកការពង្រីកនៃចំណេះដឹង និងការយល់ដឹងអំពីសម័យខ្មែរក្រហម និងសហគមន៍អន្លង់វែង ជាមួយនឹងបំណងដើម្បីធ្វើឲ្យមានការដឹងឮជាសកលលោក ។ ការសម្ភាសន៍ជាបុគ្គលត្រូវបានធ្វើឡើងដោយសហការី និងសិស្សវិទ្យាល័យក្នុងស្រុក គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីបន្ថែមនូវការយល់ដឹងពីសម័យខ្មែរក្រហម មនោគមវិជ្ជា និងផលប៉ះពាល់នៃប្រវត្តិសាស្ត្រលើកម្មាភិបាលខ្មែរក្រហមដែលរួចជីវិត និងគ្រួសារ ។

ដោយមនុស្សបានឆ្លងកាត់សម័យនោះពេលខ្លះមានការប្រុងប្រយ័ត្ន និងបានបង្ហាញពីបំណង ក៏ដូចជាតម្លាភាពនៅពេលដែលអ្នកសម្ភាសន៍បានទៅដល់ ។ សិស្សវិទ្យាល័យក្នុងស្រុកផ្តល់នូវផលប្រយោជន៍ទៅលើដំណើរការសម្ភាស និងការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ សិស្សទាំងអស់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលយ៉ាងសកម្មទៅលើរបបប្រល័យពូជសាសន៍ និងប្រវត្តិសាស្ត្រខ្មែរក្រហម មុនចុះសម្ភាសន៍ក្នុងភូមិជុំវិញ ។ បទពិសោធន៍ទាំងនេះ គឺមិនត្រឹមជាការអប់រំនោះទេ ប៉ុន្តែវាជាការផ្តល់អានុភាព យ៉ាងកត់សម្គាល់ទៅសិស្ស ។ យុវជននៅតំបន់នោះមានសមត្ថភាពក្នុងការទាក់ទង និងផ្លាស់ប្តូរសហគមន៍របស់ខ្លួន ដូច្នេះការផ្តល់ជំនាញការគិតស៊ីជម្រៅ និងឱកាសអប់រំ គឺសំខាន់ណាស់ដើម្បីផ្លាស់ប្តូរ និងបន្តឲ្យមានសន្តិភាព ។

ចក្ខុវិស័យរបស់មជ្ឈមណ្ឌលសន្តិសុខនៃតំបន់អន្លង់វែងគឺជាភាពទូលំទូលាយ ។ ពីការដាំដើមឈើ ការបង្កើតវគ្គបណ្តុះបណ្តាល និងការសហការជាមួយម្ចាស់ជំនួយបរទេស ក្នុងការអភិវឌ្ឍន៍ឧស្សាហកម្មទេសចរណ៍ជាចីរភាព ការផ្តួចផ្តើមរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក្នុងការស្នើនូវការសន្យា និងឱកាសសម្រាប់អន្លង់វែង ។ នៅពេលដែលសួរថាតើអ្នកស្រុកមានលក្ខខណ្ឌចំពោះការហូរចូលនៃទេសចរណ៍សម្រាប់អន្លង់វែង អ្នកស្រុក រួមទាំងអតីតកម្មាភិបាលខ្មែរក្រហម អ្នកទាំងអស់គ្នាស្វាគមជីវភាពបែបនេះ ។ ជាមួយនឹងបំណងដើម្បីបង្កើនសមាហរណកម្ម និងការលូតលាស់នៃសេដ្ឋកិច្ច មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនឹងអនុវត្តគម្រោងដែលផ្តល់ផលប្រយោជន៍ឲ្យបានច្រើន ដូចនឹងអ្នកវិនិយោគទុន និងអ្នកទស្សនាក៏សង្ឃឹមដើម្បីទាក់ទាញ ។

ជាចុងបញ្ចប់ របួសនឹងរលុបដោយការយល់ដឹងយ៉ាងវិសេសនៃអតីតកាល គឺជាការជោគជ័យក្នុងការភ្ជាប់សហគមន៍អន្លង់វែង និងការលើកកម្ពស់ការផ្សះផ្សា ។ ជាមួយនឹងការរួមចំណែករបស់យុវជនក្នុងតំបន់ មជ្ឈមណ្ឌលមណ្ឌលសន្តិភាពអន្លង់វែងក៏បានផ្តល់កម្ពុជា នូវឱកាសដ៏ប្រសើរដើម្បីយល់ និងកំណត់ប្រវត្តិសាស្ត្រដោយខ្លួនឯង ។ ដោយសង្គ្រាម ហាក់ដូចបានកើតឡើងភ្លាមៗ សន្តិភាពក៏នៅក្នុងដំណើរការតាមពេលវេលា ការយល់ដឹង ការព្យាបាល និងការតាំងចិត្តដើម្បីសេចក្តីថ្លៃថ្នូរនៃមនុស្ស ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានបង្ហាញការតាំងចិត្តដើម្បីដើរលើដំណើរការសន្តិភាព និងបន្តជំរុញគោលបំណងឲ្យដូចនឹងការអនុវត្តផ្តួចផ្តើមរបស់គម្រោង ។ **អ៊ីធី ថាយល័រ**

# ប្រសិនបើគ្មានរបបខ្មែរក្រហម យើងនឹងរស់នៅជុំគ្នា

***សាវតារ និងការរៀនសូត្រ***

ហ៊ឹម ណាឡា ជាគ្រូរបាំកើតនៅឆ្នាំ១៩៥៦ នៅសង្កាត់លេខ៦ រាជធានីភ្នំពេញ នៅក្នុងគ្រួសារមួយដែលមានឪពុកម្តាយប្រកបរបររកស៊ីបើកហាងលក់គុយទាវឈ្មោះ "គុយទាវកំពង់ត្រាំ" នៅម្តុំពេទ្យរុស្ស៊ី ។ ណាឡា ជាកូនស្រីទីប្រាំ នៅក្នុងចំណោមបងប្អូនចំនួន៨នាក់ ។ ណាឡា មានជីតាឈ្មោះ ប្រាជ្ញ ហ៊ឹម ជាអាចារ្យនៅវត្តថាន់ ។ ជីតារបស់គាត់បានទទួលគោរមងារពីសម្តេចព្រះបាទនរោត្តម សីហនុ ជាអាចារ្យវរៈវោហារ ប្រាជ្ញ ហ៊ឹម ។ សព្វថ្ងៃជីតារបស់គាត់រស់នៅជិតសាលាបឋមសិក្សាចៅពញាហុក ។

ណាឡា បានចូលរៀនថ្នាក់បឋមសិក្សានៅសាលាបឋមសិក្សាចៅពញាហុក ។ នៅទល់មុខសាលារបស់ ណាឡា មានវត្តមួយឈ្មោះវត្តថាន់ ហៅ វត្តនួនមុន្នីរាម ។ វត្តនេះ មានក្រុមល្ខោនហ្លួងមួយក្រុម ចេញពីក្រុមល្ខោនហ្លួងព្រះបរមរាជវាំង ដឹកនាំដោយ ឃុន ថាន់ កាលពីសម័យសង្គមរាស្ត្រនិយម ។ ឃុន ថាន់ បានបង្កើតថ្នាក់របាំតូចមួយនៅក្នុងសាលាបឋមសិក្សាចៅពញាហុក ។ ដោយសារតែទីតាំងវត្ត និងសាលារបស់គាត់នៅជិតគ្នាដូច្នេះក្រៅពីសិក្សាមុខវិជ្ជា គេហវិជ្ជា កីឡា និងមុខវិជ្ជាផ្សេងៗទៀតនៅក្នុងថ្នាក់ ណាឡា បានចំណាយពេលសិក្សាមុខវិជ្ជារបាំច្រើនជាងគេ ដោយសារចំណង់ចំណូលចិត្តរបស់គាត់ ទោះបីក្រុមគ្រួសារគាត់មិនមែនជាអ្នកសិល្បៈក៏ដោយ ។

នៅពេលរៀនដល់ថ្នាក់ទី៧ ជីតារបស់ ណាឡា បានស្នើសុំឪពុកម្តាយរបស់ ណាឡា យក ណាឡា ទៅហាត់របាំនៅក្នុងព្រះបរមរាជវាំង ដោយសារតែជីតារបស់គាត់យល់ឃើញថា គាត់មានទេពកោសល្យ និងមានរូបរាងសមជាអ្នករបាំ ។ ណាឡា បានរំឭកថា នៅសម័យនោះកម្រមានមនុស្សបានចូលហាត់សិល្បៈនៅក្នុងព្រះបរមរាជវាំងណាស់ ព្រោះការជ្រើសរើសតឹងរ៉ឹង ។ កាលដែលគាត់អាចចូលហាត់របាំបាន ព្រោះតែជីតារបស់គាត់ស្គាល់ហ្លួងសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសមៈនារីរ័ត្ន ។ មុននឹង ណាឡា ចូលគាល់សម្តេចព្រះមហាក្សត្រិយានី ជីតារបស់គាត់បានបង្ហាត់បង្រៀន និងណែនាំគាត់អំពីរបៀបរបប និង ឥរិយាបថដែលគាត់ត្រូវប្រណិប័តន៍ នៅក្នុងព្រះបរមរាជវាំង ។ នៅពេលចូលទៅដល់ក្នុងព្រះបរមរាជវាំង ហ្លួងសម្តេច ព្រះមហាក្សត្រិយានី ទ្រង់សព្វព្រះរាជហឫទ័យទទួលយក ណាឡា ឲ្យចូលហាត់សិល្បៈ ។ មិនតែប៉ុណ្ណោះ ទ្រង់បានព្រះរាជប្រទានខ្សែក្រវ៉ាត់ប្រាក់មួយខ្សែដល់គាត់ជាព្រះរាជអំណោយអនុស្សាវរីយ៍ ។ ចាប់តាំងពីពេលនោះមក ណាឡា បានចូលព្រះបរមរាជវាំង ហាត់ល្ខោនហ្លួងរៀងរាល់ថ្ងៃព្រហស្បតិ៍ ។ កាលពីដំបូង ណាឡា បានហាត់សម្តែងជាតួនាយរោង បន្ទាប់មក គាត់ហាត់សម្តែងតួនាង ជាមួយអ្នកគ្រូប៊ុណ្ណាត ។ ក្រោយមក ណាឡា បានហាត់សម្តែងជាតួយក្ស ។ អ្នកគ្រូ ប៊ុណ្ណាត គឺជាអ្នកសម្តែងតួឯក ជាតួមុន្នីមេខឡា ។



អ្នកគ្រូ ហ៊ឹម ណាឡា នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

ណាឡា តែងតែអង្គុយសញ្ជឹងគិតក្នុងចិត្តចង់ចេញទៅសម្តែងនៅខាងក្រៅ ដោយសារតែគាត់ចង់ពាក់មកុដរាំដូចសិស្សដទៃ ។ ថ្ងៃមួយអ្នកគ្រូ ប៊ុណ្ណាត បានហៅគាត់មកសួរថាតើគាត់បានរៀនចេះអ្វីខ្លះ ។ បន្ទាប់មកអ្នកគ្រូ ប៊ុណ្ណាត បានប្រើងបង្ហាត់បង្រៀន ណាឡា រហូត ណាឡា បានចូលរួមសម្តែងរបាំលើកដំបូងនៅព្រលានយន្តហោះពោធិ៍ចិនតុង នៅពេលដែលគណៈប្រតិភូបរទេសមកទស្សនកិច្ចនៅប្រទេសកម្ពុជា ។ ណាឡា បានរំឭកថា នៅពេលនោះខ្យល់បក់មកយ៉ាងខ្លាំង ម្យ៉ាងទៀតគាត់មានអារម្មណ៍ភិតភ័យ ព្រោះនោះជាការសម្តែងលើកទីមួយ ។ បន្ទាប់ពីសម្តែងចប់ ណាឡា បាននៅហាត់រៀនជាមួយអ្នកគ្រូ ប៊ុណ្ណាត បន្តទៀត ។ ពេលនោះ ណាឡា ទទួលបានប្រាក់ឧបត្ថម្ភ១០រៀល ក្នុងមួយខែ ក្នុងការហាត់រៀនសិល្បៈនៅក្នុងព្រះបរមរាជវាំង ។

ក្រោយពីហាត់របាំ ណាឡា បានបន្តការសិក្សារហូតប្រឡងជាប់ និងបានចូលរៀននៅវិទ្យាល័យអនុវត្ត ។ នៅពេលនោះ បងប្រុសរបស់គាត់បានទិញកង់មួយឲ្យគាត់ជាការលើកទឹកចិត្តដែលបានប្រឡងចូលរៀនដោយមិនបង់ប្រាក់ ។ ប៉ុន្តែ បងប្រុសរបស់គាត់បានជំរុញឲ្យគាត់បោះបង់ការហាត់សិល្បៈ ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សា ។ ផ្ទុយទៅវិញ ជីតា និងឪពុករបស់គាត់មិនយល់ស្របនឹងគំនិតបងប្រុសរបស់គាត់ទេ ។ ជីតា និងឪពុករបស់ ណាឡា បានបន្តលើកទឹកចិត្ត ណាឡា ឲ្យខិតខំប្រឹងប្រែងហាត់សិល្បៈថែមទៀតពីព្រោះអ្នកទាំងពីរចង់ឃើញ ណាឡា ចេញទៅសម្តែងសិល្បៈនៅបរទេស ។ ហេតុដូច្នេះ ណាឡា បានបន្តហាត់រៀនរបាំនៅក្នុងព្រះបរមរាជវាំងរហូតដល់ព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះបាទនរោត្តម សីហនុ ។

## ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០

បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ កិច្ចប្រជុំមួយត្រូវបានរៀបចំឡើងជាមួយសិស្ស ដែលធ្លាប់ហាត់រៀនសិល្បៈនៅក្នុងព្រះបរមរាជវាំង ដោយតម្រូវឲ្យសិស្សទាំងអស់ទៅចុះឈ្មោះចូលរៀននៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលមានទីតាំងនៅជិតក្រសួងអភិវឌ្ឍន៍ជនបទបច្ចុប្បន្ន ។ នៅពេលនោះ ណាឡា បានសម្រេចចិត្តឈប់ពីវិទ្យាល័យអនុវត្ត ដើម្បីបន្តការសិក្សាផ្នែកសិល្បៈ ។ មុននឹងអាចចូលសិក្សាបាន ណាឡា ត្រូវឆ្លងកាត់ការប្រឡងជាមុនសិន ។ វិញ្ញាសារប្រឡង រួមមាន ការសម្តែងសមត្ថភាពរាំ និងសំណេរ ។ ណាឡា បានប្រឡងជាប់ និងចូលរៀនឆ្នាំទី២ ។ នៅឆ្នាំ១៩៧៣ ណាឡា បានស្នើសុំអ្នកគ្រូ ជា សាមី ដែលជាគ្រូធំខាងសិល្បៈជួយដឹកនាំការប្រលងបញ្ចប់ថ្នាក់របស់គាត់ ។ ណាឡា បានជ្រើសរើសយកការសម្តែងរឿង "ព្រះសមុទ្រ ប៊ុត សុម៉ាលី" ។ បន្ទាប់ពី ណាឡា បញ្ចប់ការសិក្សា គាត់ក៏បានរៀបការជាមួយអតីតនិស្សិតផ្នែកគំនូរបុរាណ ឈ្មោះ អ៊ិន ស៊ីយ៉ុន្តា នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៤ ។

## របបខ្មែរក្រហម និងការជម្លៀសដោយបង្ខំ

ណាឡា រៀបការមិនបានប៉ុន្មានផង យោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ខ្មែរក្រហមបានបញ្ជាឲ្យគាត់ និងក្រុមគ្រួសារចាកចេញពីលំនៅដ្ឋានចំនួនបីថ្ងៃ ។ ពេលនោះ ឪពុករបស់គាត់បានបដិសេធ មិនព្រមចាកចេញទេរហូតដល់ពេលយោធាខ្មែរក្រហមបានមកដល់ផ្ទះ និងយកកាំភ្លើងមកគំរាម ទើបឪពុក និងក្រុមគ្រួសារសម្រេចចិត្តចេញតាមការបញ្ជា ។ នៅខណៈនោះ ប្តីរបស់ ណាឡា ក៏បានសុំចេញទៅរកម្តាយ និងបងប្អូននៅម្តុំគីរីរម្យ ប៉ុន្តែ ណាឡា បានអង្វរប្តីរបស់គាត់ឲ្យនៅរួមដំណើរជាមួយគ្នា ។

នៅតាមផ្លូវជម្លៀសចេញពីផ្ទះ ណាឡា បានធ្វើដំណើរជាមួយឪពុកម្តាយ ប្តី ប្អូនស្រីពីរនាក់ និងក្មួយពីរនាក់ ។ ក្រុមគ្រួសាររបស់ ណាឡា បានធ្វើដំណើរកាត់តាមអតីត ផ្ទះរបស់ លន់ នល់ សំដៅទៅក្បាលថ្នល់ ។ ណាឡា បានវង្វេងបាត់ប្តីរបស់គាត់នៅម្តុំវត្តចម្ប៉ា នៅពេលដែលប្តីរបស់អ្នកគ្រូដើរទៅរកទឹកដឹក ។ ដូច្នេះ ណាឡា និងក្រុមគ្រួសារក៏បានឈប់សម្រាកនៅវត្តចម្ប៉ាមួយយប់ ដើម្បីរង់ចាំជួបប្តីរបស់គាត់ មុននឹងបន្តដំណើរទៅមុខទៀត ។ នៅយប់នោះ ណាឡា បានឈរចាំមើលផ្លូវប្តីរបស់គាត់នៅខាងក្រៅវត្ត នៅពេលដែលមេឃកំពុងភ្លៀង ។ មួយសន្ទុះក្រោយមក ឡាណាបានឃើញប្តី ហើយគាត់ក៏បានស្រែកហៅឲ្យចូលមកសម្រាកនៅក្នុងវត្តជុំគ្នា ។ នៅពេលនោះ ណាឡា ក៏បានជួប បងប្រុសទីពីរ ឈ្មោះ ហ៊ឹម ណាទីម ជាទាហានជើងទឹក ព្រមទាំងប្រពន្ធកូនរបស់គាត់នៅវត្តចម្ប៉ាដែរ ។ ប៉ុន្តែ បងប្រុសទីពីររបស់ ណាឡា បានសុំលាឪពុកត្រឡប់ចូលមកទីក្រុងភ្នំពេញវិញតាមការកោះហៅរបស់

ខ្មែរក្រហម ព្រោះបងប្រុសគាត់គិតថានឹងបានចូលបម្រើការងារវិញ ។ ចាប់តាំងពីពេលនោះមក ណាឡា មិនឃើញបងប្រុសទីពីររបស់គាត់វិលមកទេ ។ មិនតែប៉ុណ្ណោះ ណាឡា ក៏បាត់ដំណឹងបងស្រីទីបីរបស់គាត់ឈ្មោះ ហ៊ឹម ណាលីន ដែលបានរៀបការជាមួយទាហាន លន់ នល់ ប្រចាំការនៅវិហារសួគ៌ ខេត្តកណ្តាល និងបងស្រីទីបួនឈ្មោះ ហ៊ឹម វណ្ណថារ៉ា ដែលជាពេទ្យឆ្មប ព្រមទាំងប្អូនស្រីទីប្រាំមួយឈ្មោះ ហ៊ឹម ណាលីស ជាសិស្សដែលបានបែកគ្នាពេលគាត់កំពុងរៀនដែរ ។

លុះដល់ថ្ងៃបន្ទាប់ ក្រុមគ្រួសាររបស់ ណាឡា បានបន្តដំណើរតាមវត្តកោះក្របី ជាទីដែលក្មួយស្រីម្នាក់របស់គាត់បានបាត់បង់ជីវិត ។ បន្ទាប់ពីបញ្ចុះសពក្មួយស្រីនៅវត្តកោះក្របីរួចរាល់ ណាឡា បានបន្តដំណើរឆ្លងទៅត្រើយម្ខាង ។ ក្រុមគ្រួសាររបស់ ណាឡា បានយកកង់ដែលយកមកជាមួយទៅឲ្យម្ចាស់ទូកជាថ្នូរនឹងការជួយចម្លងទឹក ។ បន្ទាប់ពីឆ្លងទឹករួច គ្រួសារ ណាឡា បានធ្វើដំណើរបន្តដោយថ្មើរជើង ។ ពេលទៅដល់ម្តុំសៀមរាបកន្ទួត ឪពុករបស់គាត់ចាប់ផ្តើមកើតជំងឺរាករូស ។ ដូច្នេះ ណាឡា ក៏បានសុំអ្នកបររទេះម្នាក់ឲ្យជួយដឹកឪពុករបស់គាត់ ដោយគាត់បានដាក់ចានឆ្នាំង និងអង្ករមួយចំនួននៅលើរទេះទុកសម្រាប់ឪពុករបស់គាត់ដាំបាយហូបតាមផ្លូវ ។ តាំងពីពេលនោះមក គាត់បានបែក និងបាត់ដំណឹងឪពុករបស់គាត់រហូត ។ មកដល់សព្វថ្ងៃ ណាឡា មិនដឹងថា ឪពុករបស់គាត់ស្លាប់នៅកន្លែងណាទេ ។

ក្រុមគ្រួសារ ណាឡា បានបន្តដំណើរទៅមុខរហូតដល់បត់រកា ខេត្តតាកែវ ។ អង្គការបានចាត់តាំងឲ្យគាត់ធ្វើស្រែ ចំណែកប្តីគាត់លើកភ្លឺស្រែ ដែលជាការងារដែលគាត់ទាំងពីរនាក់មិនធ្លាប់ធ្វើពីមុនមក ។ ក្រុមគ្រួសាររបស់ ណាឡា តែងស្ថិតនៅក្រោមការតាមដានរបស់អង្គការជាប្រចាំ ។ ជារឿយៗ ម្តាយរបស់ ណាឡា តែងលួចខ្សឹបប្រាប់ ណាឡា និងប្តីរបស់គាត់ឲ្យប្រយ័ត្នប្រយែងក្នុងការនិយាយស្តី ព្រោះប្តីរបស់ ណាឡា មានប្រវត្តិជាទាហាន លន់ នល់ ។ មិនយូរប៉ុន្មាន ក្មួយប្រុសរបស់ ណាឡា ដែលរួមដំណើរជាមួយគាត់បានស្លាប់បន្តទៀត ។

ថ្ងៃមួយ ម្តាយរបស់ ណាឡា បានយករូបថតបងស្រី ណាឡា ជាពេទ្យឆ្មបហែកចោល និងបោះចោលនៅក្បែរត្រពាំងទឹកមួយ ព្រោះបងស្រីរបស់ ណាឡា មានមុខមាត់ស្រដៀងនឹង ណាឡា ហេតុដូច្នេះម្តាយរបស់ ណាឡា ខ្លាចអង្គការមានការភាន់ច្រឡំ ។ ណាឡា បានបន្តថា ពេលនោះប្រហែលជាមានអ្នកភូមិបានឃើញ និងបានរាយការណ៍ប្រាប់អង្គការ ទើបគាត់ពុស្ទូរជើងមនុស្សដើរមកស៊ើបការណ៍ក្រោមផ្ទះរបស់គាត់រៀងរាល់យប់ ។ ទន្ទឹមនោះ មានអ្នកភូមិម្នាក់ដែលមានសន្តានចិត្តល្អ បានលួចប្រាប់គាត់ឲ្យប្រុងប្រយ័ត្នដែរ ព្រោះគ្រួសាររបស់គាត់កំពុងស្ថិតនៅក្រោមការតាមដានរបស់ឈ្លប ។

### ការជម្លៀសលើកទីពីរ (ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ)

នៅរដូវវស្សា ឆ្នាំ១៩៧៦ គ្រួសាររបស់ ណាឡា ត្រូវបានខ្មែរក្រហមជម្លៀសចេញពីសហករណ៍បត់រកា ខេត្តតាកែវ តាមរថយន្តសំដៅទៅខេត្តពោធិ៍សាត់ ដើម្បីរង់ចាំរថភ្លើងជិះបន្តទៅតំបន់៤ ខេត្តបន្ទាយមានជ័យ ។ ជារឿយៗ ណាឡា បានឃើញមនុស្សស្លាប់នៅតាមផ្លូវ ។ មកដល់ចំណតរថភ្លើង ប្រជាជនតម្រូវឲ្យស្វែងរកអាហារហូបដោយខ្លួនឯង ។ ប៉ុន្តែ គាត់ហូបមិនចូលទេ ដោយសារតែក្លិនស្អុយ និងស្អុះស្អាប ។ នៅពេលប្រជាជនឡើងជិះពេញរថភ្លើង ខ្មែរក្រហមបានដឹកប្រជាជនជម្លៀសទាំងនោះឆ្ពោះទៅសេរីសោភ័ណ ។ បន្ទាប់មក ខ្មែរក្រហមបានដឹក ណាឡា ម្តាយ និងប្អូនស្រីរបស់គាត់តាមរទេះគោទៅស្រុកភ្នំស្រុក ។ ដោយឡែកប្តីរបស់អ្នកគ្រូមិនត្រូវបានអនុញ្ញាតឲ្យជិះរទេះនោះទេ ។ ប្តីរបស់គាត់ត្រូវដើរតាមក្រោយរទេះ តែដោយសាររទេះបរលឿន ទើបប្តីរបស់គាត់ដើរមិនទាន់ ។ ប្តីរបស់គាត់បានដើរតាមរទេះផ្សេងវិញ ព្រោះរទេះទាំងនោះមានទិសដៅទៅភ្នំស្រុកដូចគ្នា ។ ណាឡា បានធ្វើដំណើរទៅដល់តំបន់ព្រៃកញ្ជរ ក្នុងស្រុកភ្នំស្រុក ដែលជាតំបន់គ្រុនចាញ់ ។ ប្តីរបស់ ណាឡា បានទៅរកគាត់ឃើញនៅទីនោះ ចំណែក ណាឡា បានវង្វេង ម្តាយ និងប្អូនស្រី ដែលបានឡើងជិះរទេះគោផ្សេង ។ ណាឡា បានរលូតកូននៅក្នុងផ្ទៃនៅពេលដែលគាត់ធ្វើដំណើរតាមរទេះគោដែលរលាក់នោះ ។ សំណាងល្អមួយសប្តាហ៍ក្រោយមក ណាឡា ក៏បានជួបម្តាយ និងប្អូនស្រីពីរនាក់នៅក្នុងភូមិវិញ ។

ថ្ងៃមួយមានខ្យល់ព្យុះបោកបក់មកយ៉ាងខ្លាំង បណ្តាលឲ្យខ្ទមរលំបាក់សង្កត់លើម្តាយរបស់គាត់ស្លាប់ ។ ប្អូនស្រីរបស់ ណាឡា

បានរត់មកប្រាប់ ណាឡា ពីដំណឹងអកុសលនេះ ហើយប្តីរបស់គាត់ក៏បានទៅជួយរុំសពម្តាយយកទៅបញ្ចុះ ។ ចំណែក ណាឡា មិនត្រូវបានអនុញ្ញាតឲ្យជួយប្តីរបស់គាត់ទេ ។ បន្ទាប់ពីម្តាយស្លាប់ ប្អូនស្រីពីរនាក់របស់ ណាឡា បានមករស់នៅជាមួយ ណាឡា វិញ ។

ណាឡា បានរំឭកថា នៅស្រុកភ្នំស្រុក គាត់បានឈឺជំងឺគ្រុនចាញ់ រហូតដល់កោរសក់ ។ មុខ និងក្បាលជន្គង់របស់គាត់ហើមធំ ចំណែក ដៃជើងប្រែជាស្គមកំព្រឹង ។ ណាឡា មិនបានទៅធ្វើការដូចប្រជាជនដទៃទេ ចំណែកប្តីរបស់គាត់ចេញទៅធ្វើការធម្មតា ។ នៅពេលសម្រាកពីការងារ ប្តីរបស់គាត់បានត្រឹមមកលួចមើលគាត់ពីចម្ងាយ ។ ចំណែកប្រជាជនដែលខ្មែរក្រហមជម្លៀសមកភ្នំស្រុកដូចគ្នា បានឆ្លៀតមកសួរសុខទុក្ខ ណាឡា មុននឹងដើរត្រឡប់ទៅខ្ទមដើម្បីសម្រាក ។ ប្រជាជនជាច្រើននៅទីនោះ បានស្លាប់ ដោយសារជំងឺគ្រុនចាញ់ ។ សាកសពរបស់អ្នកដែលបានស្លាប់ និងបានកប់នៅក្បែរៗខ្ទមរបស់ប្រជាជនស្នាក់នៅ ។

**ការជម្លៀសលើកទីបី (សហករណ៍តាភរ)**

នៅរដូវប្រូតកាត់ ឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀស ណាឡា ប្តី និងប្អូនស្រីទាំងពីរ តាមរទេះទៅកាន់សហករណ៍តាភរ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ ប្តីរបស់ ណាឡា បានដើររកថ្នាំមកឆ្អើរព្យាបាលប្អូនស្រីទាំងពីររបស់គាត់ដែលបានកើតដំបៅផារ ។ នៅសហករណ៍តាភរ អង្គការបានបញ្ជាឲ្យប្រជាជនធ្វើស្រែ និងត្រូវស្មោះត្រង់ជាមួយអង្គការ ។ ក្រៅអំពីការងារស្រែចម្ការ អង្គការបានចាត់តាំងឲ្យ ណាឡា បង្រៀនរបាំដល់កុមារនៅក្នុងសហករណ៍ ដែលជាកូនរបស់ប្រជាជនមូលដ្ឋាន ។ នៅទីនោះ ណាឡា បានជួបលោកតាម្នាក់ដែលធ្វើការខាងសង្គមកិច្ច ។ គាត់បានប្រាប់ ណាឡា ថា "អ្នកគ្រូមានជំងឺទាស់" ។ លោកតាម្នាក់នោះបានឲ្យថ្នាំ ណាឡា ផឹករហូតដល់អការៈជំងឺរបស់ណាឡាបានធូរស្រាលជាងមុន ។

នៅពេលនោះ កងឈ្លបតែងតែឡើងទៅឆែកឆេរផ្ទះរបស់ ណាឡា ជាញឹកញាប់ដើម្បីស៊ើបរកឯកសារ និងរបស់របរដែលពាក់ព័ន្ធនឹងប្រវត្តិសាវតារគ្រួសាររបស់គាត់ ព្រោះគ្រួសារគាត់ទើបនឹងជម្លៀសមក ។ ពេលខ្លះ ឈ្លបបានមកហៅប្តីរបស់គាត់ទៅសួរនាំអំពីប្រវត្តិរូបទាំងយប់ ។ នៅក្នុងសហករណ៍តាភរ ប្អូនស្រីម្នាក់របស់គាត់ត្រូវបានឈ្លបខ្មែរក្រហមសម្លាប់ ដោយសារប្អូនស្រីរបស់គាត់បានលួចពងមាន់មួយគ្រាប់ទុកហូប ។ ក្រោយមក



រូបខាងឆ្វេង ៖ អ្នកគ្រូ ហ៊ឹម ណាឡា កំពុងសំពះសែនគ្រូពាលី មុននឹងចាប់ផ្តើមពិធីសម្តែងសិល្បៈ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

មានអ្នកភូមិម្នាក់ (អតីតធ្លាប់បានបួសរៀន) បានមកលួចខ្សឹបប្រាប់ ណាឡា ថាឈ្មោះប្ដីរបស់គាត់ស្ថិតនៅក្នុងបញ្ជីឈ្មោះតាមដានរបស់ឈ្លប ។ ហេតុដូច្នេះ ប្រសិនបើអង្គការជម្លៀសចេញ ត្រូវតែចេញតាមបញ្ជាកុំនៅភូមិនេះតទៅទៀត ។

## ការជម្លៀសលើកទីបួន (សហករណ៍កាប់ចោរ)

មិនយូរប៉ុន្មាន អង្គការបានជម្លៀសគ្រួសារ ណាឡា ពីសហករណ៍តាភរ ទៅភូមិកាប់ចោរ ក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យវិញ ។ ខ្មែរក្រហមបានបំបែកប្អូនស្រីរបស់ ណាឡា ឲ្យទៅនៅក្នុងកងកុមារ ព្រមទាំងបានណែនាំឲ្យប្អូនស្រីរបស់គាត់ឲ្យតាមដាន និងរាយការណ៍អំពីសកម្មភាពរបស់គាត់ទៀតផង ។ ណាឡា មិនដឹងថា ប្អូនស្រីរបស់គាត់បានរាយការណ៍ឬយ៉ាងណាទេ បានជាឈ្លបខ្មែរក្រហមដឹងថា គាត់បានលួចដាំបាយនៅលើផ្ទះ ។ ល្ងាចនោះ ណាឡា បានយកអង្ករដែលបានមកពីការដោះដូរជាមួយរបស់របរដែលគាត់មាន មកដាំបាយហូប ។ នៅពេលដែលបាយឆ្អិន ស្រាប់តែកងឈ្លបបានមកដល់ ហើយបម្រុងនឹងយកឆ្នាំងបាយនោះមកវាយគាត់ថែមទៀត ។ ជាគុណបុណ្យ ណាឡា តែងតែជួបមនុស្សល្អ ដោយមានបុរសមូលដ្ឋានម្នាក់ឈ្មោះ នឿម បានរំឭកគ្រួសាររបស់គាត់ឲ្យប្រុងប្រយ័ត្នព្រោះអង្គការកំពុងតាមដាន ។

នៅទីនោះ មានរឿងរ៉ាវច្រើនតែងតែមកញាំញីក្រុមគ្រួសាររបស់ ណាឡា ។ ថ្ងៃមួយ វេលាម៉ោងប្រហែលប្រាំល្ងាច ឈ្លបបានមកចាប់ប្ដីរបស់ ណាឡា បន្ទាប់ពីស្ងោរដំឡូងមីឆ្អិន ដោយចោទថា "ប្ដីរបស់គាត់បានលួចដកដំឡូង" រួចហើយក៏យកប្ដីគាត់ទៅឃុំនៅក្នុងវត្តមួយ ។ ពេលឃើញហេតុការណ៍ដូច្នោះ ណាឡា ក៏បានរត់ទៅពឹងមិត្តនារីនៅក្នុងសហករណ៍ម្នាក់ឲ្យជួយ ។ ណាឡា បានប្រាប់មិត្តនារីនោះថា ប្ដីរបស់ខ្លួនត្រូវបានឈ្លបចាប់យកទៅហើយ ។ ណាឡា បានឲ្យដឹងថា មិត្តនារីម្នាក់នោះប្រហែលមានស្រុកកំណើតនៅខេត្តកំពតដូចប្ដីរបស់គាត់ បានជួយប្ដីគាត់ឲ្យបានរស់រានមានជីវិត ។ លុះទៀបភ្លឺ ប្ដីរបស់គាត់បានត្រឡប់មកដល់ផ្ទះវិញ ។ ណាឡា បានស្ដុះទៅឱបប្ដី ព្រមទាំងប្រាប់ប្ដីរបស់គាត់ឲ្យឈប់លួចដកដំឡូងទៀត ដើម្បីជៀសវាងឈ្លបមកចាប់យកទៅសម្លាប់ ។

នៅសហករណ៍កាប់ចោរ ណាឡា ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការជាអ្នកដាំបាយ នៅការដ្ឋានលើកទំនប់ ។ ណាឡា តែងតែគិតគូរដល់ប្រជាជនជម្លៀសដូចគ្នា ។ ជួនកាល ណាឡា បានលួចដួសបបរដែលនៅសល់ដាក់ទៅក្នុងឆ្នាំង ហើយយកទៅឲ្យប្រជាជនជម្លៀសដូចគ្នា ដោយយកលេសថាប្រជាជនទាំងនោះខ្ចីឆ្នាំង ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានចាប់ប្ដីរបស់ ណាឡា យកទៅឃុំឃាំងនៅក្នុងសាលារៀនមួយ ។ ពេលនោះ ណាឡា ក៏បានលួចបេះផ្ទីយកមកស្ងោរឲ្យប្ដីហូប ។ បន្ទាប់ពីស្ងោរឆ្អិន ណាឡា បានពឹងប្អូនស្រីរបស់គាត់ឲ្យយកម្ហូបទៅឲ្យប្ដីរបស់គាត់ ។ នៅពេល ណាឡា ផ្ញើម្ហូបតាមប្អូនស្រី ណាឡា បានផ្ដាំប្អូនរបស់គាត់ឲ្យស្ដាប់សំឡេងបងថ្លៃ មុននឹងហុចកញ្ចប់អាហារតាមប្រឡោះជញ្ជាំងទៅឲ្យ ។ ប៉ុន្តែពេលខ្លះប្ដីរបស់គាត់ មិនបានទទួលអាហារនោះទេ ដោយសារតែអ្នកទោសផ្សេងទៀតបានបន្លំសំឡេងប្ដីរបស់គាត់ ។

## វត្តមានកងទ័ពរំដោះ និងការចាប់ផ្ដើមជីវិតថ្មី

ខ្មែរក្រហមបានផ្ដើមរត់គេចខ្លួន នៅពេលដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយចូលមក ដែលធ្វើឲ្យស្ថានការណ៍នៅពេលនោះច្របូកច្របល់យ៉ាងខ្លាំង ។ ណាឡា បានជួបប្ដី និងប្អូនស្រី បន្ទាប់មកគាត់បានដើរប្រមូលស្រូវសម្រាប់ទុកហូប ។ គ្រួសាររបស់ ណាឡា បាននាំគ្នារត់ចេញពីសហករណ៍សំដៅទៅផ្លូវជាតិ ។ នៅតាមផ្លូវគាត់បានជួបប្រជាជនមូលដ្ឋាន និងប្រជាជនជម្លៀសដែលធ្លាប់ធ្វើការជាមួយគ្នាពីមុនមក ។ ប្រជាជនទាំងនោះគិតថា ណាឡា និងក្រុមគ្រួសារបានស្លាប់អស់ហើយ ។ ពេលធ្វើដំណើរទៅដល់សេរីសោភ័ណ ណាឡា បានជួបម្ដាយមីងខាងប្ដី ហើយបាននាំគ្នារង់ចាំរថយន្តជិះត្រឡប់មកក្រុងភ្នំពេញវិញ ។ នៅពេលនោះ ម្ដាយមីង ប្អូនស្រី និង ណាឡា បានឡើងជិះរថយន្តមួយ ។ ចំណែកប្ដីរបស់គាត់មិនបានឡើងជិះជាមួយទេ ដោយសារតែមានមនុស្សជិះពេញ ។ ហេតុដូច្នេះ ណាឡា ព្រមទាំងសាច់ញាតិបានសម្រេចចិត្តចុះពីលើរថយន្តនោះ ដើម្បីរង់ចាំរថយន្តបន្ទាប់ជាមួយប្ដីរបស់គាត់ ។ បន្ទាប់ពីឡើងជិះរថយន្តទាំងអស់គ្នាហើយ ណាឡា បានឮអ្នកជិះជាមួយប្រាប់ថា មនុស្សដែលឡើងរថយន្តទៅមុន បានស្លាប់អស់ ដោយសារតែរថយន្តកិនមីនកប់ក្នុងដី នៅម្ដុំស្រុកព្រះនេត្រព្រះ ។ ណាឡា បន្តថា នេះជាសំណាងរបស់គាត់ និងគ្រួសារដែលបានចុះពីរថយន្តនោះ បើមិនដូច្នេះទេក្រុមគ្រួសារគាត់ប្រហែលស្លាប់អស់ហើយ ។

នៅពេលធ្វើដំណើរទៅដល់ខេត្តសៀមរាប ណាឡា និងក្រុមគ្រួសារ ត្រូវបង្ខំឲ្យដើររកមធ្យោបាយផ្សេងទៀតដើម្បីធ្វើដំណើរបន្តមកភ្នំពេញ ។ ណាឡា បានសុំរថយន្តកងទ័ពវៀតណាមជិះជាមួយរហូតមកដល់ស្គន់ គាត់ និងក្រុមគ្រួសារក៏បានចុះពីលើរថយន្តធ្វើដំណើរបន្តដោយថ្មើរជើង ។ មកដល់ភ្នំពេញ គាត់បានទៅរស់នៅក្នុងផ្ទះមួយនៅម្ដុំផ្សារដើមថ្កូវ ។ នៅមុនខែមេសា ឆ្នាំ១៩៧៩ អ្នកភូមិនាំគ្នាវាយស្គររាំលេងកម្សាន្តមុនពិធីបុណ្យចូលឆ្នាំខ្មែរ ។ នៅពេលដែលអ្នកគ្រូកំពុងរាំ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងព័ត៌មាន លោក កែវ ចិន្តា បានទៅទស្សនកិច្ចនៅម្ដុំនោះ ។ គាត់បានឃើញអ្នកគ្រូរាំ ។ ហេតុដូច្នេះលោក កែវ ចិន្តា បានសួរអ្នកគ្រូ ទើបដឹងថាគាត់ជាអ្នករបាំ និងមានប្ដីជាអ្នកគំនូរបុរាណ ។ បន្ទាប់ដឹងព័ត៌មាននេះ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៩ លោក កែវ ចិន្តា បានចាត់លោក ប៉ែន យ៉េត ឲ្យមកហៅ ណាឡា ឲ្យចូលធ្វើការនៅក្រសួងវប្បធម៌ ។ នៅពេលនោះ ក្រសួងបានរៀបចំក្រុមសិល្បៈនៅផ្ទះកាកបាទក្រហមចាស់ នៅកាច់ជ្រុងអតីតផ្ទះលោក សម សារី ដោយអ្នកគ្រូ ជា សាមុី រស់នៅផ្ទះខាងលើ ។ ក្រោយពីរៀបចំក្រុមសិល្បៈរួចហើយ សិល្បករបាននាំគ្នាដើរប្រមូលសម្ភារ និងឧបករណ៍សិល្បៈពីអគារចាស់ៗមករៀបចំសម្រាប់ហ្វឹកហាត់ឡើងវិញ ។ បន្ទាប់មកទៀត លោក កែវ ចិន្តា បានប្រមូលសិល្បករឲ្យទៅរស់នៅអគារប៉ូឌីញ ក្បែរអតីតសាលមហោស្រពព្រះសុរាម្រិតវិញ ។

នៅឆ្នាំ១៩៧៩ ណាឡា បានចេញទៅសម្ដែងនៅប្រទេសវៀតណាម និងសូវៀត ។ នៅខែមករា ឆ្នាំ១៩៨០ ណាឡា សម្រាលបានកូនស្រីមួយ ។ ណាឡា បានដាក់ឈ្មោះ កូនស្រីរបស់គាត់ថា "វិចិត្រណា" ដោយសារតែគាត់ស្រឡាញ់ និងចូលចិត្តសិល្បៈ ។ នៅឆ្នាំដដែល ណាឡា បានសម្រេចចិត្តចូលបង្រៀនសិស្សនៅសាលារចនា បន្ទាប់ពីអ្នកគ្រូ ជា សាមី បានណែនាំ ។ ណាឡា បានធ្វើស្មៀនអ្នកគ្រូ ជា សាមុី ដោយជួយកត់ត្រា ផ្ទៀងផ្ទាត់ឃ្លាចុងចួននៃសាច់រឿង ។ នៅឆ្នាំ១៩៩៦ ណាឡា ត្រូវបានតែងតាំងជាព្រឹទ្ធបុរសរងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ ។

សព្វថ្ងៃ ណាឡា បង្រៀនរបាំបុរាណ ដឹកនាំរឿង និងដឹកនាំការសម្ដែង ព្រមទាំងណែនាំនិស្សិតប្រឡងបញ្ចប់ការសិក្សា ។ ណាឡា មានអារម្មណ៍សប្បាយរីករាយ នៅពេលដែលបានចូលរួមបណ្ដុះបណ្ដាល និងផ្ទេរចំណេះដឹងដល់និស្សិតជំនាន់ក្រោយ ។ ណាឡា មានប្រសាសន៍ថា ប្រសិនបើគ្មានរបបខ្មែរក្រហម ប្រហែលជាជីវភាពគ្រួសាររបស់គាត់អាចប្រសើរជាងបច្ចុប្បន្ន ព្រមទាំងអាចរស់នៅជួបជុំគ្នា ។

**រ៉ម៉ែន ពិចិត្រ**

# ដំណឹងស្វែងរកអ៊ំ

ខ្ញុំបានឈ្មោះ មាស ម៉ុង សូមប្រកាសរកគ្រួសាររបស់អ៊ំប្រុសឈ្មោះ អ៊ួង សុផល ហៅ ឌូ ។ អ៊ំប្រុសមានស្រុកកំណើតនៅស្រុកសំរោង ខេត្តតាកែវ ។ មុនការមកដល់នៃរបបខ្មែរក្រហម អ៊ំប្រុស និងគ្រួសារ រស់នៅ និងធ្វើការនៅទីក្រុងភ្នំពេញ ។ ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ថ្ងៃ១៧ មេសា ១៩៧៥ ខ្ញុំបានឮដំណឹងថា គ្រួសាររបស់អ៊ំប្រុស ត្រូវបានខ្មែរក្រហមជម្លៀសទៅខាងភូមិភាគពាយ័ព្យ ហើយចាប់តាំងពីពេលនោះមក ក៏បាត់ដំណឹងពីគ្រួសារគាត់រហូត ។ អ៊ំប្រុស អ៊ួង សុផល មានឪពុកឈ្មោះ អ៊ួង ឌឹម និងម្ដាយ ចាប អ៊ុង ។ អ៊ួង សុផល មានប្រពន្ធឈ្មោះ លី ណៃ និងកូនស្រី អ៊ួង សុភាព ។

អាស្រ័យដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ និងដឹងដំណឹងអំពីគ្រួសាររបស់អ៊ំប្រុសខ្ញុំ ដូចបានរាយនាមខាងលើ សូមមេត្តាទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទូរសព្ទលេខ ០២៣ ២១៤ ០០៩ ឬទាក់ទងមកកាន់ខ្ញុំបាទផ្ទាល់តាមរយៈទូរសព្ទលេខ ០៩២ ៥២៩ ៩៥៨ ។ ***សូមអរគុណ!***

# ខ្ញុំយំគ្រប់ពេលដែលខ្មែរក្រហមបង្គាប់ ឱ្យហៅឪពុកខ្ញុំថា «មិត្ត»

ផល្លី មិនព្រមហៅឪពុករបស់ខ្លួនថា “មិត្ត” តាមបញ្ជារបស់កម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិទេ ។ ផល្លី បានរៀបរាប់ថា មុនពេលរបបខ្មែរក្រហមគ្រប់គ្រង ឪពុករបស់គាត់ជាជាងធ្វើប៉ោតធុង ចំណែកឯម្តាយប្រកបរបរធ្វើស្រែ ។ ជារៀងរាល់ថ្ងៃ ផល្លី ទម្លាប់ហៅអ្នកទាំងពីរថា “ប៉ា” និង “ម៉ាក់” ។ ផល្លី បានបន្តថា ដោយសារមិនដែលឮពាក្យ “មិត្ត” និងមិនទម្លាប់និយាយពាក្យនេះពីមុនមក ទើបគាត់ប្រកែក និងយំ នៅពេលដែលខ្មែរក្រហមបង្គាប់គាត់ឲ្យប្រើពាក្យនេះ ។ ខ្មែរក្រហមប្រចាំនៅភូមិគំរាមវាយ និងយកគាត់ទៅសម្លាប់ចោល ប្រសិនបើនៅតែរឹងទទឹងហៅឪពុកខ្លួនឯងថា “ប៉ា” ដែលខ្មែរក្រហមបានចាត់ទុកថា ជាពាក្យរបស់មូលធន នាយទុន សក្តិភូមិ ។ ចាប់តាំងពីពេលនេះមក ផល្លី បាក់ស្បាត និងខ្លាចខ្មែរក្រហមរហូតមក ។

ផល្លី បានរៀបរាប់ថា គាត់មានស្រុកកំណើតនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ក្រុងភ្នំពេញ ។ គាត់មានឈ្មោះថា តិច ផល្លី ឪពុកឈ្មោះ កៅ តិច ដែលបច្ចុប្បន្ននៅរស់ ។ ចំណែកម្តាយមានឈ្មោះថា កៅ ម៉ៅ បានទទួលមរណៈភាពកាលពីឆ្នាំមុនដោយសារជំងឺ ។ ផល្លី មានបងប្អូនចំនួន៦នាក់ ហើយគាត់គឺជាកូនច្បង ។


អ្នកគ្រូ តិច ផល្លី

នៅពេលខ្មែរក្រហមចូលមកក្រុងភ្នំពេញ ផល្លី មានអាយុបីឆ្នាំ ។ ក្រុមគ្រួសារ ផល្លី រួមទាំងបងប្អូនត្រូវបានអង្គការជម្លៀសទៅភូមិបង្អោង ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ នៅពេលធ្វើដំណើរ ឪពុក ផល្លី មិនមានកម្លាំងកំហែង និងដើរពុំបានឆ្ងាយទេ ។ ម្តាយរបស់គាត់បានយកការ (រទេះធ្វើពីឈើ តែពុំមានកង់) មកឲ្យឪពុកគាត់ជិះ រួចហើយយកគោមកអូស ។

គ្រួសាររបស់ ផល្លី បានទៅរស់នៅភូមិបង្អោងរយៈពេលបីខែ ទើបកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិបានបែងចែកក្រុមគ្រួសារគាត់ឲ្យទៅរស់នៅភូមិស្មោរវិញ ។

ក្រោយមក អង្គការបានបំបែកម្តាយរបស់ផល្លីឲ្យទៅលើកទំនប់នៅព្រែកញ្ញៀ ។ ផល្លី និងប្អូនស្រីនៅកងកុមារនៅភូមិរំដួល ។ ចំណែកឪពុករបស់ ផល្លី រស់នៅ និងធ្វើការក្នុងភូមិស្មោរដដែល ។ ផល្លី ចាំបានថា ពីភូមិអង្គរំដួល ទៅភូមិស្មោរ មានចម្ងាយឆ្ងាយពីគ្នាប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ គាត់មិនចំណាំទីតាំងភូមិទាំងពីរនេះទេ ។ នៅភូមិស្មោរ ឪពុករបស់គាត់មានជំងឺហើមដោយសារហូបមិនគ្រប់គ្រាប់ ។ ចុងភៅស្លតែស្លឹកដំឡូងមី ដំឡូងជ្វា ស្លឹកអំពិលបារាំង និងខ្ទោតឲ្យឪពុកគាត់ហូបតែប៉ុណ្ណោះ ។ មកដល់សព្វថ្ងៃ ឪពុករបស់គាត់នៅតែដំណាលពីខ្ទោតដែលចុងភៅកាប់ដុំៗ ខលាយជាមួយទឹកស្ករ ដោយក្នុងត្នោតមួយដុំសម្រាប់សមាជិកបួននាក់ ។

ផល្លី រស់នៅក្នុងកងកុមារ ។ អង្គការបានសង់រោងពីឬស្សីដែលមានបណ្តោយ១០ម៉ែត្រ និងទទឹង៧ម៉ែត្រឲ្យស្នាក់នៅដោយក្នុងមួយកងមានកុមារប្រមាណ៥០នាក់ និងមានស្ត្រីចំណាស់ម្នាក់នៅគ្រប់គ្រង ។ រៀងរាល់ព្រឹក ផល្លី បានចេញដើររើសអាចម៍ទន្សាយតាមគុម្ពល្ពាក់ និងគុម្ពឫស្សីព្រៃ ។ ផល្លី បានទៅរែកស្មៅទ្រាបនៅនឹងដីជាមួយនឹងអ្នកនៅក្នុងកងជាមួយ ។ នៅពេលឃើញអាចម៍ទន្សាយទាំងនោះ កុមារដែលស្គាល់ច្បាស់ក៏បានចង្អុលប្រាប់ ផល្លី ឲ្យរើសដាក់ថ្នក់ក្រមាពណ៌សខ្មៅដែលអង្គការចែកឲ្យ ។ ផល្លី ដើរ

រើសអាចម៍ទន្សាយក្នុងមួយថ្ងៃឲ្យបានមួយថ្នក់ក្រម៉ា ដើម្បីយកទៅប្រគល់ឲ្យមិត្តពេទ្យដែលភាគច្រើនមានអាយុប្រមាណតែ១០ឆ្នាំ ។ ពេទ្យបានយកអាចម៍ទន្សាយទាំងនោះ ទៅចែកឲ្យអ្នកជំងឺដែលមានអាការគ្រុនក្តៅដែលមកស្នើសុំថ្នាំ ។ មុននឹងផ្តល់អាចម៍ទន្សាយឲ្យទាល់តែពេទ្យពិនិត្យឃើញអ្នកជំងឺនោះឈឺធ្ងន់ ។ នៅពេលខ្លះពេទ្យក៏បានយកទឹកដូងទៅចាក់ឲ្យអ្នកជំងឺទាំងនោះដែរ ។

បន្ទាប់ពីសម្រាកពីការងារ ផល្លី និងកុមារផ្សេងទៀតនៅពេលព្រលប់ឡើងដួងត្រូវរត់ទៅហូបអាហារដែលមានតែបបររាវៗ នៅរោងបាយជុំគ្នា ។ កងកុមារនៅពេលនោះត្រូវដេកទល់ដើងគ្នានៅផ្ទាល់នឹងដី ដោយគ្មានកន្ទេល ភួយ និងខ្នើយទេ គឺមានតែក្រមាមួយប៉ុណ្ណោះ ។ យប់ខ្លះ ផល្លី រងារខ្លាំងណាស់ ប៉ុន្តែគាត់មិនដែលឈឺថ្កាត់ទេ ។ មិនត្រឹមតែប៉ុណ្ណោះ ផល្លី ថែមទាំងធាត់ទៀតដងរហូតដល់ប្រធានកងសង្ស័យថា ឪពុករបស់គាត់លួចយកអាហារឲ្យគាត់ហូប ។ ផល្លី បានឲ្យដឹងថា គាត់មានសុខភាពល្អប្រហែលមកពីឪពុកគាត់ធ្លាប់ដុតសត្វថ្លែនឲ្យគាត់ហូប ។

នៅថ្ងៃមួយ ខណៈពេល ផល្លី កំពុងដើររើសអាចម៍ទន្សាយនៅតាមគុម្ពឫស្សី និងគុម្ពោធល្ពាក់ ក៏ឃើញអង្គការកំពុងរៀបចំពិធីមួយ ។ ផល្លី បានសួរក្មេងៗដែលនៅកងជាមួយ ទើបដឹងថាអង្គការកំពុងរៀបការឲ្យប្រជាជន ហើយអ្នកនៅក្នុងកងរបស់គាត់ក៏បានហាមឃាត់គាត់កុំឲ្យនៅឈរមើល ព្រោះបើអង្គការដឹងនឹងចាប់គាត់យកទៅវាយសម្លាប់មិនខាន ។

ក្រោយមក ប្រជាជននៅក្នុងភូមិជាមួយគ្នាបានរាយការណ៍ទៅអង្គការថា ឪពុករបស់ ផល្លី ជាទាហានពាក់ស័ក្តិ៥ និងជា សេ.អ៊ី.អា ។ ចាប់តាំងពីពេលនោះមក អង្គការបានតាមដានក្រុមគ្រួសារ ផល្លី រហូតប្រធានសហករណ៍ដែលគ្រប់គ្រងកងរបស់ម្តាយគាត់នៅព្រែកព្នៅ ហៅម្តាយគាត់ទៅប្រជុំនៅរាល់ពេលសម្រាកពីការងារពេលល្ងាច ថែមទាំងចោទថា ម្តាយគាត់ជា "ប្រពន្ធស័ក្តិ៥" ។ ម្តាយរបស់ ផល្លី បានបដិសេធថា "គាត់មិនមានប្តីពាក់ស័ក្តិ៥ទេ ហើយសឹងតែមិនស្គាល់ភ្នំពេញបែរមុខទៅខាងណាផង គាត់ដឹងតែធ្វើស្រែតែមួយមុខប៉ុណ្ណោះ" ។ ពេលព្រលប់ដូច្នេះប្រធានសហករណ៍ក៏ស្រែកបញ្ជោរមកថា "បើអ៊ីចឹងមិត្ត ម៉ៅ ឯងស្ទូងស្រូវឲ្យយើងមើលឃើញពីជ្រុងម្ខាងនេះទៅជ្រុងម្ខាងនោះ (ស្ទូងឲ្យចេញជាក្រឡាចត្



រូបទីពីររាប់ពីស្តាំ ៖ អ្នកគ្រូ តិច ផល្លី ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ដែលរៀបចំដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា កាលពីខែសីហា ឆ្នាំ២០១៧

វគ្គ) ដែលសម័យនោះអង្គការតែងហៅថា ស្រែគំរូ» ។ ដោយសារម្ដាយ ផល្លី ធ្លាប់ធ្វើស្រែ ម្ដាយគាត់បានយកកណ្ដាប់ស្រូវពីផ្ទួនមកស្ទូងក្នុងស្រែម្នាក់ឯង ដែលមើលពីមុខទៅក្រោយ និងពីឆ្វេងទៅស្ដាំចេញជាក្រឡា និងបន្ទាត់ស្មើទាំងអស់ ។ ឃើញដូច្នេះទើបប្រធានសហករណ៍ជឿថា ម្ដាយគាត់ជាអ្នកស្រែ មិនដូចការរាយការណ៍មកទេ ។ ក្រោយឆ្នាំ១៩៧៩ ម្ដាយរបស់ ផល្លី នៅតែរំឭកប្រាប់ ផល្លី ថា ប្រសិនបើគាត់មិនចេះធ្វើស្រែ ប្រហែលគាត់មិនបានរស់ទេ ។

បងស្រីម្ដាយរបស់ ផល្លី ម្នាក់ដែលជម្លៀសពីភ្នំពេញមកនៅស្រុកគងពិសីជាមួយគ្រួសារផល្លី ដែរ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យបររទេះដឹកស្រូវ ។ ថ្ងៃមួយ ពេលអ៊ំស្រីរបស់ ផល្លី កំពុងបររទេះ គោបានវាត់កន្ទុយចំភ្នែក ធ្វើឲ្យភ្នែកអ៊ំស្រីរបស់គាត់ឡើងបាយ ។ អ៊ំស្រីរបស់គាត់ក៏កើតជំងឺអុតស្វាយ ហើយចេញជាកន្ទួលនិងដំបៅរលួយដែរ ។ មានតាម្នាក់នៅក្នុងភូមិបានប្រាប់អ៊ំស្រីគាត់ថា បើគាត់កើតជំងឺអុតស្វាយ តាមជំណាមពីបុរាណ «មិនឲ្យអ្នកជំងឺនៅជិតកន្លែងដែលមានសំឡេងក្ដួងក្ដាំង ហើយមិនត្រូវរំលំដើមត្នោតដែលដុះនៅជិតខ្ទមដែលអ្នកជំងឺរស់នៅទេ» ។ ពេលលេចឮពាក្យនេះដល់កម្មាភិបាលនៅក្នុងភូមិ ក៏មានបញ្ជាមកថា «ត្រូវតែកាប់រំលំដើមត្នោត ដើម្បីចង់ដឹងថាបើរំលំដើមត្នោតទៅអ៊ំរបស់គាត់ងាប់ ឲ្យឃើញងាប់ពិតប្រាកដ» ។ បន្ទាប់ពីកាប់រំលំដើមត្នោតភ្លាម ភ្នែកអ៊ំរបស់គាត់ឈឺកាន់តែខ្លាំងឡើង ទើបប្រធានកងយកអ៊ំរបស់ ផល្លី ទៅព្យាបាលនៅពេទ្យភូមិស្នោ ។ ពេទ្យបានខ្វេះយកគ្រាប់ភ្នែកដែលឈឺធ្ងន់ម្ខាងចេញ ធ្វើឲ្យអ៊ំរបស់គាត់ឈឺចាប់យ៉ាងខ្លាំងរហូតស្រែករកអ្នក ។ ពេទ្យបានគំរាមអ៊ំរបស់គាត់ថា «បើមិត្តនៅតែស្រែកទៀត នឹងសម្លាប់ចោលទាំងពូជ» ទើបអ៊ំរបស់គាត់នៅស្ងៀម ។ ផល្លី បានឮសំឡេងអ៊ំរបស់គាត់ស្រែកនៅពេលដែលគាត់ដើររើសអាចម៍ទន្សាយនៅក្បែរមន្ទីរពេទ្យភូមិស្នោនោះ ។

ក្រោយពីដឹងច្បាស់ថាអ៊ំរបស់ខ្លួនហើយ ផល្លី បានរត់ទៅប្រាប់ឪពុកគាត់ថា «ប៉ា! អង្គការខ្វេះភ្នែកម៉ាក់ធំហើយ» ។ ឪពុករបស់ ផល្លី ក៏សួរបញ្ជាក់ថា ខ្វេះនៅណា? ផល្លី ក៏ប្រាប់ទៅឪពុកវិញថា នៅពេទ្យ ។ បន្ទាប់ពីដឹងដំណឹងនេះហើយ ឪពុករបស់ ផល្លី បានលួចខ្សឹបប្រាប់ ផល្លី ថា សូមកូនកុំហៅ «ម៉ាក់ធំអ៊ី» បើកូននៅតែហៅពាក្យនេះទៀត «អង្គការនឹងយកយើងទៅសម្លាប់ទាំងអស់គ្នា» ។

ផល្លី បានរៀបរាប់ថា ដំបូងគាត់អាចហៅឪពុកថា «ប៉ា» បាន ប៉ុន្តែពេលអង្គការបំបែកគាត់ឲ្យមករស់នៅខាងជើងផ្លូវនៅក្នុងភូមិអង្គរំដួល នៅឆ្នាំ១៩៧៧ អង្គការបង្គាប់ឲ្យគាត់ប្ដូរពីហៅ «ប៉ា» មកហៅ «ពុក» វិញ ។ បន្ទាប់មក អង្គការបានបញ្ជាគាត់ឲ្យហៅឪពុកថា «មិត្ត» ។

ចាប់តាំងពីពេទ្យខ្វេះភ្នែកមក អ៊ំរបស់ ផល្លី បានងងឹតទាំងសងខាង ទើបប្រធានកងប្រាប់គ្រួសារ ផល្លី ថា «បើមិត្តនេះ (អ៊ំរបស់ ផល្លី) មើលមិនឃើញ រកអ្នកមកជួយមើលទៅ គ្រាន់បានជួយដឹកទៅបត់ដៃ បត់ជើង គ្មានមិត្តណាមកជួយមើលទេ» ។

ខណៈនោះ ប្អូនរបស់ ផល្លី ក៏ឈឺរាកមួលធ្ងន់ដែរ ។ ផល្លី បានដឹងរឿងនេះ ព្រោះនៅពេលនោះគាត់ស្នាក់នៅរោងមួយជាប់ជាមួយនឹងរោងប្អូនស្រីរបស់គាត់ (សម័យនោះអង្គការបែងចែកកុមារទៅតាមអាយុ និងភេទ ហើយពេលខ្លះអង្គការបំបែកបងប្អូនឲ្យនៅកងចម្ងាយប្រមាណពីរទៅបីគីឡូម៉ែត្រឆ្ងាយពីគ្នា) ហើយមូលហេតុដែលប្អូនគាត់មានជំងឺហូរឈាមនេះ ដោយសាររាល់ពេលប្អូនគាត់ជុះ ប្រធានកងមើលថែកុមារ «កងម៉ែៗ» យកស្រកីដូងទៅរួសសម្អាតគូថប្អូនស្រីរបស់គាត់បណ្ដាលឲ្យដាច់ និងហូរឈាម ។ ផល្លី បានទៅមើលប្អូន ប៉ុន្តែកុមារនៅក្នុងកងជាមួយគាត់ដែលមានអាយុច្រើនជាងគាត់លួចខ្សិបប្រាប់គាត់ថា «មិត្តឯងកុំខស្បាហ៍ទៅមើលប្អូនពេក ប្រយ័ត្នអង្គការសម្លាប់ទាំងអស់គ្នា» ។ បើអាណិតប្អូនគ្រាន់តែសម្លឹងមើលពីចម្ងាយបានហើយ ។ ពេលឮពាក្យនេះ ផល្លី ភិតភ័យខ្លាំងណាស់ ។

មិនយូរប៉ុន្មានដំណឹងប្អូនរបស់ ផល្លី ឈឺបានឮទៅដល់ឪពុករបស់គាត់នៅឯភូមិស្នោ ។ ឪពុកផល្លី ក៏បានស្នើទៅប្រធានសហករណ៍ ដើម្បីទៅមើលកូននៅភូមិអង្គរំដួល ។ ឪពុករបស់គាត់បានរើសយកស័ង្កសីមកធ្វើជាកាដងទឹក យកទៅជូនប្រធានសហករណ៍ ។ ប្រធានសហករណ៍ក៏សួរឪពុក ផល្លី ថាមិត្តបានកានេះមកពីណា? ឪពុកគាត់ក៏ប្រាប់ថា រើសស័ង្កសីចាស់ៗមកធ្វើ ។ ប្រធានសហករណ៍នោះយល់ព្រមតាមសំណើរបស់ឪពុកគាត់ ដោយសារអំណោយការដងទឹកមួយនេះ ។

មួយរយៈក្រោយមក ដោយមានការលំបាកខ្លាំងក្នុងការ

មើលថែទាំកូន ឪពុករបស់ ផល្លី ក៏ស្នើទៅប្រធានសហករណ៍សុំឲ្យម្តាយ ផល្លី មកជួយមើលកូនស្រីដែលមានជំងឺរាកមួល និងហូរឈាមនៅពេលជុះ ។ ឪពុករបស់ ផល្លី លើកមូលហេតុថា គ្រួសារគាត់មានបងពិការ ហើយមានកូនឈឺទៀត ។ ប្រធានសហករណ៍បានយល់ព្រម ។ ប៉ុន្តែក្រៅពីមកមើលថែទាំកូន ប្រធានកងបានដាក់ការងារឲ្យម្តាយរបស់ ផល្លី ធ្វើថែមទៀត គឺរកអុសមករម្ងាស់ស្ករត្នោតក្នុងមួយថ្ងៃឲ្យបាន៣០ខ្ទះ តែដោយសារនៅក្នុងកងនេះមានសមាជិកបីនាក់ ទើបបែងចែកក្នុងម្នាក់រម្ងាស់១០ខ្ទះវិញ ។ ក្រៅពីការងាររកអុស និងរម្ងាស់ស្ករ អង្គការចាត់តាំងឲ្យម្តាយរបស់ ផល្លី ទៅរែកទឹកត្នោតពីភូមិផ្សេងៗនៅជុំវិញនោះទៀត ។

ថ្ងៃមួយប្អូនរបស់ ផល្លី បានទាររហូបស្ករ ។ ម្តាយរបស់ ផល្លី បាននិយាយបន្ទប់ថា កូនកុំយំ ចាំបន្តិចទៀតទៅបបរមិនទាន់ឆ្អិនទេ ។ ឮដូច្នេះសមាជិកក្នុងកងជាមួយ បាននិយាយមកកាន់ម្តាយរបស់ ផល្លី ថា មិត្ត ម៉ៅ ចេះណាស់កូនទាស្ករ ថាបបរមិនទាន់ឆ្អិន ។ ចៃដន្យពេលនោះប្រធានសហករណ៍មកដល់ ក៏បញ្ជាម្តាយ ផល្លី ថា “មិត្ត ម៉ៅ ឯងទៅខ្ទះយកស្ករ នៅឆ្នាំងយកទៅឲ្យកូនកុំឲ្យវាយំ ប្រយ័ត្នអង្គការយកទៅបាញ់ចោល” ។ ដោយសារខ្លាចខុសវិន័យរបស់អង្គការដែលហាមមិនឲ្យយករបស់សមូហភាព ទើបម្តាយរបស់ ផល្លី មិនហ៊ានទៅយក ។ ឃើញដូច្នេះ ប្រធានសហករណ៍បានទៅដួសស្ករដោយខ្លួនឯងមកឲ្យប្អូន ផល្លី មួយស្លាបព្រាបាយ ។ ប្អូនរបស់ ផល្លី បានលិតស្ករហើយ ទើបឈប់យំ ។

នៅពេលនោះ ឪពុករបស់ ផល្លី ក៏បានស្កាត់មកជួបម្តាយ ផល្លី ដែរ តែមិនដែលហ៊ាននៅយូរទេ ព្រោះត្រូវត្រឡប់ទៅធ្វើការឲ្យទាន់ពេល ។ ចំណែក ផល្លី បានត្រឹមសម្លឹងមើលម្តាយប៉ុណ្ណោះនៅពេលគាត់ដើរចេញទៅធ្វើការម្តងៗ ប៉ុន្តែគាត់មិនដែលហ៊ានទៅលេងនិងនិយាយជាមួយម្តាយទេ ទោះបីគាត់នឹកម្តាយខ្លាំងប៉ុណ្ណាក៏ដោយ ព្រោះនៅសម័យនោះអង្គការតែងបំពាក់បំប៉នគាត់ថា អង្គការជាម៉ែឪ ។ ដូច្នេះនៅពេលឃើញម្តាយម្តងៗ ផល្លី ធ្វើហាក់ដូចជាអ្នកទីទៃ មិនដែលស្គាល់គ្នា ។ ដោយសាររឿងរ៉ាវនេះកើតឡើងចំពោះគាត់ រហូតមកដល់សព្វថ្ងៃ គាត់តែងតែនិយាយប្រាប់សិស្សឲ្យចេះនិយាយរាក់ទាក់រកគ្នា រាប់អានគ្នា ទៅវិញទៅមក ។

ក្រោយមក ប្រធានកងបានដក ផល្លី ពីកងរើសអាចម៍



រូបទីមួយរាប់ពីឆ្វេង ៖ អ្នកគ្រូ គិច ផល្លី ថតរូបជុំគ្នាជាមួយសិក្ខាកាម និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា កាលពីខែសីហា ឆ្នាំ២០១៧

ទន្សាយ ឲ្យមករើសអាចម៍គោ និងដើរកាត់ដើមទន្ទ្រានខែត្រវិញ ។ ពេលខ្លះ ផល្លី ទូលទន្ទ្រានខែត្រពុំរួច ក៏អូសយកមកកងទាំងប្រឡាក់ភក់ ក្នុងមួយថ្ងៃឲ្យបានបីបាច់ ។ បន្ទាប់មក ផល្លី ត្រូវប្រមូលដើមទន្ទ្រានខែត្រមកកាប់ចិញ្ច្រាំលាយជាមួយលាមកមនុស្សធ្វើជី ។ ថ្ងៃមួយបន្ទាប់ពីចិញ្ច្រាំជីទន្ទ្រានខែត្ររួច ប្រធានកងបាននាំ ផល្លី និងកងកុមារទៅផ្ងូតទឹក ។ ពេលនោះ កុមារដែលមានមាឌធំជាង ផល្លី បានហៅគាត់ឲ្យចុះមកមុជទឹកក្នុងបឹង ។ ខណៈពេលដែល ផល្លី ចុះទៅក៏ជុតជើង និងបានលង់ទឹក ចំណែកកុមារធំៗទាំងនោះឡើងទៅកងមុនអស់ ។ ចៃដន្យឪពុកផល្លី មកពីធ្វើការក៏ឃើញ ក៏ស្រែកពីចម្ងាយថាកូនរណា ស្រាប់តែស្រន់មកទើបដឹងថាកូនរបស់ខ្លួន ។ ឪពុករបស់ ផល្លី បានលើករលាក់ឲ្យទឹកចេញពីខ្លួនរបស់គាត់ រួចយកគាត់ទៅឆ្អើរភ្លើងរហូតដឹងខ្លួន ។ ចាប់តាំងពីពេលនោះ ផល្លី មិនហ៊ានចុះហែលទឹកទៀតទេ ។

ផល្លី បានរំឭកថា នៅយប់ថ្ងៃមួយ នៅពេលគាត់កំពុងដេក ស្រាប់តែពស់ថ្លាន់ទំហំប៉ុនភ្លៅបានវាកាត់លើខ្លួនរបស់គាត់ ធ្វើឲ្យគាត់ភិតភ័យ និងស្រែកយ៉ាងខ្លាំង ។ ពេលនោះម៉ែៗគ្រប់គ្រងកងកុមារបម្រុងនឹងយក ផល្លី ទៅកសាង ។ ឪពុករបស់ ផល្លី បានទៅសូមអង្វរម៉ែៗកុំឲ្យយកទោសពៃរ៍ ដោយសារតែ "កូនដេកមមើ" ទើបកងម៉ែៗអនុគ្រោះ រួចហើយបញ្ជូន ផល្លី ឲ្យទៅគាស់គល់ឈើជាមួយកងយាយៗវិញ ។

ក្រោយមក ផល្លី ត្រូវបានចាត់ឲ្យមកមើលថែ និងដឹកដៃអ៊ំរបស់គាត់ទៅហូបបាយ ។ ថ្ងៃមួយអ៊ំរបស់ផល្លី ភ្លេចខ្លួន ត្រូវទៅរកពេទ្យ ។ ពេលនោះ ផល្លី មិនហ៊ានហៅអ៊ំរបស់គាត់ថា "អ៊ំ" ទេ ដោយសារខ្លាចខុសនឹងវិន័យអង្គការហាមឃាត់ គឺត្រូវប្ដូរមកហៅ "មិត្ត" វិញ ព្រោះអង្គការធ្លាប់ប្រជុំប្រាប់គាត់ជាញឹកញាប់ថា "មិត្តយើងត្រូវតែប្ដូរតាមបរិបទរបស់អង្គការ" ទោះបីគាត់មិនយល់អត្ថន័យនោះក៏ដោយ ។

ទៅទីនោះ ប្រធានសហករណ៍តែងនិយាយមកកាន់អ៊ំរបស់ ផល្លី ដែលពិការថា "មិត្តឯងកុំឈឺទម្រន់ ល្មមជាហើយ" រួចហើយក៏ចាត់តាំងអ៊ំរបស់គាត់ត្បាញកន្ទេល និងមើលថែកុមារនៅក្នុងកង ទោះបីដឹងថាអ៊ំរបស់គាត់ពិការភ្នែកទាំងពីរក៏ដោយ ។ តែដោយសារតំបន់ដែលអ៊ំរបស់ ផល្លី រស់នៅមិនមានកុមារតូចៗ ទើបអ៊ំរបស់គាត់មិនសូវជួបការលំបាក ។ ក្រៅពីថែអ៊ំស្រី ផល្លី ក៏ត្រូវទៅកាត់ទន្ទ្រានខែត្រមកធ្វើជីដែរ រហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ។

គ្រួសារ ផល្លី បានធ្វើដំណើរចូលមកភ្នំពេញវិញ ។ ពេលនោះ ផល្លី ឃើញមានសាកសពជាច្រើននៅតាមផ្លូវ ។ គ្រួសារ ផល្លី បានមកស្នាក់នៅបណ្ដោះអាសន្ននៅផ្សារដើហុយ ដើម្បីតាមស៊ើបសួររកបងប្អូនដែលបាត់ខ្លួនមួយចំនួន ។ ក្រោយមក ឪពុករបស់ ផល្លី បានជួបអ្នកធ្លាប់ទៅស្រុកបារាំងឈ្មោះ វ៉ន ។ វ៉ន បានប្រាប់ឪពុក ផល្លី ថា ម៉ុក ស៊ុនឃុន ដែលត្រូវជាបងប្អូនជីដូនមួយឪពុកគាត់ត្រូវបានខ្មែរក្រហមបញ្ជូនត្រឡប់មកប្រទេសកម្ពុជា និងជាប់នៅទួលស្លែង តែមិនដឹងរស់ឬស្លាប់ទេ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៩ ឪពុកម្ដាយរបស់ ផល្លី បានពឹងគិញវៀតណាមដែលធ្លាប់ស្គាល់គ្នា ឲ្យជូនមកគុកទួលស្លែង ព្រោះពេលនោះប្រជាជនមិនទាន់អនុញ្ញាតឲ្យចេញចូលក្នុងភ្នំពេញដោយសេរីទេ ។ នៅពេលចូលទៅក្នុងគុកទួលស្លែង ឪពុករបស់ ផល្លី បានឃើញរូបថត ម៉ុក ស៊ុនឃុន ភ្ជួរនៅនឹងជញ្ជាំង ធ្វើឲ្យឪពុកគាត់រន្ធត់យ៉ាងខ្លាំង ។ ឪពុក ផល្លី និង ផល្លី បានត្រឡប់មកផ្ទះវិញ ហើយចាប់តាំងពីពេលនោះមកគ្រួសារគាត់លែងនឹកនា និងស៊ើបសួរដំណឹង ម៉ុក ស៊ុនឃុន តទៅទៀត ។

ផល្លី បានរៀបរាប់ពីប្រវត្តិរបស់ ម៉ុក ស៊ុនឃុន ថា ម្ដាយរបស់ម៉ុក ស៊ុនឃុន ត្រូវជាបងប្អូនបង្កើតម្ដាយខាងឪពុកគាត់ ។ នៅពេល ម៉ុក ស៊ុនឃុន អាយុបានពីរឆ្នាំ ម្ដាយរបស់ ម៉ុក ស៊ុនឃុន ឈ្មោះ មួយ បានស្លាប់ដោយសារហូបត្រីផ្អី ហើយទាស់ នៅសល់តែឪពុកប៉ុណ្ណោះ ឃើញដូច្នេះយាយរបស់គាត់ឈ្មោះ ម៉ាពួយ បានយក ម៉ុក ស៊ុនឃុន មកបំបៅដោះជាមួយកូនបង្កើតរបស់ខ្លួនម្នាក់ទៀតដែលទើបនឹងកើតបានមួយខួបឈ្មោះ តាវ ត្រូវជាអ៊ំរបស់ ផល្លី ដែលក្រោយមកត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅម្ដុំបឹងទន្លេសាប ក្នុងខេត្តពោធិ៍សាត់ ។ នៅពេល ម៉ុក ស៊ុនឃុន អាយុបាន ៧ឆ្នាំ ឪពុករបស់ ស៊ុនឃុន បានស្លាប់ដោយសារយន្តហោះទម្លាក់គ្រាប់បែកចំ នៅម្ដុំបន្ទាយសានីឬបន្ទាយបក្ស (បច្ចុប្បន្នផ្សារចោមចៅ) ។ ចាប់តាំងពីពេលនោះមក ម៉ុក ស៊ុនឃុន បានក្លាយទៅជាក្មេងកំព្រា ។ ស៊ុនឃុន ត្រូវបានយាយតារបស់ ផល្លី យកមកចិញ្ចឹមបីបាច់ថែរក្សា និងរស់នៅជុំគ្នាជាមួយកូនបង្កើតចំនួនប្រាំនាក់

ទៀត នៅម្តុំផ្សារចោមចៅ ។ នៅពេលនោះ ស៊ុនឃុន បានចូលរៀននៅសាលាបឋមសិក្សាស្ថិតនៅវត្តគោកបញ្ញាន់ ជិតវាលយន្តហោះពោធិ៍ចិនតុង ។ ក្រោយមក ដោយសារជីវភាពក្នុងគ្រួសារជួបការលំបាកខ្លាំង ស៊ុនឃុន បានមករស់នៅវត្តវិញ ។ ដោយសារ ស៊ុនឃុន ជាសិស្សក្រីក្រ និងកំព្រាឪពុកម្តាយ ដូច្នេះគាត់ក៏បានទទួលអាហាររូបករណ៍ចូលរៀននៅសាលាវិចិត្រសិល្បៈ ផ្នែកគំនូរ ។ នៅពេលនោះ ស៊ុនឃុន ក៏បានប្រឡងជាប់លេខ១ និងទទួលបានអាហាររូបករណ៍ផ្នែកវិស្វករគំនូរ ទៅសិក្សានៅប្រទេសបារាំង ហើយក្រោយមកក៏បាត់ដំណឹងគាត់រហូត ។ រហូតមកដល់ឆ្នាំខែកក្កដា ឆ្នាំ២០១៧ នៅពេលដែល ផល្លី មកចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) រយៈពេលបីថ្ងៃនៅវិទ្យាស្ថានជាតិអប់រំដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ ទើបគាត់ស្នើរកឯកសារពាក់ព័ន្ធនឹង ម៉ុក ស៊ុនឃុន ម្តងទៀត ។ បន្ទាប់ពីស្រាវជ្រាវនៅក្នុងប្រព័ន្ធទិន្នន័យឯកសារ បុគ្គលិកផ្នែកទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញឯកសារមួយទំព័រចុះលេខ I ៨៤២១ មានបិទរូបថត និងសរសេរថា ប្រវត្តិរូបសង្ខេបអ្នកទោសជាប់ឃុំឃាំង ៖ ឈ្មោះដើមៈ ម៉ុក ស៊ុនឃុន ជនជាតិៈ ខ្មែរ ភេទៈ ប្រុស ក្រសួង និងនាទីបច្ចុប្បន្នៈ មុនវិស្វករខាងគំនូរ ទីកន្លែងឃាត់ខ្លួនៈ ស្រុកបារាំង ឆ្នាំ១៩៧៦ ។

ផល្លី មានប្រសាសន៍ថា នៅពេលឃើញប្រវត្តិរូបនេះ ធ្វើឲ្យគាត់នឹកឃើញឡើងវិញពីពូ និងអ៊ំមួយគ្រួសារទៀតដែលខ្មែរក្រហមសម្លាប់ ហើយគាត់តែងតែយំនៅពេលរំឭកឡើងវិញពីរឿងរ៉ាវនេះម្តងៗ ។

បន្ទាប់មក គ្រួសារ ផល្លី បានទៅនៅភូមិត្រពាំងថ្មីង (អតីតខ្សែក្រវ៉ាត់ក្រុងភ្នំពេញ និងខេត្តកណ្តាល) វិញ ។ ទៅដល់ដំបូង ផល្លី ឃើញមានដើមត្នោតប្រមាណ៤០ ដែលនៅសល់ពីឈ្លបខ្មែរក្រហម ដែលធ្លាប់មកស្នាក់នៅភូមិនេះ ។ នៅទីនោះ ឪពុកម្តាយរបស់ផល្លីបានចាប់ផ្តើមប្រកបរបរធ្វើស្រែសារជាថ្មី ។

នៅអំឡុងពេលនោះដោយសារតែចង់រៀន ផល្លី បានទៅឈរមើលសិស្សដែលកំពុងរៀនសាលាបឋមសិក្សាជម្ពូវ័ន្ត ប៉ុន្តែនៅសម័យនោះមុននឹងបានចូលរៀនសិស្សត្រូវបង់ជាអង្ករឲ្យទៅគ្រូ ហើយក៏មិនមានសៀវភៅសរសេរដែរ ។

ក្រោយមក ផល្លី ក៏បានចូលរៀន រហូតមកដល់ឆ្នាំ១៩៨៧ ទើបគាត់ប្រលងឌីប្លូមជាប់សញ្ញាបត្រ តែធ្លាក់កៅអី ។ ដូច្នេះ ផល្លី មិនបានចូលរៀនទេ ។ ផល្លី បានដើរបេះត្រកួនដើម្បីលក់នៅផ្សារស្ទឹងមានជ័យ ទួលទំពូង និងផ្សារដើមគយកប្រាក់ផ្គត់ផ្គង់គ្រួសារ ។ ក្រៅពីលក់ត្រកួន ផល្លី បានឆ្លៀតមករៀនបំពេញវិជ្ជានៅសាលាសន្ធរម៉ុកមួយឆ្នាំ ក៏ប្តូរទៅរៀននៅសាលាជម្ពូវ័ន្ត ព្រោះនៅជិតផ្ទះ ។ ផល្លី រៀនរហូតដល់ថ្នាក់ទី៩ ដើម្បីត្រៀមប្រឡងបាក់ឌុបនៅថ្នាក់ទី១០ (សម័យនោះសិស្សត្រូវប្រលងបាក់ឌុបត្រឹមថ្នាក់ទី១០) ។

ថ្ងៃមួយ នៅពេលដែល ផល្លី ទៅលក់ត្រកួននៅផ្សារពោធិ៍ចិនតុង ក៏ជួបនឹងប្រធានអប់រំស្រុកដង្កោ គាត់ក៏ប្រាប់ ផល្លី ឲ្យទៅប្រលងគ្រូមត្តេយ្យ និងឲ្យទៅយកពាក្យប្រលងនៅកន្លែងគាត់ធ្វើការ ។ នៅថ្ងៃបន្ទាប់ ពេលទៅយកពាក្យប្រធានអប់រំស្រុកបានសួរ ផល្លី ថាមានគំនិតដូចម្តេចទើបចង់ចូលធ្វើគ្រូ? ពេលនោះផល្លី បានឆ្លើយថាចង់កសាងប្រទេស និងជាទំពាំងស្នងជាឫស្សីរឹងមាំដើម្បីប្រទេសជាតិ ទើបប្រធានអប់រំប្រគល់ពាក្យឲ្យគាត់ដោយមិនគិតថ្លៃ ។

ផល្លី បានប្រឡងជាប់ និងចូលរៀននៅសាលាមត្តេយ្យមជ្ឈិម ។ បន្ទាប់ពីរៀនចប់ ផល្លី បានចេញទៅបង្រៀននៅជម្ពូវ័ន្ត ក្រៅពីកិច្ចការបង្រៀន គាត់ត្រូវលក់ចេកចៀនដើម្បីយកប្រាក់មកផ្គត់ផ្គង់ប្អូនប្រាំនាក់ទៀតឲ្យរៀនបន្ត និងចិញ្ចឹមឪពុកម្តាយ ។ ប្អូនៗរបស់ ផល្លីបានរៀនរហូតចប់វិទ្យាល័យ ។ ក្រោយមក ទើប ផល្លី បានដាក់ពាក្យប្រលងជាប់បាក់ឌុប និងរៀនបន្តយកមុខវិជ្ជាភូមិវិទ្យា-ប្រវត្តិវិទ្យា ។ នៅឆ្នាំ២០០៧ ប្តីរបស់ផល្លី បានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ ។ ផល្លី ត្រូវទទួលបន្ទុកចិញ្ចឹមកូនពីរនាក់នៅក្នុងបន្ទុក និងឪពុកចាស់ ។ រហូតមកដល់សព្វថ្ងៃ ផល្លី បង្រៀននៅវិទ្យាល័យជម្ពូវ័ន្ត ហើយឆ្លៀតពេលថ្ងៃសៅរ៍ និងអាទិត្យ គាត់ត្រូវជិះរថយន្តទៅបង្រៀនសិស្សនៅសាកលវិទ្យាល័យឯកជននៅតាមខេត្ត ។ ផល្លី មានប្រសាសន៍ថា នៅពេលដែលគាត់ចេញទៅឆ្ងាយម្តងៗ គាត់តែងតែបារម្ភពីឪពុក និងកូនស្រីទាំងពីរនាក់របស់គាត់ ព្រោះខ្លាចបែកបាក់ដូចក្នុងសម័យខ្មែរក្រហម ។

**សោម ប៊ុនថន**

# ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ផុន សារួន រស់នៅភូមិពោធិ៍ស្នាយ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង ។ សូមប្រកាសរកបងប្រុសបងស្រី ដែលបានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ដូច មានរាយនាមដូចខាងក្រោម ៖

១) ភុន ចាន់ថា (ស្រី) កើតឆ្នាំរកា នៅពេលបាត់ខ្លួនមានអាយុ២១ឆ្នាំ ។ បងស្រី ភុន ចាន់ថា បានបាត់ខ្លួននៅឆ្នាំ១៩៧៧ នៅពេលដែលខ្មែរក្រហមជម្លៀស និងឲ្យគាត់ទៅធ្វើការនៅជប់ពាមជាំង ស្រុកអូររាំងឪ ខេត្តកំពង់ចាម (ត្បូងឃ្មុំ) ។ បងស្រីធ្វើជាកម្មករនៅរោងចក្រស្ករកៅស៊ូ នៅជប់ពាមជាំង ហើយក្រោយមកក៏បាត់ដំណឹងពីគាត់រហូត ។ ចាន់ថា មាឌធំល្មម សម្បុរខ្មៅស្រអែម និងមានកម្ពស់ ១.៥៥ ម៉ែត្រ ។

២) ភុន សាបី (ប្រុស) កើតឆ្នាំឆ្លូវ នៅពេលបាត់ខ្លួនមានអាយុ១៧ឆ្នាំ ។ បងប្រុស ភុន សាបី បានបាត់ខ្លួននៅឆ្នាំ១៩៧៧ អំឡុងពេលដែលខ្មែរក្រហមចាត់គាត់ឲ្យទៅធ្វើទ័ពនៅខេត្តស្វាយរៀង ។ ចាប់តាំងពីពេលចេញទៅធ្វើទ័ពក៏បាត់ដំណឹងពីបងប្រុសរហូត ។ សាបី មាឌធំល្មម សម្បុរខ្មៅស្រអែម កម្ពស់ ១.៦៥ ម៉ែត្រ ។ អ្នកទាំងពីរមានស្រុកកំណើតនៅភូមិពោធិ៍ស្នាយ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង ។ ខ្ញុំមានឪពុកឈ្មោះ ពោច ភុន (ស្លាប់) និងម្តាយឈ្មោះ ខាត់ ស៊ី និងមានបងប្អូនបង្កើតចំនួន១៤នាក់ ៖

១) ភុន ចាន់ថា (ស្រី) បាត់ខ្លួន

២) ភុន សម្បត្តិ (ប្រុស)

៣) ភុន សាបី (ប្រុស) បាត់ខ្លួន

៤) ភុន សាបន (ប្រុស) ស្លាប់

៥) ភុន សាបាន (ប្រុស)

៦) ភុន សុភុន (ប្រុស)

៧) ភុន សុគៀន (ប្រុស)

៨) ភុន សុគួន (ប្រុស)

៩) ភុន ចាន់ឌាន (ស្រី)

១០) ភុន ចាន់ឌី (ស្រី)

១១) ភុន សំអឿន (ស្រី)

១២) ភុន សំអួន (ស្រី)

១៣) ភុន សារួន (ប្រុស)

១៤) ភុន រិទ្ធិ (ប្រុស)

អាស្រ័យដូចបានរៀបរាប់ខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ និងដឹងដំណឹងអំពីបងប្រុសបងស្រីរបស់ខ្ញុំទាំងពីរ ដូចដែលបានរាយនាមខាងលើ សូមមេត្តាទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋានផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន និងទូរសព្ទ ០២៣ ២១៨ ០០៩ ឬក៏ទំនាក់ទំនងមកខ្ញុំ បាទផ្ទាល់តាមរយៈទូរសព្ទលេខ ០៩២ ២០៤ ៣៦៧ , ០៦៩ ៥៨៣ ៥០០ ឬសារអេឡិចត្រូនិច phunsaroun@gmail.com ។ **សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្ដល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្ដាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្ដាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្ដល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 212, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.